ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី “ឌុច”
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩**

**សវនាការលើកទី៤១**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ គុលវុឌ្ឍី

លោក ម៉ាតូ គ្រីស្តារ

*(Mr. Matteo Crippa)*

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

អានីស អះម៉េត

លោក ពេជ្រ សម្បត្តិ

លោក ហ្សាធិរី ឡាំពែល *(Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក គង់ ពិសី

លោក គីម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក តោត ខន

សួរដោយ លោក សេង ប៊ុនឃាង ផ្ដើមពី....ទំព័រ ៦
សួរដោយ លោក អានីស អះម៉េត ផ្ដើមពី ....ទំព័រ ១០
សួរដោយ លោកស្រី ម៉ាទីន ហ្សាកកាំង ផ្ដើមពី ....ទំព័រ ១២
សួរដោយ លោក គឹម ម៉េងឃី ផ្ដើមពី....ទំព័រ ១៦
សួរដោយ លោក គង់ ពិសី ផ្ដើមពី ....ទំព័រ ២២
សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី....ទំព័រ ២៤
សួរដោយ លោកស្រី លោកស្រី ម៉ារីប៉ូល កានីហ្សារ ផ្ដើមពី ....ទំព័រ ២៨

### អ្នកស្រី ជិន ម៉េត

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ....ទំព័រ ៣៤
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ....ទំព័រ ៨១

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អានីស អះម៉េត | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ភោគ ខន | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោកស្រី ម៉ារីប៉ូល កានីហ្សារ | បារាំង |
| លោកស្រី ជិន ម៉េត | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០២:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលលើដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ សុខន ដែលជាកិច្ចបន្តត្រូវសួរដោយភាគី ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាននិងអវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួមក្នុងកិច្ចដំណើរនីតិវិធីសវនាការនៅព្រឹកនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធានភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួនហើយ ។ ចំណែកឯបុគ្គលដែលត្រូវមកផ្ដល់សក្ខីនៅក្នុងព្រឹកនេះដែរ ក៏មានវត្តមានដែរ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន មុននឹងចាប់ផ្ដើមសវនាការថ្ងៃនេះ តំណាងអយ្យការសូមដាក់សេចក្ដីសន្និដ្ឋានសង្ខេបមួយជូនដល់អង្គជំនុំជម្រះសាលាដំបូង ។ យោងតាមវិធាន 87.4 នៃវិធានផ្ទៃក្នុងតំណាងអយ្យការ សូមស្នើដាក់នូវភស្តុតាងជាប្រវត្តិរូបអ្នកទោសស-២១ ដែលមានឈ្មោះ មុំ យ៉ូវ របស់សាក្សីឈ្មោះ នង ចាន់ផល ហើយប្រវត្តិរូបនេះគឺមានលេខ ERN ជាភាសាខ្មែរ 00346163 ហើយជាភាសាអង់គ្លេសគឺ 00346317 ហើយឯកសារនេះក៏បានបកប្រែជាភាសាបារាំងហើយដែរ គឺមានលេខ ERN00347087 ឯកសារនេះគឺបញ្ជាក់បន្ថែមទៅលើសក្ខីកម្មរបស់ នង ចាន់ផល ។ ជាពិសេសគឺបញ្ជាក់ថា នង ចាន់ផល ហ្នឹងត្រូវបានឃុំខ្លួននៅមន្ទីរស-២១ នៅពេលដែលគាត់-- នៅពេលដែលម្ដាយគាត់ត្រូវបានចាប់បញ្ជូនទៅស-២១ ហើយ នង ចាន់ផល ក៏ទៅជាមួយម្ដាយរបស់គាត់ដែរ ។

ការិយាល័យសហព្រះរាជអាជ្ញាបានទទួលប្រវត្តិរូបនេះពីមជ្ឈមណ្ឌលឯកសារកម្ពុជា*(ឌីស៊ីខេម)*

នៅល្ងាចថ្ងៃសុក្រ តាមរយៈអ៊ីម៉ែល ហើយសូមបញ្ជាក់ថាការិយាល័យសហព្រះរាជអាជ្ញាមិនបានស្នើសុំដល់ *ឌីស៊ីខែម* ដើម្បីឱ្យផ្តល់ឯកសារនេះទេ ។ គឺ *ឌីស៊ីខែម* បានស្រាវជ្រាវរក ហើយក៏បានរកឃើញនូវឯកសារនេះដោយខ្លួនឯង បន្ទាប់ពីបានស្តាប់ការសួរដេញដោលសាក្សីឈ្មោះ នង ចាន់ផល នេះ ។

នៅពេលដែលការិយាល័យសហព្រះរាជអាជ្ញាទទួលបានឯកសារនេះ ភ្លាមក៏បានថតចម្លងចែកជូនគ្រប់ភាគីទាំងអស់ផងដែរ ។ ម្យ៉ាងវិញទៀត សូមជម្រាបជូនអង្គជំនុំជម្រះផងដែរថា នៅថ្ងៃដែលសាក្សី នង ចាន់ផល មកធ្វើសក្ខីកម្មនោះ ជនជាប់ចោទក៏បាននិយាយផងដែរ ថាបើសិនជាមានប្រវត្តិរបស់ មុំ យ៉ូវ ដែលជាម្តាយរបស់ នង ចាន់ផល នេះគឺអាចបញ្ជាក់បានថា នង ចាន់ផល ក៏ត្រូវបានឃុំខ្លួននៅមន្ទីរស-២១ ដែរ ។ ហើយជនជាប់ចោទក៏បានស្នើសុំឱ្យការិយាល័យសហព្រះរាជអាជ្ញា ដើម្បីរកឯកសារនេះផងដែរ ។

ដូច្នេះ តំណាងអយ្យការសូមស្នើដាក់ឯកសារដែលជាប្រវត្តិរូបអ្នកទោសស-២១ ដែលមានឈ្មោះថា មុំ យ៉ូវ ដែលជាម្តាយរបស់ នង ចាន់ផល នេះយកមកធ្វើជាភស្តុតាង ។ ដោយយោងតាមវិធាន87.4 នៃវិធានផ្ទៃក្នុង ។ សូមអរគុណ ។

[០៩:០៨:០៣]

**ប្រធានអង្គជំនុំ៖**

ភាគីផ្សេងទៀត តើមានការកត់សម្គាល់អ្វីលើឯកសារប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ដែលមានឈ្មោះដើម មុំ យ៉ូវ ដែលបានស្នើសុំដាក់ដោយសហព្រះរាជអាជ្ញានេះដែរឬទេ?

សូមអញ្ជើញមេធាវីការពារក្តី ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន! សូមគោរពលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ ។ ដូចដែលខ្ញុំបានជម្រាបពីថ្ងៃមុនថា កូនក្តីខ្ញុំជាជនជាប់ចោទបានសារភាពទទួលស្គាល់ឧក្រិដ្ឋកម្មនៅទួលស្លែងចំនួន ១២.៣៨០នាក់ ។ អ៊ីចឹងជនដទៃទៀតដែលថា ខ្លួនបានជាប់នៅស-២១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំបានជម្រាបជូនលោកព្រះរាជអាជ្ញាជាតិនិងអន្តរជាតិថា ឲ្យតែមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា គាត់ពិតជាជាប់នៅស-២១ ប្រាកដមែន គឺខ្ញុំជាមេធាវីការពារអត់ជំទាស់ទេ គឺសូមទទួលមិនមែនតែម្នាក់ទេ គឺប៉ុន្មាននាក់ទៀតមកក៏យើងទទួលទាំងអស់ឲ្យតែមានភស្តុតាងគ្រប់គ្រាន់។

ដូច្នេះ បើសិនជាមានប្រវត្តិរូបម្តាយរបស់ នង ចាន់ផល នៅក្នុងស-២១ ពិតប្រាកដមែនគឺខ្ញុំអត់

មានជំទាស់ទេ គឺសូមទទួលដោយរីករាយ។ សូមអរគុណ ។

[០៩:១០:១២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**លោកស្រី ម៉ារីប៊ូល កានីហ្សារ៖**

លោកប្រធាន យើងផ្តល់សេចក្តីសង្កេតថា ឯកសារនេះត្រូវបានបង្កើតឡើងគឺថា ក្រោយកាលកំណត់នោះ ហើយយើងទទួលយកនៅថ្ងៃនេះ គឺជាការលើកលែងមួយ ។ ហើយនៅក្នុងអនាគតទៅយើងនឹងបន្ត-- ត្រូវជំទាស់នូវឯកសារអ្វីដែលបង្ហាញយឺតកាលកំណត់នេះដូចជាឯកសារដែលបង្ហាញជូនដោយសហព្រះរាជអាជ្ញានោះ ។

**លោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន! សូមគោរពអង្គជំនុំជម្រះទាំងមូល ។

តាងនាមឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ពួកខ្ញុំយើងខ្ញុំសូមគាំទ្រនូវការលើកឡើងរបស់ព្រះរាជអាជ្ញា ហើយនិងសូមគាំទ្រឲ្យដាក់ឯកសារទាំងអស់នោះចូលនៅក្នុងសំណុំរឿងដើម្បីធ្វើជាភស្តុតាងហើយមិនខុសអំពីការដាក់ឯកសារក្រោយៗទៀតដែលរកបាននៅពេលក្រោយអំពីការស៊ើបអង្កេតផងដែរ ។ ដូចដែលលោកស្រី ម៉ាទីនហ្សាកកាំង គាត់បានលើកឡើងកាលពីម្សិលមិញ គាត់ថាការដាក់ឯកសារយឺតគឺវាជាបញ្ហាដែលបណ្តាលមកពីការទំនាក់ទំនងរវាងជនរងគ្រោះ ហើយនិងការទទួលបាននូវព័ត៌មានយឺត ។ ហេតុដូច្នេះ នៅក្នុងប្រព័ន្ធច្បាប់នេះ គឺតម្រូវឲ្យចៅក្រមស៊ើបគាត់ស៊ើបរកតែភស្តុតាងណាដែលមុន ហើយការដាក់ពាក្យបណ្តឹងយឺត ដូច្នេះដែលធ្វើឲ្យយើងខ្ញុំមានការលំបាក ។

ដូច្នេះ ការលំបាកបែបនេះ គួរតែជាករណីលើកលែង ហើយនិងសំខាន់បំផុតសម្រាប់អង្គជំនុំជម្រះ ដើម្បីជួយសម្រួលដល់ការចូលរួមឲ្យមានប្រសិទ្ធភាពរបស់ជនរងគ្រោះនូវក្នុងដំណើរការស្វែងរកយុត្តិធម៌នេះ ។ សូមអរគុណ ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្គេកអ៊ាវ តើលោកមានឯកសារប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ឈ្មោះដើម មុំយ៉ូវ ហើយឬនៅ? ហើយលោកកត់សម្គាល់ឃើញថា ឯកសារនេះយ៉ាងម៉េចដែរ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! សូមគោរពអង្គជំនុំជម្រះសាលាដំបូងជាទីគោរព! ឯកសារនេះខ្ញុំទទួលស្គាល់ ។ ទីមួយ ជាឯកសារនៅទួលស្លែង ដោយមាន TSL ជាភស្តុតាងស្រាប់ ហើយទីពីរ អក្សរដៃ ខ្ញុំទទួលស្គាល់ទៀតថា ពិតជាអក្សរដៃបុគ្គលិករបស់មន្ទីរស-២១ ។ ទន្ទឹមនេះតាមរយៈអង្គសវនាការយើងនេះ ខ្ញុំសូមទោសដល់លោក នង ចាន់ផល ដែលពេលនោះខ្ញុំមិនទាន់ឃើញឯកសារ ខ្ញុំមានការខុសឆ្គងទៅលើគាត់ខ្លះ ។ ដូច្នេះ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

[០៩:១៦:១១]

**ប្រធានអង្គជំនុំ៖**

អរគុណ ។ សូមអញ្ជើញលោកមេធាវី ។

**លោក អាឡាំង វែនណឺ៖**

លោកប្រធាន សូមពន្យល់ពីរបីម៉ាត់នៅចុងក្រោយ គឺថាហេតុអ្វីដែលថា យើងបានបង្ហាញឯកសារហ្នឹងយឺត ។ តាមការយល់ហ្នឹង ក្នុងអតីតកាល គឺថាអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា គឺថាបានព្យាយាមៗស្វែងរកឯកសារនេះ ហើយការស្រាវជ្រាវនោះ គឺត្រូវបានធ្វើនៅក្នុងប្រព័ន្ធ *ដេតាបេស* (Database) ប៉ុន្តែ អ្វីដែលជាលទ្ធផលនោះ គឺថាក្រោយពីការសវនាការ គេបានស្វែងរកម្តងទៀត គឺថាលើកនេះបានរកឃើញ ហេតុអ្វីមិនរកឃើញពីមុន ពីព្រោះថា មានការសរសេរប្រកបអក្សរហ្នឹង ខុសគ្នា ដើម្បីរកការប្រកបខុសគ្នា ហ្នឹងហើយជាមូលហេតុដែលថា រកនៅថ្ងៃសុក្រ គឺថាមិនបានរកឃើញពីមុនទេ ដោយសារមានការប្រកបឈ្មោះលើកនេះត្រូវ ។ ដូច្នេះ ជាមតិមួយដែលថា មានការបំភ្លឺដល់អង្គតុលាការសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី! អង្គជំនុំជម្រះ ដោយសារឯកសារនេះ បានស្នើសុំដាក់ពីខាងតំណាងសហព្រះរាជអាជ្ញា ហើយភាគីទាំងអស់មិនជំទាស់ទេ ជាពិសេសគឺជនជាប់ចោទនិងមេធាវីការពារ គឺបានទទួលស្គាល់នូវឯកសារនេះ ។ អ៊ីចឹង អង្គជំនុំជម្រះសម្រេចទទួលឯកសារនេះ ដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ ដោយឡែក គឺអង្គជំនុំជម្រះសូមជម្រាបទៅមេធាវីការពារក្តីអន្តរជាតិ សូមជ្រាបថាតាមវិធានផ្ទៃក្នុង គឺមិនកំហិតកំណត់ជាក់លាក់នៅក្នុងពេលវេលានៃការទទួលឯកសារនោះទេ ។

អង្គជំនុំជម្រះនឹងពិចារណាទៅតាមករណីជាក់ស្តែង នៃស្ថានភាពក្នុងការស្នើសុំដាក់ឯកសារជាក់

លាក់ណាមួយ ថាត្រូវទទួល ឬក៏មិនទទួល ហើយទទួលហើយ ត្រូវសម្រេចដាក់មកពិភាក្សាដេញដោល ឬក៏អត់ ។ នោះធ្វើទៅតាមនីតិវិធីទៅតាមករណីជាក់ស្តែង ដូចហេតុផលមេធាវី ឬក៏សហព្រះរាជអាជ្ញាបានលើកឡើងអំពីកាលៈទេសៈពិសេសដែលនាំឲ្យមានបញ្ហាខកខានមិនបានស្រាវជ្រាវរកឯកសារ ឬក៏ការស្រាវជ្រាវរកហ្នឹងដល់នាទីចុងក្រោយនៃការពិភាក្សាដេញដោល ។ ប៉ុន្តែ មិនទាន់ហួសពេលទេ ដោយសារអង្គជំនុំជម្រះមិនទាន់បានបញ្ចប់នូវនីតិវិធីដេញដោលនៅឡើយ ។ អ៊ីចឹង ភាគីគឺអាចនៅតែមានពេល មានឱកាសក្នុងការផ្តល់នូវភស្តុតាងជាក់លាក់ ដើម្បីឲ្យអង្គជំនុំជម្រះពិនិត្យពិចារណា គ្រាន់តែការដេញដោលហ្នឹងនៅពេលណាមួយ គឺយើងនឹងកំណត់កម្មវិធីជាក់លាក់កុំឲ្យមានការប្រជែងជាមួយនឹងកាលវិភាគដែលយើងបានគ្រោងទុក ។

អញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន! ខ្ញុំជឿថា គឺថាអាចជាបញ្ហាការបកប្រែ ឬខ្ញុំបានពិនិត្យឃើញថា ក្នុងគោលបំណងនៃការកត់ត្រាប្រតិចារឹក ជាសំខាន់យើងចង្អុលបង្ហាញថា ត្រូវដាក់ឯកសារនេះចូលក្នុងសំណុំរឿង ហើយត្រូវបានបង្ហាញ ឬរកឃើញនៅក្នុងពេលសវនាការ ។ អ៊ីចឹងតម្លៃនៃឯកសារ គឺអាចតទល់គ្នាបាន ប៉ុន្តែយើងបានសម្រេចថា ដាក់ចូលកក្នុងសំណុំរឿង ដោយសារមិនមានការជំទាស់ពីភាគីផ្សេងទៀត ។

[០៩:១៩:៥៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម ដែលបានបញ្ជាក់បន្ថែមលើបញ្ហានេះឲ្យកាន់តែច្បាស់ ។ ជាកិច្ចបន្តគឺយើងចាប់ផ្តើមបន្តនីតិវិធីនៃការពិភាក្សាដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អោគ ខន ដែលជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងសួរដេញដោល ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ ប្រសិនបើមានសំណួរសូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញា ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** អរគុណលោកប្រធាន! ជម្រាបសួរលោកពូ អោគ ខន កាលពីម្សិលមិញ លោកបាននិយាយថានៅក្នុងអង្គភាព៣១៧ ប្រសិនបើមានអ្នកប្រព្រឹត្តិខុសត្រូវបញ្ជូនទៅ ស-២១ ឬក៏ទៅព្រៃស ។

ហេតុអីបានជាលោកដឹងថាដូច្នេះ? តើកន្លងមកហ្នឹង អង្គភាពនោះមានវិធានការបែបនេះមែនទេ?

**លោក សោត ខន៖**

**ឆ៖** ជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា! នៅអង្គភាព៣១៧ ចំណុះឲ្យកងពល៣១០ ដែលគេចាត់ទុកថា ជាកងវិន័យ គឺជាកងកែប្រែ រស់នៅទីនោះប្រព្រឹត្តធ្វើការងារដោយទុរន់ទុភា ដោយធ្វើស្រែប្រាំងនៅបឹងបាយ៉ាបយើងនេះ ក៏កាលបង្ហូរទឹកនៅព្រែកព្នៅ ។ បង្ហូរទឹកបឹងបាយ៉ាបអស់ទៅ ធ្វើស្រែប្រាំងលើនោះ ។ ដូច្នេះកង៣១៧ គឺធ្វើនៅទីនោះ បង្ខំធ្វើការដោយធ្ងន់ធ្ងរ ។ បើយុទ្ធជន ឬក៏កម្មាភិបាលដែលធ្វើការខ្ជិលច្រអូស ឬក៏ពោលថា ហូបមិនឆ្អែត ដេកមិនបានគ្រប់គ្រាន់ គេតាមដានទាំងយប់ទាំងថ្ងៃ គឺអាចចាប់បញ្ជូនមកស-២១ ក៏ប៉ុន្តែពេលនោះ ខ្ញុំមិនដឹងថា ស-២១ នៅទីណាទេ ប៉ុន្តែឮតែគេថា ស-២១ ឬក៏ព្រៃស តែប៉ុណ្ណោះទេ ។

**ស៖** អរគុណ ។ នៅក្នុងពាក្យបណ្ដឹងរបស់លោកក៏បានរៀបរាប់ដែរ ថានៅក្នុងខែមីនា ឆ្នាំ១៩៧៦ លោកធ្លាប់បានទៅការពារនៅមន្ទីរសេនាធិការរបស់ សុន សេន តាមការចាត់តាំងរបស់ឈ្មោះ អឿន ។ តើពេលនោះ លោកត្រូវបានគេចាត់ឲ្យទទួលភារកិច្ចអ្វីខ្លះនៅមន្ទីរសេនាធិការនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា! គឺនៅពេលនោះ ខ្ញុំក៏ពុំសូវចាំច្បាស់ដែរ ព្រោះថា ការចាត់តាំងរបស់ អឿន ដែលឲ្យទៅនៅមន្ទីរស្នាក់ការ នៅការពារនៅកន្លែងនោះ គឺមានរយៈតែខ្លីទេ ព្រោះថា ខ្ញុំមិនបានស្គាល់ទីកន្លែងច្បាស់លាស់ ប៉ុន្តែការទៅ គឺទៅមែន ។

[០៩:២៣:២៩]

**ស៖** តើលោកទៅការពារនៅមន្ទីរសេនាធិការនោះរហូតដល់ពេលណា លោកចាំបានទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! គឺបានរយៈពេលតែ១០ថ្ងៃទេ ខ្ញុំបកមកវិញ ។

**ស៖** ហេតុអ្វីបានជាលោកបកមកវិញ មានមូលហេតុអ្វីទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! ពេលនោះ គឺវាឆ្នាំ៧៦ ខ្ញុំបកមកវិញ គឺគេបញ្ជូនខ្ញុំមកនៅហ្នឹងជាមួយនឹង ទី វិញ នៅមន្ទីរពិការ ។ ហើយគេដកពីពិការមកវិញ បានពេលដែលចាប់ កុយ ធួន ហើយនិង អឿន គឺខ្ញុំបាន ទុយ យកមកដាក់នៅមន្ទីរកងពលវិញដដែល ។

**ស៖** អរគុណ ។ នៅពេលម្សិលមិញ លោកបានជម្រាបជូនអង្គជំនុំជម្រះថា នៅពេលនោះ លោកបានទៅសមរភូមិប្រយុទ្ធ ហើយពេលនោះលោកមានតួនាទីជាអ្នកកាន់តេអូ ។ នៅពេលនោះ តើលោកដឹងទេ ថាទាហានខ្មែរក្រហម មានចាប់បានទាហានវៀតណាមអ្វីទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក! ព្រោះថានៅពេលនោះ ដែល ទុយ បានចាប់តាំងខ្ញុំទៅនៅស្វាយរៀង ខ្ញុំបានកាន់គេអូមែន ហើយក៏ការចាប់ខ្លួនរបស់កងទ័ពវៀតណាម នៅពេលនោះក៏បានចាប់ឃើញចាប់បានមួយចំនួនដែរ ។ ប៉ុន្តែ ខ្ញុំមិនច្បាស់ថា ប៉ុន្មាននាក់នោះទេ គឺចាប់បាន ប៉ុន្តែគេមិនដឹងជាបញ្ជូនទៅណា? ព្រោះខ្ញុំនៅទីនោះដែរ ។

**ស៖** អរគុណ ។ តើលោកធ្លាប់ដឹងទេថា មានការបញ្ជូនកងទ័ពវៀតណាមទាំងនោះទៅមន្ទីរស-២១ តើលោកដែលឮ ឬក៏ដឹងពីបញ្ហានេះដែរទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! គឺថាពេលនោះ ដោយខ្ញុំនៅមមារញ៉ីកនឹងខាងតេអូពេក ខ្ញុំក៏មិនបានចាប់អារម្មណ៍ថា ចាប់បញ្ជូនទៅណាទេ? ព្រោះថាខ្ញុំមិនដឹងថា ស-២១ ឬក៏ទៅទីណានោះទេ?

**ស៖** អរគុណ ។ វិលមកនៅក្នុងមន្ទីរស-២១ វិញ នៅពេលដែលលោកត្រូវបានបញ្ជូនទៅក្នុងបន្ទប់ឃុំឃាំងរួមមួយ ហើយពេលនោះលោកបានឃើញឈ្មោះ យឹម យ៉ាវ នៅទីនោះដែរ ។ តើក្រៅពី យឹម យ៉ាវ នោះ តើលោកស្គាល់អ្នកណាផ្សេងទៀតទេ? ហើយតើនៅក្នុងទីនោះមានអ្នកទោសស្ត្រី និងកុមារដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍សហព្រះរាជអាជ្ញា! គឺនៅពេលដែលខ្ញុំចូលដល់ គេដាក់ខ្នោះជើង និងស្រាយដៃរួចហើយ ទើបគេស្រាយមុខ ។ ស្រាយមុខ ពេលនោះ ខ្ញុំបើកភ្នែកទៅ ឃើញឈ្មោះ យឹម យ៉ាវ នៅទីនោះពិតមែន ។ ឯអ្នកទោសស្ត្រី និងកុមារនៅទីនោះ គឺអត់មានទេ គឺមានតែមនុស្សប្រហាក់ប្រហែលនឹងខ្ញុំ កាលនោះ ខ្ញុំអាយុ២២ឆ្នាំហើយ ខ្ញុំនៅក្មេងទេ មិនឃើញស្ត្រី ឬកុមារនោះទេ ។

**ស៖** អរគុណ ។ នៅក្នុងបន្ទប់រួមនោះ តើលោកឃើញអ្នកទោសមានសភាពយ៉ាងម៉េចដែរ ? ហើយលោកមានឃើញ មានជនបរទេសនៅក្នុងបន្ទប់នោះដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍សហព្រះរាជអាជ្ញា! គឺនៅក្នុងនោះៗ គឺខ្ញុំមិនបានឃើញជនបរទេសទេ គឺឃើញតែខ្មែរយើងធម្មតា ហើយនិងមានសភាពទ្រុឌទ្រោម ដោយគ្មានខ្វះអាហារដេកចុក-- ដេកនៅឃើញថាពិបាក ស្គមម្នាក់ៗ គឺអត់មាន ដូចជាគ្មានកម្លាំងកំហែង ។

[០៩:២៧:៤៩]

**ស៖** អរគុណ ។ វិលមកកន្លែងដែលគេបញ្ជូនលោកទៅសម្លាប់ ហើយលោកបានជម្រាបអង្គសវនាការថា មុននឹងគេសម្លាប់លោក គឺគេបានបញ្ជូនលោកក្នុងផ្ទះមួយ តើលោកបានដឹង ឬក៏បានឮអ្នកយាមនៅទីនោះនិយាយពីអ្វីខ្លះដែរទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! គឺនៅពេលនោះ គេចងដៃ ចងភ្នែក ហើយនិងដឹកចូលទៅហ្នឹង គឺខ្ញុំស្មានមិនខុស គឺផ្ទះនោះ គឺជាផ្ទះឈើទេ ។ ក៏ប៉ុន្តែ អ្នកយាមដឹកទៅនោះ គេក៏មិនឮថា និយាយអ្វីក្រៅពីបញ្ចូលអ្នកទោសទៅក្នុងនោះ ក៏គេបិទទ្វារជាប់ទៅ ហើយខ្ញុំមិនដឹងថាទីនោះគឺជាអ្វីទេ ព្រោះថាជិតអស់ហើយងងឹតផង ។

**ស៖** អរគុណ ។ នៅពេលដែលលោកវារចេញពីរណ្ដៅដែលគេសម្លាប់មនុស្សនោះ តើលោកមានឃើញអ្វីគួរឲ្យចាប់អារម្មណ៍ដែរទេ? ឧទាហរណ៍ដូចជា ផ្ទះសម្រាប់ដាក់អ្នកទោសមុននឹងយកទៅសម្លាប់ តើមានរូបរាងយ៉ាងម៉េច? អីយ៉ាងម៉េច? តើលោកអាចបញ្ជាក់បានទេ?

**ឆ៖** ជម្រាបប្រសាសន៍! គឺនៅពេលនោះ ដែលខ្ញុំបានងើបពីរណ្ដៅមក គឺដែលមានខ្មោចចំនួនបីនាក់នៅពីលើសង្កត់ទៀតនោះ គឺខ្ញុំងើបឡើង ដែលបានផ្ងារខ្លួន ភ្ញាក់ប្រាណ បានអង្គុយងើបឡើងមកនោះ គឺមានឃើញសាកសពមួយ ។ គ្រាន់តែក្បាលនោះ វាបែកខ្ទេចអស់ទៅហើយ ក៏ប៉ុន្តែចង្រិតនៅត្រង់ក គឺនៅតឹកៗបន្តិច ហើយខ្ញុំអាចសន្និដ្ឋានបានថា មិនរស់ទេ ។ ខ្ញុំក៏បានងើបរំកិលផុតពីអន្លង់នោះ ខ្ញុំអើតទៅឃើញផ្ទះមួយនៅឆ្ងាយ បើតាមបាន់ស្មានទៅ មើលឃើញព្រិលៗឆ្ងាយ ប្រហែលជាមួយរយ ទៅពីររយម៉ែត្រដែរ ព្រោះផ្ទះនោះ ផ្ទះឈើតែប្រក់ មិនដឹងជាប្រក់អ្វីទេ ព្រោះខ្ញុំមើលឆ្ងាយដែរ ។

[០៩:៣០:០៣]

**ស៖** អរគុណ ។ តើមានសំណង់អ្វីផ្សេងទៀតដែរទេ ឬក៏ដើមឈើអ្វីដែលគួរចាប់អារម្មណ៍ ដែរទេនៅពេលនុ៎ង?

**ឆ៖** ជម្រាបប្រសាសន៍សហព្រះរាជអាជ្ញា! គឺនៅពេលនោះ ដែលខ្ញុំសម្លឹងទៅ ឃើញមានដើមឈើមួយដែលខ្ញុំបាទលូនទៅ ដែលវៀរផងដើរផងនោះ ទៅដល់ឈើនោះឯងខ្ញុំបានរុះខ្សែដាច់នឹងគល់ឈើធំមួយនោះមិនដឹងជាដើមឈើអ្វីទេ ព្រោះខ្ញុំវាមើលមិនច្បាស់ដែរពេលនោះជិតវាភ្លឺហើយ ក៏ប៉ុន្តែមិនអាចសន្និដ្ឋានថាដើមអ្វី ។

**ស៖** អរគុណ ។ រហូតមកដល់ពេលនេះ តើលោកអាចស្មានដឹងទេថា កន្លែងនុ៎ងនៅម្ដុំណាដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍! គឺរហូតដល់ពេលនេះខ្ញុំមិនដែលបានទៅដែរ ព្រោះថាជើងឯក ប៉ុន្តែតាមការស្មាន ទីកន្លែងនោះប្រហែលជានៅជើងឯកហើយ ក៏ប៉ុន្តែពេលនោះ ក៏ខ្ញុំមិនដែលទៅទេ តាំងពីពេលនោះមករហូតមកដល់ឆ្នាំ២០០៨ ដែលខ្ញុំបានចូលមកស-២១ នេះ ក៏មិនបានទៅដល់ទៅជើងឯកដែរ ។

**ស៖** អរគុណ ។ នៅពេលដែលលោកជាប់នៅស-២១ នោះ តើលោកមានដឹងទេថា អ្នកណាជាប្រធានរបស់មន្ទីរស-២១ នោះ?

**ឆ៖** ជម្រាបប្រសាសន៍! នៅទីនោះខ្ញុំមិនដឹងថា អ្នកណាជាប្រធានទេ ពីព្រោះថា តែជាប់ឃុំឃាំង គឺគ្មានពេលនឹងដើរ ឬក៏អើតមើលឲ្យបានឃើញគ្រប់ជ្រុងជ្រោយនោះទេ ព្រោះអើតមើលបានតែបរិវេណមន្ទីរឃុំឃាំងតែប៉ុណ្ណោះ ឯជុំវិញ គឺសុទ្ធតែជញ្ជាំងជិត ហើយក៏មានបង្អួចដែរ ក៏ប៉ុន្តែមើលបានតែក្បាល ឃើញតែក្បាលអ្នកយាមទេ ហើយអ្នកដើរទៅមកៗ ។ ប៉ុន្តែ ខ្ញុំមិនអាចដឹងបានថា អ្នកទទួលខុសត្រូវនៅ ស-២១ នោះជាអ្នកណាទេ ។

**ស៖** អរគុណ ។ ត្រឡប់មកពេលដែលគេចាប់លោកវិញ តើនៅពេលនោះ គេមានប្រាប់ លោកថា លោកខុសអ្វីដែរទេ?

[០៩:៣២:១៤]

**ឆ៖** បាទ, ជម្រាបប្រសាសន៍! នៅពេលគេចាប់ខ្លួនខ្ញុំ ក៏ខ្ញុំអត់មានដឹងខ្លួនថា គេទៅចាប់ទេ ពីព្រោះថា ពេលនោះសម្រាកពីការងារប្រហែលជាម៉ោងប្រាំកន្លះហើយ ខ្ញុំបានឡើងចេញមក ឃើញឡានឡាំប្រ៊ីតា កង់បីនោះចូលទៅ ខ្ញុំក៏មិនចាំចាប់អារម្មណ៍ថា គេចាប់ខ្ញុំទេ ទាល់តែឃើញយុទ្ធជនពីរនាក់ ហើយនិងបើកបរនោះម្នាក់ វាបីនាក់ ។ ដល់ពេលគេហៅខ្ញុំមកជិតទៅ គេក្ដង់ចាប់ចងបណ្ដោយទៅ ខ្ញុំអត់មាន អត់មានឮថា គេថាអ្នកឯងខុសអ្វីផង ។

**ស៖** អរគុណ ។ ពេលដែលគេចាប់លោកដាក់ឡាន តើគេចាប់នៅកន្លែងណា ហើយថា ទិសដៅរបស់ឡាននោះ មានដំណើរឆ្ពោះទៅទិសខាងណាដែរ លោកចាំបានទេ?

**ឆ៖** សូមជម្រាបប្រសាសន៍! ឃើញថា ការចាប់នោះ ឃើញថាឡាននោះ គឺមានបិទជិតអស់ហើយ គឺមានផ្ដាក់ ទម្លាក់កំណាត់ កំណាត់នោះបែបជាកំណាត់ក្រាស់ បិទជិតចំហៀង ហើយនិងក្រោយ ខាងមុខអ្នកបើកក៏គេមិនឲ្យឃើញដែរអ្នកបើក*ឡាំប្រ៊ីតា* គេបិទជិតខាងមុខខាងក្រោយ ចំហៀងសងខាង ហើយខ្ញុំគេចូលទៅឲ្យអង្គុយកណ្ដាល ហើយអ្នកយាមកៀនកៀកអង្គុយម្ខាងម្នាក់ៗ ។ ហេតុដូច្នេះ ខ្ញុំក៏មិនដឹងថា ឡាននោះវាវិលទៅទិសខាងជើង ឬក៏ទិសខាងត្បូងនោះទេ ។

**លោក សេង ប៊ុនឃាង៖**

អរគុណ ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ ប៉ុន្តែតំណាងអយ្យការមានសំណួរមួយចង់សួរបញ្ជាក់ទៅជនជាប់ចោទតាមរយៈលោកប្រធាន តើលោកប្រធានអនុញ្ញាតដែរទេ បន្ទាប់ពីតំណាងសហ

ព្រះរាជអាជ្ញាអន្តរជាតិបានសួរសំណួរហើយ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក អានីស អះម៉េត៖**

លោក ភោគ ខន លោកត្រូវបានដេញដោលយ៉ាងច្រើនដោយចៅក្រម និងសហសេវិករបស់ខ្ញុំ ហើយខ្ញុំមិនមានសំណួរច្រើននោះទេ ។

**ស៖** ខ្ញុំមានសំណួរមួយ សុំឱ្យលោកបំភ្លឺតាមការលោកឆ្លើយកាលពីម្សិលមិញ ។ កាលពីម្សិលមិញ លោកប្រធានបានចង្អុលលើកឡើងអំពីចំណុចខុសគ្នាមួយ រវាងអ្វីដែលលោកបានលើកឡើងនៅទីនេះ និងនៅក្នុងពាក្យសុំរបស់លោក ។ ចំពោះចំណុចនេះ ខ្ញុំសូមឱ្យលោកធ្វើការបញ្ជាក់បំភ្លឺ ថាតើលោកបានជួបជាមួយនិងអង្គការផ្សេងៗទុំងប៉ុន្មានដងនៅឆ្នាំ២០០៨ នៅពេលដែលលោកជួបជាមួយនឹងជួប-- នៅពេលដែលលោកបានមកបំពេញពាក្យសុំនោះ តើលោកជួបជាមួយអាដហុកប៉ុន្មានដង អង្គការអាដហុក?

[០៩:៣៥:៣៨]

**ឆ៖** សូមជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា! កាលពីឆ្នាំ២០០០ ចុងឆ្នាំ២០០៧ហើយ គេមានធ្វើការប្រជុំមួយនៅក្នុងវត្តបន្ទាយស្រី ដែលមានអង្គភាព អង្គការក្រៅរដ្ឋាភិបាល គឺសមាគមអាដហុក ក៏បានអញ្ជើញខ្ញុំទៅធ្វើការនៅទីនោះ ហើយក៏បានរៀបរាប់ពីជីវប្រវត្តិរបស់ខ្ញុំនៅពេលនោះ ។ មិនដឹងជាថ្ងៃខែ ខ្ញុំភ្លេចហើយ ហើយក៏បានរៀបរាប់រួចទៅក៏គាត់បានកត់កំណត់ហេតុ ធ្វើជាសំណុំរឿង សំណុំបែបបទបញ្ជូនទៅឱ្យខ្ញុំនៅភូមិចំនួនម្តង ។ ពេលនោះ ខ្ញុំក៏មិនបានជាចាប់អារម្មណ៍មើលទេ ព្រោះថាគេឱ្យផ្តិតមេដៃរួច ក៏បញ្ជូនមកវិញទៅ គឺខ្ញុំបានជួបនឹងសមាគមអាដហុកនៅពេលនោះ នៅឯភូមិនោះ ជួបបានតែពីរដងនៅកន្លែងប្រជុំម្តងនៅនឹងភូមិម្តងតែប៉ុណ្ណោះទេ ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ តើឯកសារនេះត្រូវបានអានឱ្យលោកស្តាប់ដែរឬទេ? នៅពេលដែលលោកផ្តល់ជាចំណុចផ្សេងៗនៅក្នុងនុំង ឬក៏នៅពេលដែលលោកត្រូវបានផ្តិតមេដៃនោះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! គឺនៅពេលនោះ ខាងអង្គភាពអាដហុក គាត់មិនបានយកទៅទេ គាត់ផ្ញើរតាមរយៈ *"ខមប្រ៉ែហ្វល"* គាត់ហៅខ្ញុំពីផ្ទះទៅ ទៅផ្តិតមេដៃនៅផ្ទះឈ្មោះ ស្រី ឡូញ ដែលជាភូមិជាមួយគ្នាដែរ ក៏គាត់បានយកលិខិតមកៗជួបខ្ញុំ ខ្ញុំក៏បានអានបានរយៈតែខ្លី ព្រោះមិនបានអានជាប់នោះ

ទេ ក៏ខ្ញុំក៏គេថា ហ៎!ផ្ដិតមេដៃទៅអាឯកសារនេះប្រញាប់បញ្ជូនមកលើ នេះក៏ខ្ញុំសូមអភ័យទោសពីនេះដែរ ព្រោះខ្ញុំខុសពីខ្លួនខ្ញុំ ឬក៏យ៉ាងម៉េចទេ ព្រោះខ្ញុំមិនបានអាន ហេតុដូច្នេះ សូមលោកសហព្រះរាជអាជ្ញាអនុគ្រោះ នៅពេលនោះ ព្រោះខ្ញុំក៏ផ្ដិតមេដៃ ក៏យកមកបាត់ទៅ ។

**លោក អានីស អះម៉េត៖**

លោក លោកស្រីចៅក្រម ខ្ញុំអត់មានសំណួរទៀតទេ ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ។ សូមអរគុណ ។

**សួរដោយលោក សេង ប៊ុនឃាង៖**

លោកប្រធានសំណួរដែលតំណាងអយ្យការចង់សួរទៅជនជាប់ចោទ សួរថា តើនូវការចេញចាប់អ្នកទោសនៅទីក្រុងភ្នំពេញ តើគេយករថយន្តឡាំប្រ៊ីតា ទៅប្រើប្រាស់ដែរឬទេ? អរគុណ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអាចឆ្លើយបានទេ មិនចាំបាច់តាមរយៈប្រធានអង្គជំនុំជម្រះទេ ព្រោះភាគីសហព្រះរាជអាជ្ញាមានសិទ្ធិក្នុងការសួរ គ្រាន់តែសុំការអនុញ្ញាតសួរបានហើយ អ៊ីចឹងសំណួរនេះជនជាប់ចោទអាចឆ្លើយតបបាន ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! នៅសម័យស-២១ ដែលខ្ញុំធ្វើប្រធាននេះក៏ដោយ តាំងពី ណាត មកក៏ដោយ ឡាំប្រ៊ីតា មានតែមួយទេជារបស់ដែលខ្ញុំបាទប្រើ ។ ឯចំណែកចេញទៅទទួលមនុស្សកន្លែងផ្សេង គឺយកអាកាត់សង់កាត់ (៤០៤) ចិន សូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ជាកិច្ចបន្តនេះ សូមប្រគល់វេទិកាទៅមេធាវីអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ។ ហើយតើមេធាវីអ្នកតំណាងឲ្យ ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមណានិយាយមុន? ក្រុមបីដែលជាតំណាងឲ្យភោគ ខន? សូមអញ្ជើញ ។

**លោក គីម ម៉េងឃី៖**

ជម្រាបប្រសាសន៍លោកប្រធាន! គឺថាពាក់ព័ន្ធនឹងការតាំងសំណួរ ទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី គឺមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបីជាអ្នកចាប់ផ្ដើមមុន ហើយការចាប់សំណួរហ្នឹង នឹងសួរដោយសហមេធាវីអន្តរជាតិជាដំបូង ហើយបន្ទាប់មក គឺសហមេធាវីជាតិ ហើយនិងសល់ម៉ោង គឺយើង

ទុកឲ្យសហមេធាវីផ្សេង នៅក្នុងក្រុមផ្សេងៗទៀត ។ សូមអរគុណ ។

**សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង៖**

អរុណសួស្តីលោក លោកស្រីចៅក្រម និងអរុណសួស្តីលោក គោគ ខន ។ ខ្ញុំចង់សួរសំណួរទាំងនេះទៅលោក ។

**ស៖** ជាបឋម ថាតើលោកមានអាយុប៉ុន្មានដែរ នៅពេលដែលលោកចូលរួមជាមួយនិងខ្មែរក្រហម?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! កាលពីខ្ញុំចូលរួមលើកទីមួយ មុនដំបូងបង្អស់គឺនៅឆ្នាំ៧១ គឺអាយុតែ១៥ឆ្នាំទេ ។ រហូតមកដល់ឆ្នាំ៧៥ ពេលដែលគេចាប់ខ្លួនខ្ញុំ ខ្ញុំមានអាយុ២១ ឬ២២ឆ្នាំ ។

**ស៖** តើលោកបានចូលរួមនៅក្នុងសមរភូមិណាមួយដែរឬទេ? ប្រសិនបើចូលរួមមែននោះ តើលោកចូលរួមនៅសមរភូមិណាដែរ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! គឺនៅសម័យនោះ គឺចាប់ពីចូលបដិវត្តន៍នៅឆ្នាំ៧១ រហូតមកគឺខ្ញុំឈរជើងនៅសមរភូមិខេត្តកំពង់ធំ គឺនៅសម័យប្រតិបត្តិការចេនឡាទី២ រហូតមកនៅកំពង់ចាម នៅសមរភូមិកំពង់ចាម ហើយនិងបន្តបន្ទាប់មកទៀត គឺនៅសមរភូមិច្រើន ដូចជា ព្រែកក្តាម ព្រែកឆ្នោ និងសមរភូមិ ភ្នំព្រៃគ្រី ខេត្តកំពង់ឆ្នាំង ជាដើម ។

**ស៖** តើលោកបានចូលរួមនៅក្នុងការរំដោះយកភ្នំពេញដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! នៅទីក្រុងភ្នំពេញ គឺនៅឆ្នាំ១៩៧៥ ខ្ញុំក៏បានចូលរួមរំដោះដែរ ។

**ស៖** នៅថ្ងៃរំដោះនោះ តើលោកមានសេចក្តីរីករាយ និងសប្បាយចិត្តដែរឬទេ?

**ឆ៖** សូមជម្រាបលោកមេធាវី! គឺនៅថ្ងៃរំដោះនោះ គឺជាមុនដំបូង គឺមានចិត្តសប្បាយរីករាយដែរ ក៏ប៉ុន្តែដល់រំដោះបានហើយ គឺឃើញថា ការជម្លៀសបងប្អូនចេញពីទីក្រុងដោយបង្ខិតបង្ខំ និងការបាញ់រះសម្លាប់ដោយកងទ័ពខ្មែរក្រហមមួយចំនួន ក៏ឃើញថា ការវាប្រែប្រួលលក្ខណៈមិនពេញចិត្តរបស់ខ្ញុំ ក៏មានការរអាក់រអួលដែរក្នុងអារម្មណ៍ពេលនោះ ។

**ស៖** តើគេប្រាប់លោកដែរឬទេ ថាគេនឹងជម្លៀសប្រជាជនចេញពីភ្នំពេញ? ហើយគេផ្តល់ហេតុផលយ៉ាងម៉េចដល់លោក ហើយការជម្លៀសនោះវាមានរយៈពេលប៉ុន្មានដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍! ពីពេលនោះតាមបទបញ្ជារបស់ថ្នាក់លើ គឺត្រូវតែបង្ខំបងប្អូនទាំងអស់នៅទីក្រុងភ្នំពេញ គឺចេញឲ្យផុតក្នុងរយៈពេលម្ភៃបួនម៉ោង តាមការបញ្ជា គឺមិនឲ្យយកទ្រព្យសម្បត្តិទៅទេ គឺទៅតែខ្លួនក្នុងមួយរយៈពេលខ្លីនឹងវិលត្រឡប់មកវិញ ។ គេថាបើមិនចេញខ្លាចលោយន្តហោះអាមេរិកាំងមកទម្លាក់គ្រាប់បែកបណ្ដាលឲ្យមានការគ្រោះថ្នាក់ ។ នេះសូមជម្រាប ។

**ស៖** បន្ទាប់មកលោកបានរៀបការ ខ្ញុំចង់និយាយចំណុចនេះ ជាដំបូង តើលោកមានបំណងចង់រៀបការដែរឬទេ?

**ឆ៖** បាទ, សូមជម្រាបត្រង់នេះ ក៏ឃើញថា ការរៀបការ ។ ជាដំបូងខ្ញុំក៏មិនដែលស្គាល់ នារីនោះជាអ្នកណាទេ ព្រោះថាខ្ញុំមិនពេញចិត្ត ក៏ប៉ុន្តែការរៀបការដោយអង្គការរៀបឲ្យហើយ ក៏យកទៅ ប៉ុន្តែការពេញចិត្ត គឺគ្មានទេដោយការគោរពវិន័យ ហើយក៏យកទៅ ។

[០៩:៤៥:00]

**ស៖** នៅពេលដែលលោករៀបការ តើលោកពេញចិត្តនិងសប្បាយទេនៅពេលរៀបការនោះ?

**ឆ៖** ត្រង់ដែលខ្ញុំ ធម្មតារៀបការកាលពីដើមនិយាយបន្តិចចុះ បើថានៅក្មេង ដូច្នេះការរៀបការមុនដំបូង គឺមានលក្ខណៈមិនពេញចិត្តចំពោះគ្នានិងគ្នាទេ ។ ក៏ប៉ុន្តែ បានជាប្ដីប្រពន្ធហើយ ធម្មតាមនុស្សវាតែងតែវាមនោសញ្ចេតនា ។

**ស៖** នៅពេលដែលលោកមើលទៅលើប្រពន្ធរបស់លោកនោះ តាមរកប្រពន្ធរបស់លោកនោះ លោកចង់រកគាត់ ប៉ុន្តែលោកមិនអាចរកគាត់ឃើញទេ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ការតាមរក គឺទៅអង្គភាពដែលគេចាប់ខ្លួនបាត់ទៅហើយ ខ្ញុំក៏អាចរកឃើញទេ ក៏ប៉ុន្តែគេមិនដឹងថា ពេលចាប់ខ្លួននោះគេចាប់បញ្ជូនទៅទីកន្លែងណានោះទេ ។

**ស៖** នៅពេលនេះខ្ញុំនឹងសួរសំណួរទៅកាន់លោក អំពីស្ថានភាពមួយដែលលោកលំបាកនៅពេលដែលលោកត្រូវបានគេសួរចម្លើយ ។ ថាតើសំណួរណាដែលអ្នកសួរនោះ គេចាប់អារម្មណ៍យ៉ាងច្រើនហើយសួរទៅលើលោក? ថាតើគេសួរលោកអំពីសកម្មភាពរបស់ខ្មែរក្រហមចំពោះលោក ឬក៏សកម្មភាពខ្មែរក្រហមដែលលោកបានចូលរួម ឬក៏គេសួរលោកអំពីមេរបស់លោក? តើហេតុអ្វីបានគេសួរសំណួរទាំងអស់នោះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! ពេលនោះ គឺការសួរចម្លើយវាមានលក្ខណៈពីរយ៉ាង ។ លើកទីមួយ គឺមានលក្ខណៈពីរយ៉ាង មុនដំបូងគេសួររបៀបត្រជាក់ឲ្យខ្ញុំឆ្លើយ គេអត់មានវ៉ៃទេ មិត្តឯងឆ្លើយ

ត្រង់មក គេនឹងដោះលែងវិញ ។ តើអ្នកណាជាអ្នកបង្គាប់បញ្ជាមិត្តឯង នៅក្នុងជួររបស់មិត្តឯងជា *សេអ៊ីអា* ឬ *កាហ្សេបេ* ភ្នាក់ងារយួន? គេបានសួរតែចំណុចនេះគឺត្រជាក់ ។ ពេលនោះខ្ញុំក៏មិនដឹងថាអ្នកណាទេ ព្រោះថាខ្ញុំវាមិនដឹងថាខ្ញុំ *សេអ៊ីអា* ដោយសារអ្នកណា *កាហ្សេបេ* នោះក៏មិនដឹងគេបញ្ចូលដោយសារអ្នកណា រួចភ្នាក់ងារយួនក៏មិនដោយសារអ្នកណាដែរ ព្រោះខ្ញុំរវលទៅស្វាយរៀងបកមកវិញគេចាប់ខ្លួន ខ្ញុំមិនដឹងដែរ មិនដឹងជាភ្នាក់ងារយួន*, សេអ៊ីអា, កាហ្សេបេ* នោះពីពេលណាមកទេ ។

**ស៖** ថាតើអ្នកសួរចម្លើយនោះ គេចាប់អារម្មណ៍សួរអំពីប្រធាន ឬមេរបស់លោកដែរឬទេ? ប្រសិនបើគេចាប់អារម្មណ៍ទៅលើមេរបស់លោកនោះ ហេតុអ្វីបានជាគេចង់ដឹងទៅលើចំណុចនេះ?

[០៩:៤៨:៣២]

**ឆ៖** បាទ, ជម្រាបប្រសាសន៍! គេសួរបើតាមខ្ញុំយល់ គេអាចថា ព្រោះខ្ញុំធ្លាប់បានរស់នៅជាមួយ អឿន ក៏ដូចជាធ្លាប់ស្គាល់ កុយ ធួន ។ បានគេចាប់អារម្មណ៍ថា ខ្ញុំជាប់និន្នាការនយោបាយ ឬក៏ជាប់ពាក់ព័ន្ធផ្សេងៗជាមួយ អឿន នៅក្នុងកងពល៣១០ ខ្ញុំបាទ ។

**ស៖** ក្រោយពីការសួរចម្លើយចុងក្រោយ ថាតើលោកត្រូវបានគេនាំទៅបន្ទប់មួយដាច់ដោយឡែក ឬក៏បន្ទប់រួម ឬក៏បន្ទាប់ពីលោកត្រូវបានទុកនៅក្នុងបន្ទប់រួមនោះរហូត រហូតដល់ពេលគេយកលោកទៅសម្លាប់ចោល ឬក៏លោកត្រូវបានគេឃុំនៅបន្ទប់រួមដែរ មុនពេលយកទៅសម្លាប់ចោលនោះ?

**ឆ៖** បាទ,ជម្រាបប្រសាសន៍លោកមេធាវី! នៅពេលគេសួរចម្លើយលើកទីមួយរួច គេអត់បានយកទៅដាក់បន្ទប់រួមដដែលនោះទេ គឺយកទៅដាក់បន្ទប់ដោយឡែកតែម្នាក់ឯង គឺមានបន្ទប់កឡើងពីឥដ្ឋជញ្ជាំងជុំវិញទៅ មានតែទ្វារចូលដែលមានទទឹងមួយម៉ែត្រ មួយម៉ែត្រមួយតឹក ឬក៏ពីរតឹក បណ្ដោយពីរម៉ែត្របីតឹក បួនតឹក តែប៉ុណ្ណោះឯងទេ ។

**ស៖** ក្រោយពីការសួរចម្លើយលើកទីពីរ តើគេទុកលោកនៅក្នុងបន្ទប់ដាច់តែឯងរង់ចាំការសម្លាប់ចោល ឬក៏នៅពេលនោះគេបានដូរលោកទៅដាក់ក្នុងបន្ទប់រួមវិញ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ជាលើកទីពីរ ក៏គេធ្វើតែរបៀបដដែលនោះ គឺគេយកទៅដាក់ក្នុងបន្ទប់តែម្នាក់ឯងរហូត ។

**ស៖** ដូច្នេះ លោកនៅក្នុងបន្ទប់តែឯងនេះរហូត ដល់ពេលគេយកលោកទៅសម្លាប់ចោល? តើមែនដែរឬទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! មែន ។

**ស៖** នៅចុងក្រោយទាក់ទងទៅនឹងរឿងរ៉ាវចុងក្រោយរបស់លោក នៅពេលដែលលោកតោងក្តារនៅក្នុងទន្លេ ហើយលោកមាននិយាយថាលោកទន់ខ្សោយណាស់ ហើយលោកនិយាយថា ទាហានជួយលោក ប្រសិនបើមានទាហាននោះជួយលោកមែន តើទាហាននោះជាទាហានណាដែរ? ហើយពួកគេជានរណា?

**ឆ៖** ជម្រាបប្រសាសន៍! នៅពេលដែលខ្ញុំតោងក្តារនៅកៀនទន្លេហ្នឹង ក៏វាកៀនច្រាំងដែរ ឃើញថាពេលនោះ ខ្ញុំឃើញបាឡាកាណូតចុះ បើកមកមានគ្នាដប់នាក់ គេបើកតម្រង់មកខ្ញុំ ស្មានតែខ្ញុំស្លាប់ទេ ពេលនោះក៏ខ្ញុំដើរទៅលើដៃឡើង គេឃើញគេថារស់គេចូលមកជិត ក៏លើកខ្ញុំដាក់ទៅ គឺកងទ័ពខ្មែរនោះប្រាំនាក់ វៀតណាមនោះប្រាំនាក់ គឺកងទ័ពរំដោះរណសិរ្សយើងរំដោះជាតិកាលនុ៎ង ។

[០៩:៥២:២០]

**ស៖** នៅពេលនេះ យើងនិយាយត្រឡប់ទៅពេលដែលគេចាប់ខ្លួនលោកវិញ ។ នៅក្នុងពាក្យសុំរបស់លោក លោកបាននិយាយថាសមមិត្ត អឿន ហើយលោក ជឿ ទ្រី ហើយនិងប្រពន្ធគាត់ និងកូនគាត់បីនាក់ ។ ហើយសមមិត្ត ទ្រី គឺក្នុងកងពល៣០៤ ហើយតើគេចាប់ខ្លួនគាត់នោះនៅពេលជាមួយនឹងលោក ឬក៏មុនពេលចាប់ខ្លួនលោក ដោយសារតែលោកនិយាយអំពីចំណុចនេះ នៅពេលដែលលោកនៅទួលស្លែងផងដែរ ថាតើហេតុអីបានជាលោកបានដឹងអំពីករណីលោកហ្នឹង?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! សំណួរនេះ សួរម្តងទៀតទើបបានខ្ញុំយល់ អត់សួរច្បាស់ ។

**ស៖** ខ្ញុំគិតថា សំណួរវាមានលក្ខណៈពុំលំបាក ដូច្នេះ ខ្ញុំសូមបំបែកវា ទីមួយគឺ សមមិត្ត អឿន ដែលលោកធ្វើការជាមួយ ហើយនិងសមមិត្ត ទ្រី តើអ្នកទាំងអស់នោះត្រូវបានគេចាប់ខ្លួនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! សមមិត្ត អឿន ដែលជាប្រធានកងពល៣១០ ពីមុន ទុយទៅទៀតនោះគឺ ចាប់ខ្លួនអស់ហើយ ។ ឯមិត្ត ទ្រី មិនមែនមិត្តទ្រី ទេគឺឈ្មោះ រឿង ទេ ដែលទទួលបន្ទុកក្រោម អឿន ហើយនិងឈ្មោះ ខ្ញុំមិនចាំឈ្មោះបុគ្គលិកទទួលខាងផ្នែកភស្តុភារនោះទេ ប៉ុន្តែបើខ្ញុំចាំបានគឺមានតែ បងអឿន ដែលក្តាប់កងពល៣១០ ហើយនិងបង រឿង ដែលទទួលអនុប្រធាន ទទួលខាងផ្នែកយោធា ហើយមួយទៀតខាងផ្នែកពស្តុភារ ខ្ញុំក៏ដូចជាភ្លេចឈ្មោះហើយ ព្រោះថាយូរដែរ ។ គេបានចាប់ខ្លួនទាំងបីនេះឯងបាទ ។

**ស៖** ថាហេតុអ្វីបានលោកដឹងថា អ្នកទាំងអស់នោះត្រូវបានឃុំខ្លួន និងធ្វើទារុណកម្មនៅទួលស្លែង? ហេតុអ្វីបានជាលោកដឹងថាអ្នកទាំងអស់នោះស្លាប់?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! គឺនៅពេលចាប់ខ្លួន អឿន នៅក្នុងកងពល៣១០ បានជាខ្ញុំដឹងគឺថាបានប្រមូលកងពិការ “ក៤” ទាំងអស់មកប្រជុំនៅវត្តភ្នំ ។ ពេលនោះគឺមានការថតខ្សែអាត់ដោយសំឡេង អឿន ផ្ទាល់ចាក់ឲ្យបងប្អូន និងយុទ្ធជននៅកងពិការ និងវរៈដទៃទៀតស្តាប់ ។ ឯចម្លើយសារភាពរបស់ បងអឿន ពេលនោះ ក៏ឃើញថា គាត់ឆ្លើយដោយមានការលំបាក រអាក់រអួលខ្លះដែរ ក៏ប៉ុន្តែចម្លើយរបស់គាត់ គឺពិតប្រាកដ គេចាក់ផ្សាយឲ្យបងប្អូនយុទ្ធជនកម្មាភិបាលទាំងអស់នៅក្នុងកងពល៣១០ នៅហ្នឹងវត្តភ្នំ គេហៅថាកន្លែងនោះគឺជាវត្តភ្នំ គឺរោងកុនចាស់ មិនដឹងជាកុនអ្វីទេ ព្រោះថានៅទីនោះ គឺខ្ញុំបានស្តាប់មែនព្រោះថា អាចសន្និដ្ឋានបានថា បងអឿន គាត់គេចាប់ខ្លួននៅពេលនោះ ឬក៏មិនដឹងជានៅស-២១ ឬពេលណានោះទេ ព្រោះខ្ញុំមិនបានស្គាល់ទេ ពេលនោះស-២១ មិនដឹងជាយ៉ាងម៉េចទេ ព្រោះតាមការសន្និដ្ឋាន គឺអាចស្លាប់នៅពេលនោះមែន ។

[០៩:៥៦:០៦]

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណច្រើនលោក ។ នៅពេលនេះ ខ្ញុំសូមផ្តល់ការសួរនេះទៅដល់ខាងសហសេវិកកម្ពុជាវិញ ។ សូមអរគុណ ។

**សួរដោយលោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល ។

**ស៖** ខ្ញុំបាទមានសំណួរជាដំបូងសួរទៅកាន់លោកអ៊ំ ភោគ ខន ។ សួរពាក់ព័ន្ធទីមួយ លោកអ៊ំបានរៀបរាប់ អំពីការចូលធ្វើខ្មែរក្រហមរបស់លោកអ៊ំ តើលោកអ៊ំអាចបញ្ជាក់បានទេ តើលោកអ៊ំចូលតាមរយៈអ្នកណា? ហើយចូលទៅតាមដោយវិធីណា? ដោយមូលហេតុអ្វី?

**ឆ៖** សូមបញ្ជាក់លោកមេធាវី ។ ចាប់និយាយពីមុនដំបូង ឬក៏និយាយពី៧៥?

**ស៖** បាទ គឺពីដំបូងដែលលោកអ៊ំ ចូលជាបក្ខជន ឬក៏ចូលនៅក្នុងចលនាតស៊ូហ្នឹងពីដំបូង ។

**ឆ៖** បាទ,ជម្រាបប្រសាសន៍! គឺការចូលបដិវត្តន៍ពីសម័យនោះ គឺដោយការចូលរួមការដើរឃោសនារបស់អង្គការខ្មែរក្រហមដែលបានដើរឃោសនានៅតាមភូមិ ។ ខ្ញុំចូលនៅឆ្នាំ៧១ គេលើកឡើងពីការរំដោះសម្តេចព្រះនរោត្តម សីហនុ គឺចូលរួមរំដោះជាតិ ធ្វើជាកងទ័ព លះបង់សាច់ញាតិទាំងអស់

ក៏ចូលរួមទៅ ។ ពេលនោះខ្ញុំចូលតាមរយៈនៅតាមឃុំ ពីដើមចូលឃុំទេ រហូតមកបានគេបញ្ជូនមកលើៗមក មកដល់ខ្ញុំបានមកហាត់កងទ័ព នៅព្រៃប្រោះ ឃុំព្រៃព្រាល យើងកំពង់ធំនេះ ។ ទើបបានគេបញ្ជូនខ្ញុំមកនៅកំពង់ធំ កំពង់ថ្ម តាំងក្រសាំង ធ្វើប្រតិបត្តិការវ៉ៃកងទ័ព លន់ នល់ នៅសម័យចេនឡាទីពីរ ជាបន្តបន្ទាប់រហូតមកដល់រំដោះភ្នំពេញ ។

**ស៖** សូមអរគុណ ។ លោកអ៊ំមានប្រសាសន៍ថា នៅក្នុងទាំងការធ្វើសក្ខីកម្មរបស់លោកអ៊ំមានពាក់ព័ន្ធទៅនឹងលោក កុយ ធួន តើលោកអ៊ំមានទំនាក់ទំនងយ៉ាងដូចម្ដេចជាមួយនឹងលោក កុយ ធួន បានជាលោកអ៊ំលើកអំពីឈ្មោះគាត់នៅក្នុងពាក្យបណ្ដឹង ហើយនិងការធ្វើសក្ខីកម្មក្នុងរយៈពេលកន្លងមកនេះ?

[០៩:៥៨:៥៧]

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍លោកមេធាវី! បង កុយ ធួន កាលសង្គ្រាមឆ្នាំ៧៣ ខ្ញុំបានរស់នៅជាមួយគាត់ នៅមន្ទីរហ-៨៣ មន្ទីរ ត-១៥ នៅគីឡូ១០ គីឡូ១៣ យើងចំការកៅស៊ូ ស្រុកស្ទឹងត្រង់ កំពង់ខ្ជួយ ខាងលើស្រែវាលស្ដី ចំការលើយើង ។ ខ្ញុំបានស្គាល់ រួចហើយរស់នៅជាមួយគាត់ ក្នុងមួយរយៈឆ្នាំ៧៣ និង៧៤ ទើបបានដកខ្ញុំមកនៅអង្គភាពកងទ័ពវិញនៅឆ្នាំ៧៤ ។ ទើបខ្ញុំស្គាល់គាត់យូរដែរនៅមន្ទីរហ-៨៣ និងមន្ទីរត-១៥ ព្រោះគាត់ជាប្រធានភូមិភាគ៣០៤។ កាលពីដើមគេហៅ បងធុចៗទេ។ ដល់ពេលរំដោះហើយនៅ ឆ្នាំ១៩៧៥ ទើបគេហៅ កុយ ធួន ។

**ស៖** សូមអរគុណ ។ ចុះទំនាក់ទំនងក្រោយពីថ្ងៃរំដោះមករវាងលោកអ៊ំ និងលោក កុយ ធួន ហ្នឹងបានបញ្ចប់ ឬក៏នៅមានទៀតទេ ឬក៏? ហើយមួយទៀតគឺភូមិភាគ៣០៤ហ្នឹងគឺជាអ្វី? ហើយ ហ-៨៣ មន្ទីរ ហ-៨៣ និងត-១៥ ជាអ្វី? តើលោកអ៊ំអាចបញ្ជាក់បានទេ?

**ឆ៖** បាទ,ជម្រាបប្រសាសន៍! គឺមន្ទីរហ-៨៣ គឺចំណុះឲ្យមន្ទីរភូមិភាគគឺសម្រាប់ធ្វើសន្និបាតធំៗ ដូចជាថ្នាក់តំបន់ ថ្នាក់ស្រុកក៏តែងហៅទៅប្រជុំនៅមន្ទីរហ-៨៣ ។ គឺដោយបង កុយ ធួន គាត់ជាប្រធានភូមិភាគ៣០៤ គឺភូមិភាគឧត្តរ ។ អាហ្នឹងគេសន្និបាតនៅមន្ទីរនោះ គឺជាមន្ទីរប្រចាំការ គេហៅថាមន្ទីរភូមិភាគ ។ ហើយមន្ទីរត-១៥ នោះនៅភូមិខ្ជួយ ក៏ជាមន្ទីរភូមិភាគដែរ គឺកន្លែងនោះ ត-១៥ បង្កើតក្រោយហ-៨៣ ។ គឺកកើតជាកន្លែងរបស់គាត់ដែរ ។ គឺគាត់សម្រាប់ប្រជុំកម្មាភិបាលធំៗជាថ្នាក់តំបន់ ថ្នាក់ស្រុក ចូលទៅធ្វើសន្និបាតនៅទីនោះ ។

**ប្រធានអង្គជំនុំ៖**

មេធាវីតម្រង់សំណួរឲ្យចូលក្នុងអង្គហេតុ ។ សំណួរហ្នឹងដូចឆ្ងាយពីអង្គហេតុឆ្ងាយណាស់ ។ អង្គហេតុកើតឡើងនៅក្នុងអំឡុងពេលឆ្នាំ១៩៧៨ ហើយប្រវត្តិនោះគឺតាំងពីឆ្នាំ១៩៧០មក ពេលវេលាក៏ដូចជាមិនច្រើនទេ ហើយការសួរឆ្ងាយក្រៅអង្គហេតុនាំឲ្យខាតពេលវេលាឥតប្រយោជន៍ ។

**សួរដោយលោក គីម ម៉េងឃី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនឹងកែតម្រូវសំណួររបស់ខ្ញុំឲ្យចូលកៀកទៅនឹងអង្គហេតុដែលពាក់ព័ន្ធទៅនឹងលោកអ៊ំ ភោគ ខន ។

**ស៖** លោកអ៊ំ ភោគ ខន លោកអ៊ំបានជម្រាបថា លោកអ៊ំ មានឈ្មោះហៅក្រៅមួយទៀត គឺ ភោគ សារុន ហើយលោកអ៊ំជាកម្មកររទេះភ្លើង តើលោកអ៊ំអះអាងអ៊ីចឹងមែនទេ?

**ឆ៖** បាទ, គឺនៅសម័យឆ្នាំ១៩៧៥ ខ្ញុំបានប្រែឈ្មោះ កាលពីសម័យសង្គ្រាមមុន ស៊ុំបន្តិចទៅសម័យសង្គ្រាមខ្ញុំដាក់ឈ្មោះ ភោគ សាខុន ដល់ពេល ប្រែពី ភោគ ខន ដាក់ ភោគ សាខុន ប៉ុន្តែដល់ពេលរំដោះហើយខ្ញុំក៏ប្រែពី ភោគ សាខុន មកដាក់ ភោគ សារុន វិញ ។ ខ្ញុំបានទៅនៅនុ៎ង ក្រសួងកម្មករ ក្រោយ៧៨ហើយនេះទេ គឺគេឲ្យទៅទទួលជាបណ្តោះអាសន្ន ជាកម្មករនៅវ៉ារទេះភ្លើងភ្នំពេញយើងនេះបានចំនួនប្រហែលជាដប់ប្រាំថ្ងៃទេ ត្រូវគេចាប់ខ្លួន ។

[១០:០៣:២៥]

**ស៖** ដូច្នេះឈ្មោះលោកអ៊ំ មានឈ្មោះ ភោគ សាខុន ចុះឈ្មោះ ភោគ សារុន ហ្នឹងជាឈ្មោះនៅក្នុងសម័យនោះដែរឬទេ? ហើយឈ្មោះ ភោគ ខន?

**ឆ៖** បាទ, ជម្រាបប្រសាសន៍ ឈ្មោះ ភោគ ខន គឺឈ្មោះដើម ។ ពីបញ្ជីជាតិ គឺឈ្មោះ ភោគ ខន ។ ដល់ពេលខ្ញុំចូលបដិវត្តន៍មុនដំបូង ខ្ញុំដាក់ ភោគ សាខុន ដល់ពេលរំដោះហើយ នៅឆ្នាំ៧៥ ខ្ញុំប្រែពី ភោគ សាខុន មកដាក់ ភោគ សារុន ។ នេះឈ្មោះដែលធ្លាប់ហៅជាបន្តបន្ទាប់រហូតដល់គេចាប់ខ្លួន ។

**ស៖** ពាក់ព័ន្ធនឹងឯកសារមួយដែលក្រុមមេធាវីយើងខ្ញុំបានរកឃើញហើយប្រគល់ជូនលោកអ៊ំ មានឯកសារមួយដែលនិយាយអំពីឈ្មោះ ភោគ សាខុន ហើយឯកសារមួយទៀតសរសេរជាអក្សរដៃយើងមើលមិនច្បាស់ទេ តែយើងអាចកត់សម្គាល់ថា ជាអក្សរ "រ" ប្រហាក់ប្រហែលនឹងអក្សរ "រ" ច្រើនជាង អក្សរ "ខ" ។ អ៊ីចឹង ភោគ សារុន ។ តើឯកសារនេះលោកអ៊ំអាចបញ្ជាក់បានទេថា វាមានទាក់ ទងនឹងឈ្មោះលោកអ៊ំដែរទេ ឯកសារដែលពួកយើងខ្ញុំបានប្រគល់ឲ្យហ្នឹង?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបត្រង់នេះគឺថា ឯកសារនេះដែលមានដាក់ឈ្មោះ ភោគ សារុន ពីលើរទេះភ្លើងភ្នំពេញ ។ ចម្លើយរបស់ សុខ ណាន់ តម្បាញ ត-៤ ឃើញថា សុខ ណាន់ ខ្ញុំក៏មិនស្ងវស្គាល់គេច្បាស់ទេ ព្រោះខ្ញុំអត់ទៅនៅ ព្រោះ សុខ ណាន់ ជាអ្នកខាងតម្បាញនោះទេ ។ ឯកន្លែងរ៉ាវទេះភ្លើងនេះ ខ្ញុំអាចសន្និដ្ឋានថា ឈ្មោះ ភោគ សារុន នេះគឺជាឈ្មោះខ្ញុំក៏ប៉ុន្តែ ដល់ជាចម្លើយ ចម្លើយរបស់ សុខ ណាន់ ទៅវិញ។ នេះសូមជម្រាបប៉ុណ្ណោះ ។

**ស៖** សូមអរគុណ។ មួយទៀតពាក់ព័ន្ធនឹងប្រវត្តិរូបរបស់បងប្អូនជីដូនមួយរបស់លោកពូឈឿង ភាំ (ទិន ណេត) តើប្រវត្តិរូបហ្នឹងត្រឹមត្រូវតាមអ្វីដែលលោកអ៊ំបានស្គាល់គាត់ថាជាបងប្អូនជីដូនមួយដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! គឺឈ្មោះ ឈឿង ភាំ ដែលប្រែមកពីសម័យបដិវត្តន៍ហៅថា ទិន ណេត នោះគឺជាឈ្មោះរបស់គាត់ពិតប្រាកដ គឺជាបងប្រុសជីដូនមួយរបស់ខ្ញុំពិតមែន ។

[១០:០៦:២៤]

**ស៖** សូមអរគុណ ។ អ៊ីចឹង ខ្ញុំវិលទៅក្រោយបន្តិចពាក់ព័ន្ធទៅនឹងការជាប់ឃុំឃាំង ការសួរចម្លើយនិងការធ្វើទារុណកម្ម ។ លោកអ៊ំបានរៀបរាប់ថា អ្នកសួរចម្លើយលោកអ៊ំតាមដែលលោកអ៊ំបានឮឈ្មោះ ហ៊ា និងឈ្មោះ សេង ។ ថាតើលោកអ៊ំអាចកត់សម្គាល់បានទេ ថាតើមានឈ្មោះ ហ៊ា និង សេង ហ្នឹងមានភិនភាគយ៉ាងម៉េច? ឬក៏លោកអ៊ំអាចសម្គាល់អ្នកសួរចម្លើយនោះបានដែរឬទេ?

**ឆ៖** សូមជម្រាបលោកមេធាវី! នៅពេលនោះឃើញថា ការចងជើង និងចងដៃដេកផ្កាប់មុខ ។ ហេតុដូច្នេះក្បាលខ្ញុំគឺមិនអាចងើបមើលរួចទេ ព្រោះថាដៃជាប់ចំណងទៅក្រោយទៅហើយ ។ ងើបបានដែរ ងើបបានអើតតែក្បាលបន្តិច ហើយមើលឃើញក៏ឃើញត្រឹម បើថាអើតយើងអើតឃើញត្រឹមជង្គង់ទៅក្រោម គឺមិនអាចមើលឃើញមុខថា សេង នោះមុខយ៉ាងម៉េច ហ៊ា នោះមុខយ៉ាងម៉េចទេ? ប៉ុន្តែឮតែការហៅ ដូចថា ហ៊ា គេហៅសេងទៅ សេង គេហៅ ហ៊ា ទៅ ។ អ្នកឯងផ្លាស់ប្តូរគ្នា អើ! វ៉ៃមួយសន្ទុះទៅខ្ញុំឮសួរសំរឹបជើងទេ ក៏ប៉ុន្តែ ហ៊ា ទេ គេប្រាប់ឮថា អូ! សេង, មិត្តសេង បងខាងកើតគាត់អញ្ជើញមកហើយ។ ខ្ញុំក៏មិនចាប់អារម្មណ៍ថា បងខាងកើតនោះជានរណាទេ ព្រោះមិនប៉ានឹងអើតមើលមុខគេផងអើតមើលក៏អើតមើលមិនឃើញមុខគេ។ ខ្ញុំអត់មានចាប់អារម្មណ៍ថា អ្នកទទួលខុសត្រូវនោះជាបងខាងកើតនោះ នោះអ្នកទទួលខុសត្រូវអីទេ ។ សូមជម្រាបប៉ុណ្ណោះ ។

**ស៖** ហេតុដូច្នេះបងខាងកើតក៏មិនបានឃើញភិនភាគច្បាស់លាស់ដែរ ។ អ៊ីចឹងមែនទេបាទ?

**ឆ៖** បាទ, ពិតជាអ៊ីចឹងមែន ។

**ស៖** លោកមានប្រសាសន៍ថា ក្រោយពីគេធ្វើទារុណកម្មលោក គេវ៉ៃ លោក តើលោកអាចពន្យល់បានទេ តើវិធីវ៉ៃហ្នឹងវាយ៉ាងម៉េច ហើយលោក លោកអត់អាចរើបាន? ឬក៏យ៉ាងម៉េចបានជាមិនអាចមើលឃើញឆ្វេងស្តាំ ឬក៏ឃើញភិនភាគទាំងស្រុង? ឬក៏យើងនៅ ស្ងៀមឲ្យគេវ៉ៃ? ឬក៏យើង បានន័យថា យើងមិនអាចកំរើកខ្លួនសោះនៅពេលដែលគេវ៉ៃ? ឬក៏យ៉ាងម៉េច? តើអាចពន្យល់បានទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! គឺការធ្វើទារុណកម្មវាតែងតែមានការឈឺផ្សាហើយក៏ប៉ុន្តែជើងជាប់ ដៃជាប់ទាំងអស់។ ហេតុដូច្នេះ ដេកផ្កាប់មុខហើយគឺមិនអាចផ្ងារវិញទេ ព្រោះដៃជាប់ចំណង ឯជើងក៏រើមិនរួច ។ ហេតុដូច្នេះ ការវ៉ៃតប់គឺមានការឈឺ ។ ខ្សែតីដូចដឹងស្រាប់ហើយ ខ្ញុំសូមជម្រាបថា ខ្សែល្អិតមែនពិត ប៉ុន្តែ ដាក់មួយឆ្វាច់ដល់ឆ្អឹងក្តៅ ឈឺណាស់ ហើយមានតែរើស្នា ហើយនិងខ្លួនប៉ុណ្ណោះ ។ ងាកតែខ្លួនម៉ុាងងាកៗតែប៉ុណ្ណោះឯងទេ ឯឈឺនៅតែឈឺ ប៉ុនដៃជើងមិនអាចរើទៅបានឯណារួចទេ ព្រោះជាប់ចំណងអស់ទៅហើយវាឈឺណាស់ ។ ខ្ញុំពេលនោះវាទ្រុឌទ្រោម ឈឺខ្លាំងមែនទែនទ្រាំសឹងមិនបាន ។

[១០:០៩:៥៣]

**ស៖** សូមអរគុណ។ ហើយបន្ទាប់មកទៀត ទាក់ទងទៅនឹងការនាំលោកទៅកាន់បន្ទប់រហូតមកដល់ពេលបច្ចុប្បន្ននេះ តើលោកអាចចំណាំបានទេ តើបន្ទប់ហ្នឹងគឺជាបន្ទប់សម្រាប់ឃុំមនុស្សនៅមន្ទីរស-២១ បច្ចុប្បន្ននេះដែរឬទេ? ឬក៏ជាបន្ទប់មួយផ្សេងដែលខុសពីបន្ទប់ដែលលោកធ្លាប់ត្រូវបានគេឃុំនៅក្នុងសម័យនោះ?

**ឆ៖** បាទ,ជម្រាបប្រសាសន៍! គឺថា ខ្ញុំដូចជាកាលដែលទៅវគ្គមួយជាមួយលោកគ្រូនុំង លោកមេធាវី ហើយនិងអង្គការ *ធីភីអូ* និងអង្គការផ្សេងទៀតដែលបានជូនទៅគឺថា ខ្ញុំក៏ចំណាំមិនបានដែរ ព្រោះថាពេលនោះឃើញថាការរស់នៅគឺមិនអាចដើរទៅណាបាន គឺមិនអាចចំណាំថាខ្លួនឯងនៅបន្ទប់ណា? ឬក៏អគារមួយណានោះទេ? ក៏ប៉ុន្តែកាលទៅមុនដំបូងខ្ញុំអាចថា នៅអគារជាន់ផ្ទាល់ដី ព្រោះមិនបានឡើងទៅលើទេ តាមសំរឹបដើរ និងសំរឹបការហៅទៅសួរចម្លើយ ។ ដល់ពេលខ្ញុំទៅពេលនោះក៏ខ្ញុំមិនអាចប៉ាន់ស្មានថាជាប់នៅទីណាដែរ ព្រោះចេញក៏យប់ ចូលក៏យប់ ហើយបិទភ្នែករហូតចូលទៅសួរចម្លើយគេបិទភ្នែក អាមកវិញក៏បិទភ្នែក ដល់កន្លែងទើបវាបើក។ ដល់បើកឡើងឃើញតែជញ្ជាំងជុំវិញ មិនដឹងជាអគារមួយណា ខ្ញុំក៏ចាំមិនសូវបានដែរ ។

**សៈ** សូមអរគុណនូវការបញ្ជាក់របស់លោកអ៊ំ ភោគ ខន ។ ជាបន្តខ្ញុំសូមស្នើសុំទៅលោកប្រធានមេត្តាអនុញ្ញាតឲ្យយើងខ្ញុំសួរទៅកាន់ជនជាប់ចោទពាក់ព័ន្ធទៅនឹងឯកសារដែលយើងខ្ញុំបានដាក់ជូនជាភាសាខ្មែរ។ គឺទីមួយ គឺឯកសារជាភាសាខ្មែរដែលមានលេខ ERN00282312 លេខសម្គាល់ E5/7/1.3 ហើយនិងបន្តទៀត គឺឯកសារជាភាសាខ្មែរដដែលគឺ 00282313 ហើយនិង 00282314 ជាភាសាខ្មែរ ។ សំណួរគឺសុំអនុញ្ញាតតាមរយៈលោកប្រធាន សួរថាតើលោក កាំង ហ្គេកអ៊ាវ អាចសម្គាល់បានទេ ថាតើឯកសារនេះគឺជាឯកសាររបស់មន្ទីរស-២១ ឬក៏ជាឯកសារដែលមិនចេញពីមន្ទីរស-២១? សូមមេត្តាលោកប្រធានអនុញ្ញាតឲ្យជនជាប់ចោទគាត់បញ្ជាក់លើចំណុចនេះបន្តិច ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ក្នុងចំណោមឯកសារទាំងបីនេះ ម្សិលមិញ គឺជនជាប់ចោទបានបញ្ជាក់ច្បាស់លាស់ទៅលើឯកសារដែលមានលេខ ERN00282314 រួចហើយ ។ អ៊ីចឹង មិនអនុញ្ញាតឲ្យដាក់បញ្ចាំងទៀតទេ ជារឿងដដែល ។ ដោយឡែកឯកសារពីរនេះ យើងនឹងអនុញ្ញាតឲ្យផ្នែកខាងសោតទស្សន៍ដាក់បង្ហាញនៅកញ្ចក់ទូរទស្សន៍តាមការស្នើសុំ ។

[១០:១៣:២៤]

ផ្នែកខាងសោតទស្សន៍សូមបង្ហាញនូវឯកសារចំនួនពីរ ។ គឺឯកសារទីមួយដែលមានលេខ ERN 00282312 និងឯកសារទីពីរ 00282313 ។

ជនជាប់ចោទអាចពិនិត្យមើលនូវឯកសារនេះ ហើយឆ្លើយតបនឹងសំណួររបស់មេធាវីតែម្តងដោយមិនចាំបាច់តាមរយៈប្រធានទេ ពីព្រោះភាគីមានសិទ្ធិគ្រាន់តែស្នើសុំអនុញ្ញាតសួរប៉ុណ្ណោះ ។ តើលោកអាចកត់សម្គាល់នូវឯកសារទីមួយនេះថាជាឯកសារដែលចេញពីមន្ទីរស-២១ ដែរឬទេ?

លោក កាំង ហ្គេកអ៊ាវ លោកអាចបង្ហាញបញ្ជាក់លើឯកសារនេះបានទេ? ឯកសារចំនួនពីរនេះ? ឥឡូវឯកសារទីមួយ 00282312 អំពីឈ្មោះ ភោគ សាខុន។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ឯកសារទីមួយមានលេខ 00282312 វាជាឯកសាររបស់មន្ទីរស-២១ ជាឯកសារសួរចម្លើយរវាងនៅចុងឆ្នាំ១៩៧៥និងដើមឆ្នាំ១៩៧៦ ជាពិសេសចុងឆ្នាំ១៩៧៥។ ចំណែក

ឯកសារទីពីរក៏ដូច្នេះ គឺឯកសារលេខ 00282313 ក៏ជាឯកសាររបស់មន្ទីរស-២១ ដែរ ។ សូមបញ្ជាក់ជូនតែប៉ុណ្ណេះ សូមគោរព ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍បង្វិលទៅស្ថានភាពដើម រូបភាពដើម ធម្មតាឡើងវិញ ។

ជាកិច្ចបន្តតើមានមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត មានសំណួរអីសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? បើមានសូមអញ្ជើញ ។

**សួរដោយលោក គង់ ពិសី៖**

**ស៖** សូមអរគុណលោកប្រធាន! ជាបឋមខ្ញុំសូមគោរពលោកស្រីចៅក្រម ហើយនិងលោកចៅក្រមជាតិនិងអន្តរជាតិ ។ ខ្ញុំសូមអនុញ្ញាតសួរដើមបណ្តឹងរដ្ឋប្បវេណីដូចតទៅនេះ ។ សំណួររបស់ខ្ញុំទាក់ទងនឹងការដែលចូលមកមន្ទីរស-២១ ដំបូង ។ លោកបានបញ្ជាក់អង្គចៅក្រមហើយថា ចូលដល់មន្ទីរស-២១ ដំបូង រហូតដល់បីថ្ងៃបានគេយកលោកទៅសួរចម្លើយ ។ តើក្នុងរយៈពេលបីថ្ងៃហ្នឹង លោកមានបានអាហារទទួលទានទេ?

**ឆ៖** បាទ,ជម្រាបប្រសាសន៍លោកមេធាវី! យប់មុនដំបូងដែលខ្ញុំចូលទៅដល់គឺអត់ទេ ទាល់តែព្រឹកម៉ោងប្រហែលដប់មួយ ទើបបានបបរហូប ។ មុនដំបូងអត់ទេ ។

**ស៖** សូមអរគុណ ។ ទាក់ទងទៅនឹងការហូបទឹកអី អ៊ីចឹងថ្ងៃដំបូងហ្នឹងមានបានទទួលទានទឹកទេ បើសិនអត់អាហាអ៊ីចឹងហើយ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍! នៅពេលចូលមុនដំបូង បើទឹកបាន ប៉ុន្តែបានតែមួយកែវតូចតែប៉ុណ្ណោះទេ ។

**ស៖** សូមអរគុណ ខ្ញុំមិនសួរលោកលម្អិតពីបញ្ហាហ្នឹងទៀតទេ ដើម្បីកុំឲ្យខាតពេលវេលា ។ ខ្ញុំចង់សួរលោកទាក់ទងទៅនឹងការសួរចម្លើយចប់ ។ នៅពេលដែលសួរចម្លើយចប់ តើគេយកលោកទៅដាក់ក្នុងបន្ទប់តូចអ៊ីចឹងមែនទេ?

**ឆ៖** បាទ, ពិតជាអ៊ីចឹងមែន ។

**ស៖** នៅក្នុងបន្ទប់តូចនោះ គេឲ្យលោកសម្រាន្ត តើមានមុងកន្ទេលទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! ការចូលដល់បន្ទប់តូច គេស្រាយមុខចេញហើយ គេស្រាយចំណងដៃចេញ *(អ៎សុំទោស)* គេដាក់ខ្នោះជើង ច្រវាក់ជើងរួចហើយ ទើបគេស្រាយខ្នោះដៃចេញ

គេស្រាយមុខចេញ នៅពេលនោះមើលទៅគឺអត់មានកន្ទេលទេ ហើយព្រមទាំងមានតែប៊ីដុងទឹកមួយ និងកែសគ្រាប់មួយសម្រាប់នោម និងបត់ជើងធំតែប៉ុណ្ណោះទេ ។

[១០:១៩:០២]

**ស៖** ចុះមុងអីមានទេ?

**ឆ៖** បាទ, មុងអត់មានទេ ។

**ស៖** សូមអរគុណ សំណួរបន្តទៅទៀតទាក់ទងនឹងការបន្ទប់ដដែល គឺថាតើធុំក្លិនយ៉ាងម៉េចដែរបន្ទប់នោះ ហើយមានពន្លឺយ៉ាងម៉េចដែរ? ក្លិននិងពន្លឺក្នុងបន្ទប់នោះ?

**ប្រធានអង្គជំនុំ៖**

សំណួរនេះសួររួចហើយ សំណួរច្រំដែល ដើមបណ្ដឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយទេណា មេធាវីរកសំណួរថ្មី ។

**សួរដោយលោក គង់ ពិសី៖**

**ស៖** អ៊ីចឹង ខ្ញុំសុំបន្តសំណួរបន្តទៅទៀត ។ ទាក់ទងទៅនឹងតេអូ អ៊ីចឹងខ្ញុំសូមបញ្ជាក់ជូនលោកប្រធានឲ្យជ្រាបថា ទាក់ទងនឹងតេអូនេះក៏មានសួរហើយដែរ ប៉ុន្តែចំណុចសំខាន់ទាក់ទងទៅនឹងការឆ្លើយឆ្លងតេអូ រឿងដែលជម្លោះប្រដាប់អាវុធ ។ លោកគេបញ្ជូនឲ្យលោកទៅកាន់តេអូ ទៅកាន់តេអូៗហ្នឹងធ្វើអី?

**ឆ៖** បាទ,ជម្រាបប្រសាសន៍លោកមេធាវី! កាលនោះគឺតេអូនៅក្នុងកងពល៣១០ គឺសម្រាប់ទាក់ទងកងទ័ពចុះឡើង បើនិយាយពីឲ្យខ្លីវិញថា តេអូ យើងនិយាយថាទូរលេខ សម័យនោះប្រើទូរលេខឆ្ងាយ គេទាក់ទងភ្នំពេញទៅស្វាយរៀង ដើម្បីផ្ដល់ជំនួយផ្សេងៗ ឬក៏ផ្ដល់ជាព័ត៌មាន ។

**ស៖** លោកអាចលើកពីព័ត៌មានចំណុចសំខាន់តូចមួយជូនអង្គជំនុំជម្រះបានទេ? ទាក់ទងហ្នឹងទាក់ទងពីស្អី?

**ឆ៖** សូមជម្រាបលោកមេធាវី! ពេលនោះគឺជាកងទ័ព កាលណាតេអូ គឺសម្រាប់បញ្ជា ឬក៏នាំបញ្ជូនទ័ពពីភ្នំពេញទៅស្វាយរៀងចុះឡើងដើម្បីបន្តធ្វើការប្រយុទ្ធជាមួយកងទ័ពវៀតណាមពេលនោះ ។

**ប្រធានអង្គជំនុំ៖**

អស់ម៉ោងហើយលោកមេធាវី ។ អស់ពេលហើយមេធាវី ។

តទៅនេះសូមទុកវេទិកាដល់ជនជាប់ចោទដើម្បីធ្វើការកត់សម្គាល់នូវចម្លើយរបស់ដើមបណ្ដឹង

វដ្តប្បវេណីឈ្មោះ ភោគ ខន ។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ថា ទីមួយគឺធ្វើការកត់សម្គាល់ខ្លី ហើយទីពីរគឺធ្វើការកត់សម្គាល់បន្ថែម បានន័យថា ម្សិលមិញលោកបានធ្វើការកត់សម្គាល់មួយចំនួនហើយ អ្វីដែលធ្វើរួចហើយលោកមិនបាច់ធ្វើថែមទៀតទេ ។ បើមានសូមអញ្ជើញជនជាប់ចោទ ។

[១០:២២:២៨]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមគោរពអង្គជំនុំជម្រះសាលាដំបូង បញ្ជាក់ជូនគោលជំហររបស់ខ្ញុំដូចតទៅ៖ ទីមួយខ្ញុំទទួលស្គាល់ថា មិត្ត ឈឿង ភាំ ហៅ ណេត ពិតជាទៅចូលទៅស-២១ ហើយត្រូវបានកម្ទេចនៅទីនេះ ។ ភស្តុតាងគឺឯកសាររបស់ស-២១ បញ្ជាក់ច្បាស់លាស់ ។ ទីពីរករណីរបស់អ្នកស្រី ពិន លីន ហៅ លាប ហៅ ទុយ លាប ហើយនិងករណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលនៅមុខអង្គជំនុំជម្រះសាលាដំបូងយើងនេះ ខ្ញុំសូមមិនមានមតិទេ គឺសូមជូនបញ្ហានេះទៅអង្គជំនុំជម្រះលោកវិនិច្ឆ័យចុះ ។ ខ្ញុំជឿទាំងស្រុងលើសុភវិនិច្ឆ័យនៃអង្គជំនុំជម្រះសាលាដំបូងទាំងស្រុង ។ នេះបញ្ហាដែលខ្ញុំសូមរាយការណ៍ជូនអង្គជំនុំជម្រះ ។

តទៅនេះ ខ្ញុំសូមលោកប្រធានអនុញ្ញាតឲ្យមេធាវីខ្ញុំទាំងពីរ លោកសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ ខ្ញុំសូមបញ្ជាក់តែប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សូមប្រគល់វេទិកាទៅមេធាវីការពារក្តីដើម្បីមានឱកាសក្នុងការតាំងសំណួរសួរពាក់ព័ន្ធដល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភោគ ខន ។ ប្រសិនបើមានសូមអញ្ជើញមេធាវី ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណលោកប្រធាន និងសូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ ។ លោក ភោគ ខន ខ្ញុំសុំសួរលោកទីមួយ ពីម្សិលមិញលោកប្រធានបានសួរលោកថា “លោកឈ្មោះអី?” លោកបានឆ្លើយថា “ខ្ញុំបាទឈ្មោះ ភោគ ខន” “លោកមានឈ្មោះអីហៅក្រៅទៀតទេ?” លោកឆ្លើយថា “អត់មានទេ” ។ មកដល់ពេលនេះមេធាវីរបស់លោកបានសួរលោក លោកបានប្រាប់មេធាវីរបស់លោកថា “ក្រៅពីឈ្មោះ ភោគ ខន លោកប្រើឈ្មោះ ភោគ សាខុន” ហើយចេញពីណាមកទៀត មកដល់ក្រោយមកប្រើឈ្មោះ ភោគ សារុន ។ ទៅជាប្រើឈ្មោះផ្សេងទៅទៀត ពីវាក្រៅពីឈ្មោះ ភោគ ខន ។ អ៊ីចឹងខ្ញុំសុំសួរលោកថា ហេតុអីបានជាលោកឆ្លើយទៅនឹងលោកប្រធានថា លោកអត់មានឈ្មោះក្រៅ? នេះសូម

លោកបញ្ជាក់ជូនតុលាការ ។

[១០:២៥:១០]

**ឆ៖** ខ្ញុំសូមជម្រាបលោកមេធាវីការពារក្តី ខ្ញុំបានជម្រាបហើយថា ពេលដែលលោកចៅក្រមបានជម្រាបសួរខ្ញុំ ខ្ញុំមិនបានចាប់អារម្មណ៍ថាពេលនោះលោកសួរពីមុន៧៥ តើឈ្មោះអ្វីទេ? គាត់សួរតែត្រឹមឆ្នាំ៧៥ តើមានឈ្មោះអ្វី? ហេតុដូច្នេះ ខ្ញុំក៏ឆ្លើយដាក់ ដែលរំដោះហើយនេះទេ តើមានឈ្មោះអ្វី? ខ្ញុំបាទសុំទោស ដែលខ្ញុំបានមកនៅក្នុងភូមិស្រុកកំណើតវិញទេ ខ្ញុំឆ្លើយត្រឹមថាខ្ញុំឈ្មោះ ភោគ ខន នាមពិតប្រាកដគឺ ភោគ ខន បើសិនជាលោកសួរខ្ញុំពីសម័យ៧៥ ក៏ខ្ញុំអាចឆ្លើយប្រាប់ថា ពីសម័យនោះខ្ញុំបានប្រែឈ្មោះដាក់នេះដាក់នោះដែរ ប៉ុន្តែ ខ្ញុំមិនបានចាប់អារម្មណ៍លើសំណួរ ។ ហេតុដូច្នេះ ក៏ខ្ញុំឆ្លើយខ្លី ថាខ្ញុំឈ្មោះតែ ភោគ ខន នេះទេ ដែលរំដោះហើយនេះទេ ។ បាទជម្រាបប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ។ ការពិតលោកប្រធានសួរលោកអត់មានសួរថាពីឆ្នាំនេះទៅឆ្នាំនេះលោកប្រើឈ្មោះអីលោកអត់មានសួរទេ លោកគ្រាន់តែសួរថាលោកមាន លោកឈ្មោះអី? លោកឆ្លើយថាលោកឈ្មោះ ភោគ ខន ហើយលោកប្រធានសួរទៀតថា លោកមានប្រើឈ្មោះអីក្រៅពី ភោគ ខន ទេ? លោកថាអត់មានទេ ។ នែ៎ឃើញទេ លោកប្រធានអត់មានសួរឆ្នាំណាៗអត់មានសួរទេ ។

សំណួរទីពីរ លោកប្រធានសួរលោក លោកឆ្លើយថា "លោកហែលទឹកទន្លេមេគង្គហ្នឹង យកក្តារមកដាក់ទ្រាប់ដើមទ្រូងមកទល់ដល់មុខវាំង ។ អម្បាញ់មិញមេធាវីរបស់លោកសួរលោកៗថា លោកកំពុងតែហែលទឹក នែ៎មានកាណូតមួយ ក្នុងកាណូតនោះ មានទ័ពវៀតណាមប្រាំនាក់ ទ័ពកម្ពុជាប្រាំនាក់ ។ លោកលើកដៃទៅ គេក៏ស្រង់លើកលោកយកមកដាក់ក្នុងកាណូតទៅៗ ហើយបើលើកយកដាក់ទៅហើយ លោកម៉េចមកដល់មុខវាំង ហើយយកទៅបាត់ហើយ? សូមលោកបញ្ជាក់មើលវាយ៉ាងម៉េចបានវាខុសគ្នាអ៊ីចឹង?

[១០:២៧:២២]

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! ឃើញថាពេលនោះដែលខ្ញុំជម្រាបខាងដើមពីម្សិលមិញក៏បានជម្រាបដែរថា ខ្ញុំបានហែលទន្លេ គឺមិនបានហែលនឹងកណ្តាលទន្លេនោះទេ គឺនៅអែបច្រាំងកៀនៗរហូតមកដល់ឆ្ងាយដែរហើយ ក៏ខ្ញុំមិនចាំកន្លែងទេ ហើយពេលនោះក៏មានទ័ពវៀតណាមមែនឯងក៏វាមានចំនួនដប់នាក់ទេ ។ មួយកាណូតនោះមានវៀតណាមនិងខ្មែរ ។ ពេលនោះវាបើកនៅកណ្តាលទន្លេនោះទេ ខ្ញុំនៅកៀនណោះ ក៏មិនចាប់អារម្មណ៍ថាជាទ័ពអ្នកណាទេ ។ ក៏ប៉ុន្តែ ខ្ញុំបានលើកដៃទៅ គឺខ្ញុំ

វើសវ៉ាសៗទៅ ពុំមែនលើកដៃស៊ីញ៉ូឲ្យទ័ពនោះចូលទេ ក៏ប៉ុន្តែ ខ្ញុំលើកដៃក្នុងនាមថា គ្រាន់តែកាយៗឲ្យទៅមុខបន្តិចទៅ បានទ័ពនោះគេចូលមក លើកខ្ញុំដាក់ទៅ រហូតបរមកទៅឆ្ងាយដែរ ក៏ប៉ុន្តែស្នូរកាំភ្លើងនោះវាផ្ទុះច្រើនពេកក៏យកទៅផ្ញើនឹងគេទៅ ។

នេះសូមជម្រាបតែប៉ុណ្ណេះទេ តែមិនដឹងជាទីណាទេ ព្រោះថាទន្លេគឺទន្លេហើយ ប្អូនមុខ ក៏មិនបានចាប់អារម្មណ៍ថាប្អូនមុខ ឬក៏ទីណានោះដែរ ។ ប៉ុន្តែ អាចអើតទៅលើគឺឃើញថាច្រាំង ។ ច្រាំងខាងលើគឺមើលមិនឃើញ ដូច្នេះ ខ្ញុំនៅអែបកៀន មើលមិនឃើញទៅលើនោះថា ប្អូនមុខ ឬក៏វាំង ។ កន្លែងនោះតាមស្មានសព្វថ្ងៃគឺវាំង មុខវាំងនោះតែម្តង តាមមើលទៅ ។

**ស៖** សូមអរគុណ ។ សូមសួរសំណួរទីបី ។ ពេលគេយកលោកទៅសម្លាប់ លោកថាគេចងមុខដៃគេចង ជើងអត់ចងទេ ហើយគេវ៉ៃលោកគឺជាជនទីបី លើកទីបី ។ គេវ៉ៃមុនពីរនាក់ហើយ លើកទីបីគឺលោក ។ ហ៎! គេវ៉ៃផ្ទួងទៅ លោកឱនក្បាលគេចផុត តែត្រូវឆ្អឹងជំនី នែ៎លោកក៏សន្លប់បាត់ទៅ ។ ក្នុងរណ្តៅ លោកថាលោកសន្លប់ ប៉ុនតែលោកថា លោកមានដឹងថាគេវ៉ៃបីនាក់ទៀតបន្ថែមពីលើលោក ។ ខ្ញុំសួរថាបើលោកសន្លប់ ម៉េចក៏លោកដឹងថា គេវ៉ៃបន្ថែមពីលើលោក បើលោកសន្លប់បាត់ទៅហើយ? សូមលោកបញ្ជាក់មើល ម៉េចបានលោកដឹង?

**ឆ៖** បាទ, សូមជម្រាបត្រង់ណេះឲ្យច្បាស់បន្តិច ឃើញថាពេលដែលវ៉ៃហើយ គឺខ្ញុំសន្លប់ចូលទៅមែន ហើយផ្លាក់ទៅ គឺមានផ្កាប់មុខ គឺផ្កាប់មុខៗក៏វ៉ៃក្រោយទៅទៀតទៅ ខ្ញុំមិនបានដឹងថា គេវ៉ៃប៉ុន្មាននាក់ពីក្រោយទៅទៀតទេ ដូចខ្ញុំជម្រាបលោកមេធាវីហើយកាលពីម្សិលមិញ ខ្ញុំថា អត់ដឹងថា គេវ៉ៃពីរនាក់ បីនាក់ពីក្រោយទៀតទេ ។ ពេលខ្ញុំដឹងខ្លួនឡើងទើបបានខ្ញុំឃើញខ្មោចបីនាក់ នៅពីលើខ្ញុំទៀត ។ នេះសូមជម្រាបតែប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ប៉ុន្តែពីម្សិលមិញអត់បានថា ពេលដែលលោកដឹងខ្លួនឃើញបីនាក់ទេ ខ្ញុំឃើញខ្ញុំកត់មកថា ពេលដែលលោកសន្លប់ទៅហ្នឹង ដឹងថាគេវ៉ៃបីនាក់ពីលើលោកទៅទៀត ។ អ៊ីចេះបានខ្ញុំឆ្ងល់ហ្នឹង បើសន្លប់ហើយម៉េចក៏ដឹង ។

សំណួរទីប្រាំ តើលោកមានភស្តុតាងអីខ្លះសម្រាប់បង្ហាញតុលាការថា លោកនិងប្រពន្ធរបស់លោកពិតជាជាប់នៅស-២១ ពិតប្រាកដមែន? ទោះបីជាលោករួចខ្លួនពីស្លាប់ ដោយលោកបាន គឺថា ខំរមៀលចេញរណ្តៅក្តី ក៏លោកត្រូវមានបញ្ជីឈ្មោះហ្នឹងនៅក្នុងស-២១ ថាបានកម្ទេចរួចហើយដែរ ពីព្រោះគេយកទៅកម្ទេចហើយ ហើយគ្មានអ្នកណាដឹងថាលោករួចខ្លួនទេ ព្រោះគេវ៉ៃលោកហើយៗ ។ តើ

លោកខ្លួនលោកផ្ទាល់ ឃើញទេ តើខ្លួនលោកផ្ទាល់លោកថា លោកបានទៅរកនៅស-២១ រូបថតក៏គ្មាន ប្រវត្តិរូបក៏គ្មាន ។ ចំណែកឯ សួរចម្លើយពីរដង ចម្លើយក៏មិនឃើញមាន អត់មានឃើញទេ ហើយខ្ញុំខំបើកបញ្ជីឈ្មោះអ្នកទោស រកទាំងប្ដី ទាំងប្រពន្ធលោក ក៏អត់មានឃើញដែរ ។ អ៊ីចឹង តើលោកមានភស្តុតាងអីបញ្ជាក់ជូនតុលាការថា ពិតជាលោកបានចាប់មកស-២១ ពិតប្រាកដមែន? នេះសូមលោកបញ្ជាក់ ។

**លោក គីម ម៉េងឃី៖**

សូមអនុញ្ញាតលោកប្រធាន ខ្ញុំសូមកាត់ហើយសូមកាត់ចម្លើយរបស់លោកអ៊ំ ភោគ ខន បន្តិច ។ មុននេះបន្តិច លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច លោកបានប្រាប់អង្គសវនាការហើយថា ឯកសារពីរដែលមានឈ្មោះថា ភោគ សាខុន ហើយនិង ភោគ សារុន គឺជាឯកសារនៅទួលស្លែង ។ ហេតុដូច្នេះហើយការលើកឡើងរបស់មេធាវីការពារសួរថា តើលោក ភោគ ខន មានឯកសារអ្វីបញ្ជាក់ថា ខ្លួនលោកដែលជាអ្នកជាប់នៅទួលស្លែងនោះ? ខ្ញុំគិតថា នេះគឺជា-- វាហួសពីសមត្ថភាពរបស់គាត់ដែលនឹងត្រូវបំភ្លឺប្រាប់ថា តើត្រូវបង្ហាញភស្តុតាងយ៉ាងម៉េច ដើម្បីឲ្យអង្គសវនាការដឹងថា គាត់ហ្នឹងជាប់នៅគុកទួលស្លែង ហើយគាត់ហ្នឹង ប្រពន្ធរបស់គាត់ហ្នឹងជាប់នៅគុកទួលស្លែង ។ បាទខ្ញុំកត់សម្គាល់ប៉ុណ្ណោះ ។

[១០:៣៣:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអាចបន្តទៅទៀត អាចសួរបាន ។ គ្រាន់តែកត់សម្គាល់មិនមែនជាការជំទាស់ទេ ការកត់សម្គាល់នេះក៏មិនត្រឹមត្រូវដែរ គឺជនជាប់ចោទបានទទួលស្គាល់នូវឯកសារនេះ ច្បាស់លាស់ថាជាចេញពីទួលស្លែង ។ ប៉ុន្តែ នៅចុងឆ្នាំ៧៥ ឬក៏ដើមឆ្នាំ៧៦ ទម្រង់បែបនេះប្រើប្រាស់កាលពីចុងឆ្នាំ៧៥គឺភាគច្រើន ។ អ៊ីចឹងជនជាប់ចោទ-- ដើមបណ្ដឹងរដ្ឋប្បវេណី ភោគ ខន ហើយនិងប្រពន្ធរបស់គាត់ដែលត្រូវចាប់ខ្លួនបញ្ជូនទៅហ្នឹង គឺនៅចុងឆ្នាំ៧៨ ។ អ៊ីចឹង កាលប្បវត្តិហ្នឹង គឺខុសគ្នាឆ្ងាយ ។ នេះជាការសិទ្ធិក្នុងការបញ្ជាក់ច្បាស់លាស់ ពីព្រោះបញ្ហា គឺខាងមេធាវីការពារបានកត់សម្គាល់តាំងពីដំបូងនៃភាពមិនប្រាកដប្រជានៅក្នុងការវិមតិសង្ស័យថា ដើមបណ្ដឹងរដ្ឋប្បវេណីនេះមិនបានជាប់នៅក្នុងគុកទួលស្លែងទេ ។ អ៊ីចឹងសំណួរ គឺចង់បញ្ជាក់ឲ្យបានច្បាស់ ។

សូមអញ្ជើញមេធាវីការពារក្ដីបន្តសំណួរទៀត ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណលោកប្រធាន ។ ជាបន្ថែមទៅទៀត ខ្ញុំបាទសូមអនុញ្ញាតពីលោកប្រធានជម្រាបថា ឈ្មោះ ភោគ សារុន, ឈ្មោះ ភោគ សាខុន អីនេះ ខ្ញុំក៏ប្រាកដថា ជា ភោគ ខន ដែរ ពីព្រោះខ្លួនគាត់ផ្ទាល់គាត់បានឆ្លើយចំពោះមុខលោកប្រធាន លោកប្រធានសួរគាត់ថា អត់មានឈ្មោះអីក្រៅពីហ្នឹងទេ ។ តែចំពោះមុខមេធាវីរបស់គាត់ គាត់ថាមាន ដូច្នេះ វាអត់មានប្រាកដទេ ហើយកាលបរិច្ឆេទក៏វាខុសគ្នាទៀត វាខុសគ្នាឆ្ងាយណាស់ ។ ដូច្នេះ វាធ្វើឱ្យយើងសង្ស័យថា គាត់មិនអាចជាប់នៅស-២១ ទាំងប្ដី ទាំងប្រពន្ធ ។

ដូច្នេះ រឿងនេះបើសិនជាលោក ភោគ ខន គាត់មានភស្តុតាងអី គាត់អាចបញ្ជាក់ប្រាប់តុលាការឱ្យច្បាស់ជាងនេះទៅទៀត ដែលអាចឱ្យតុលាការជឿបាន ឱ្យខ្ញុំបាទជាមេធាវីការពារជឿបាន ថាពិតជាជាប់នៅស-២១ ប្រាកដមែន គឺខ្ញុំទទួលស្គាល់ភ្លាមៗ អត់រួញរាទេ ។ ក៏ប៉ុន្តែ បើគាត់គ្មានទេ គឺខ្ញុំឈប់សួរហើយទុកឱ្យតុលាការសម្រេចសេចក្ដីចុះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្ដីអន្តរជាតិ ។

[១០:៣៦:០០]

**សួរដោយលោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណលោកប្រធាន ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី យើងបានសង្កេតឃើញថា មានភាពផ្ទុយគ្នារវាងចម្លើយដែលបានផ្ដល់នៅឆ្នាំ២០០៨ ដោយអង្គការអន្តរជាតិមួយ ហើយនិងការផ្ដល់សក្ខីកម្មផ្ទាល់មាត់ ។ នៅក្នុងសំណេរនោះ ដែលគេប្រមូលដោយអង្គការអន្តរជាតិមួយនោះ បានបញ្ជាក់នូវសេចក្ដីលម្អិតជាច្រើន ដែលលោកមិនបានបញ្ជាក់នៅក្នុងថ្ងៃនេះទេ ។ ពីម្សិលមិញលោកនិយាយថាមានតែអ្វីចំនួនដែលលោកបានបញ្ជាក់នៅក្នុងសក្ខីកម្មទេ មិនមែនព័ត៌មាននៅក្នុងចម្លើយផ្ទាល់មាត់នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨ នោះទេ ។

**ស៖** តើលោកអាចពន្យល់បានដូចម្ដេច អំពីភាពខុសគ្នាសំខាន់ៗទាំងអស់នេះ?

**ឆ៖** សូមជម្រាបលោកមេធាវីការពារក្ដី ឃើញថា កាលនោះនៅឆ្នាំ-- ចុងឆ្នាំ៧៨ គឺខ្ញុំបានមកនៅមកជាប់គុកមែន ក៏ប៉ុន្តែខ្ញុំមិនបានសន្និដ្ឋានថាមន្ទីរស-២១ ទេ ព្រោះថា ដោយខ្ញុំមិនដឹង ។ ហេតុដូច្នេះ ខ្ញុំសូមជម្រាបថា ការជាប់ គឺជាប់ពិត ជាប់ប្រាកដពិតមែន មានតែមន្ទីរស-២១ ខ្ញុំទើបតែនឹងដឹងពេល

ក្រោយនេះទេ ។ ពេលនៅឆ្នាំ២០០៨ ដែលខ្ញុំបានចូលទៅជាមួយនឹងលោកមេធាវី ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដែលបានទៅនោះទេ ព្រោះការជាប់ឃុំឃាំងខ្ញុំមិនបានសន្និដ្ឋានថា ខ្ញុំនៅជាប់មន្ទីរ ស-២១ នោះ ឬនៅទីណានោះទេ ។ ក៏ប៉ុន្តែ ខ្ញុំអាចចាំបានថា ប្រាកដជាស-២១ ពិតមែន ។

**ស៖** នៅក្នុងខណៈពេលកន្លងមកទៀត ប៉ុន្តែយើងឃើញថា វាមានភាពផ្ទុយគ្នាជាច្រើន ខ្ញុំយោងទៅរកអង្គហេតុមួយនៅក្នុងចម្លើយលាយលក្ខណ៍អក្សរលោកបាននិយាយថា "ឌុច បានសួរសំណួរមួយចំនួនកាលនោះ" លោកបានសួរថា "តើលោកបានក្បត់ហ្នឹងរយៈពេលប៉ុនណាហើយ?" ហើយបានគំរាមថា "សម្លាប់លោកជាមួយ-- ដូចប្រពន្ធរបស់លោក" ហើយក៏បានបញ្ជាថា បញ្ជាឲ្យលោក ឡាច ហើយ និង លីន ឲ្យសម្លាប់លោក-- ឲ្យធ្វើទារុណកម្មរហូតទល់តែលោកសន្លប់ ។ ហើយម្សិលមិញហ្នឹង លោកបាននិយាយថា ពាក្យទាំងអស់នេះមិនត្រឹមត្រូវទេ តើលោកអាចបញ្ជាក់ថ្ងៃនេះបានទេ? ឬក៏អាចហ្នឹងលោកដើម្បីពន្យល់យើង ថាហេតុអីបានចំណុចទាំងអស់នេះ ដែលខ្ញុំលើកអំមិញនេះគឺថា ជាចំណុចដែលមិនស្របគ្នាទៅអ្វីដែលលោកបានផ្តល់សក្ខីកម្មផ្ទាល់មាត់នោះ ។

[១០:៣៩:៣០]

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! ឃើញថាចម្លើយនៅក្នុងពាក្យបណ្តឹងដែលខ្ញុំបានដាក់ ឬក៏-- ខ្ញុំសូមអភ័យទោស ព្រោះថា ឃើញថា កាលនិយាយពីកាលនោះ គឺខ្ញុំនិយាយនៅក្នុងអង្គប្រជុំធំមួយ នៅក្នុងវត្ត ដូចខ្ញុំជម្រាបខាងដើម គឺថាបាននិយាយហើយ ។ ក៏ប៉ុន្តែ ជាការនិយាយ ពេលនោះ គឺឃើញថា មានការភន់ច្រឡំមែនហើយ ។ ប៉ុន្តែ ខ្ញុំមិនអាចចាំបាន ក៏ខ្ញុំសូមសារភាព ។ ឃើញថា បានឆ្លើយតែឮ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដូចជាបានឮ ខ្ញុំក៏បានដាក់ទៅ ។ តែតាមពិត មកពេលក្រោយដូចខ្ញុំបាននឹកឃើញថា ឱ! មិនមែនទេ ។ ហួសពេលទៅហើយ ពេលខ្ញុំប្រែកន្លាស់ពាក្យ គឺមិនអាចកែទៅបាន ។ ហេតុដូច្នេះ គឺមិនមែនទេ គឺមិនមែន កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះទេ ។

ឯឈ្មោះ ដូចជា ឡាច ក៏ដោយ គឺ ឡាច នេះ បើតាមខ្ញុំនិយាយកាលនោះ ខ្ញុំថា មិនមែន ឡាច នេះជាអ្នកសួរចម្លើយទេ ។ គឺ ឡាច គឺអ្នកជនរងគ្រោះដូចជាខ្ញុំដែរ គឺនៅក្នុងកងពល៣១០ ដូចគ្នា ។ នេះគឺជាការភាន់ច្រឡំ ព្រោះខ្ញុំឃើញយកពាក្យនោះ មកមើល ខ្ញុំមើលឃើញម្តងហើយ ខ្ញុំបានមើលឃើញថា អ៊ូ! ពាក្យនេះខុសបាត់ ។ ឡាច នេះ គឺជាជនរងគ្រោះដូចជាខ្ញុំដែរ ចាប់មុនខ្ញុំទៀត ។ នេះសូមអភ័យទោស ដែលខ្ញុំមិនបានចាប់អារម្មណ៍ហ្នឹងការមើល ។

**ស៖** ពីម្សិលមិញលោកបាននិយាយថា មនុស្សម្នាក់ឈ្មោះ ដែលមកពីខាងកើតនោះ បងខាងកើតមកចូលរួមការសួរចម្លើយរបស់លោក បន្ទាប់មកលោកក៏បានយល់ថា គឺគាត់ជាមេធំនៅក្នុងមណ្ឌលឃុំខ្លួននោះ ។ ប៉ុន្តែថ្ងៃនេះ លោកបានប្រាប់យើង និយាយថា ខ្ញុំមិនអាចដឹងថាតើគាត់ជាប្រធាននៃមន្ទីរនោះទេ ហើយខ្ញុំពិនិត្យឃើញថា មានភាពផ្ទុយគ្នានៅក្នុងចម្លើយហ្នឹង ។ តើលោកអាចពន្យល់បានទេអំពីចំណុចនេះ?

**ឆ៖** បាទ, សូមជម្រាបលោកមេធាវី! គឺថាម្សិលមិញខ្ញុំឆ្លើយ ដូចជានេះដែរ ប៉ុន្តែខ្ញុំអាចបញ្ជាក់បានថា ពេលសួរចម្លើយ គឺបងខាងកើត គាត់ដើរទៅ គឺ ហ៊ា ទេអ្នកស្រែកនោះ ។ ខ្ញុំមិនបានឃើញបងខាងកើតនេះជាអ្នកណាដែរ គឺសម្លឹងបានតែត្រឹមជង្គង់ទៅក្រោម ទៅមុខមិនបានឃើញទេ ។ សូមជម្រាបឲ្យច្បាស់អ៊ីចេះ ។

**ស៖** តើលោកប្រាកដទេថា បងខាងកើតនោះគឺ-- ហើយនិងជនជាប់ចោទនេះ មិនមែនមនុស្សដូចគ្នា មិនមែនជាមនុស្សតែមួយនោះ?

**ឆ៖** សូមជម្រាបលោកមេធាវី! ព្រោះកាលបានជាខ្ញុំចាប់អារម្មណ៍ថា គេហៅ “បងខាងកើត” ជាអារម្មណ៍ គឺអាចយល់បានថា បងខាងកើត គឺជាអ្នកទទួលខុសត្រូវខ្ពស់ទេដឹងនៅក្នុងនេះ បានជាគេហៅថា “បងខាងកើត” តែខ្ញុំមិនស្គាល់ថា ឈ្មោះបងខាងកើតនេះជាអ្នកណាឲ្យពិតប្រាកដនោះទេ ។ គ្រាន់តែឮថាបងខាងកើត ដែលគេហៅតែប៉ុណ្ណោះទេ ។

[១០:៤៣:១១]

**ស៖** ខ្ញុំចង់ត្រឡប់ទៅរកសំណួរមួយដែលលោក ការ សាវុត្ថ បានសួរលោកនោះ។ ប៉ុន្តែ ខ្ញុំមិនយល់ច្បាស់ ។ ខ្ញុំទាក់ទងទៅនឹងឈ្មោះរបស់លោក ម្សិលមិញនៅចាប់ផ្ដើមនៅសវនាការលោកប្រធានបានសួរលោកឲ្យបញ្ជាក់ថា លោកមានឈ្មោះតែមួយទេ? លោកមានឈ្មោះ តែ ភោគ ខន មួយទេ? លោកបញ្ជាក់ដោយច្បាស់ថា ប៉ុន្តែ ឥឡូវនេះលោកបានសួរសំណួរទៅលោក ការ សាវុត្ថ លោកមិនបានយល់ ហើយលោកមិនបានយល់សំណួរកាលនោះទេ ប្រហែលជាលោកប្រធានមិនបានច្បាស់អំពីឆ្នាំដែលថា មុនឆ្នាំ១៩៧៩ ហើយលោកបានប្រើឈ្មោះផ្សេងទៀត ។ អ៊ីចឹង ខ្ញុំត្រឡប់ទៅសំណួរមួយដែលសួរដោយចៅក្រម ឡាវ៉ែន៍ ទាក់ទងទៅនឹងឈ្មោះរបស់លោក ។ លោកចៅក្រម ឡាវ៉ែន៍ បានសួរលោកថា “តើលោកឈ្មោះ ភោគ សាខុន នោះ?” មានន័យ-- តើលោកយល់ដូចម្ដេចទេ? ចៅក្រម ឡាវ៉ែន៍ បានយោងទៅរកឯកសារមួយដែលមាន 00282312 ដែលនិយាយអំពីឈ្មោះ ភោគ សាខុន លោក

ឆ្លើយថា ខ្ញុំដកស្រង់សម្តីរបស់លោកថា លើកលែងតែមានការខុសឆ្គង "ឯកសារនេះមាន គឺថាមាននាមត្រកូល ដូចខ្ញុំ ប៉ុន្តែមានឈ្មោះផ្ទាល់ហ្នឹង ខុសពីខ្ញុំ" ។ ប៉ុន្តែ មេធាវីបានយកឯកសារហ្នឹង ពីកន្លែងប្រភពផ្សេងប្រហែលជាមិនមែនជាឈ្មោះខ្ញុំ ។ ប៉ុន្តែថ្ងៃនេះ ឆ្លើយតបទៅនឹងសំណួរថា តើឈ្មោះលោកជា ភោគ សាខុន ដែរឬទេ? លោកឆ្លើយថា "បាទ" ។ ប៉ុន្តែម្សិលមិញ នៅក្នុងឯកសារដែលមានឈ្មោះនេះ លោកបានប្រកាន់រឹងមាំថាៗ ឈ្មោះ ភោគ សាខុន នោះមិនមែនជាឈ្មោះលោកទេ ។ តើលោកអាចធ្វើម៉េចឲ្យយើងជឿបាននៅពេលនេះ ថាណាមួយជាឈ្មោះពិតប្រាកដនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! ឃើញថា ឈ្មោះ ភោគ សាខុន នេះ ខ្ញុំប្រើពីមុនឆ្នាំ៧៥ គឺនៅឆ្នាំចាប់ពីខ្ញុំចូលបដិវត្តន៍ឆ្នាំ៧១មក រហូតមកដល់ឆ្នាំ៧៤ គឺខ្ញុំប្រើតែឈ្មោះ ភោគ សាខុន រហូត ។ ដល់បែកភ្នំពេញនៅថ្ងៃ១៧ មេសា ៧៥ រៀបកងទ័ព៣១០រួច នៅក្នុងភ្នំពេញនេះរួចហើយ ទើបខ្ញុំប្រែឈ្មោះដាក់ ភោគ សារុន ដែលគេហៅបន្ទាប់ឈ្មោះដើម គឺ ភោគ សាខន ឈ្មោះបដិវត្តន៍ គឺ ភោគ សារុន ។ ពេលនោះគេហៅថា ភោគ សារុន រហូតទាល់តែចាប់ខ្លួន ។ នេះបានខ្ញុំជម្រាប ព្រោះថាតាំងសំណួរម្សិលមិញខ្ញុំស្ទើតជាមិនយល់សំណួរ ហេតុដូច្នេះក៏ខ្ញុំបានឆ្លើយថា ឈ្មោះពី៧៥មក ខ្ញុំនាមឈ្មោះ ភោ-- សូមទោស ពីសម័យរំដោះ ៧ មករា ហើយ គឺប្រើឈ្មោះដើមរបស់ខ្ញុំទៅវិញ ទើបខ្ញុំប្រើថា ឈ្មោះ ភោគ សាខន រហូតមក ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារអន្តរជាតិមានសំណួរច្រើនទៀតទេ? ឬក៏អស់សំណួរហើយ?

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

លោកប្រធានខ្ញុំនៅមានសំណួរខ្លីៗពីរ ដែលត្រូវសួរទៅដើមបណ្តឹងរដ្ឋប្បវេណី ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ មានហេតុផលពីរ ។ ទីមួយ គឺដល់ម៉ោងត្រូវសម្រាក ។ ទីពីរ ឌីវីឌីដែលថតសំឡេងនោះបានអស់ហើយ ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទីរហូតដល់ម៉ោងដប់មួយ អញ្ជើញចូលវិញ ដើម្បីបន្តការសួរដេញដោលបន្តទៅទៀត ។

មន្ត្រីតុលាការសម្របសម្រួលរកកន្លែងសមរម្យសម្រាប់ផ្តល់ជូនដល់លោក ភោគ ខន ដើម្បីបានសម្រាក ។

*[សវនាការសម្រាកពីម៉ោង ១០:៤៨នាទី ដល់ម៉ោង ១១:០៤ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចពិភាក្សាដេញដោលលើដើមបណ្ដឹងរដ្ឋប្បវេណី ភោគ ខន ហើយជាបន្តនេះសូមប្រគាល់វេទិកាទៅការពារក្ដីអន្តរជាតិ ។ បើមានសំណួរសូមអញ្ជើញ ។

**សួរដោយលោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណលោកប្រធាន ។ លោកបានលើកឡើងថា លោក ឈឿន ភាំ គឺជាបងជីដូនមួយរបស់លោក ។

**ស៖** តើលោកអាចបញ្ជាក់ទេ? តើលោកមានទំនាក់ទំនងបងប្អូនយ៉ាងម៉េចជាមួយនឹងគាត់ជាបងប្រុស ប្អូនប្រុសរបស់លោក ឬក៏យ៉ាងម៉េច? គឺលោក ឈឿន ភាំ ឬគាត់ហ្នឹងជាបងប្អូនសាច់ឆ្លាយរបស់លោកសូមឲ្យលោកបញ្ជាក់?

**ឆ៖** សូមជម្រាបលោកមេធាវីឈ្មោះ ឈឿន ភាំ ហៅ ទិន ណេត គឺជាបងជីដូនមួយខាងម្ដាយរបស់ខ្ញុំ ។ គឺទីនៅដើមគឺនៅភូមិគោកឫស្សីខាងត្បូង ឃុំដាន់រុន ស្រុកសូទ្រនិគម ខេត្តសៀមរាប ជាបងជីដូនមួយ ។

**ស៖** ដូច្នេះ តាមដែលខ្ញុំយល់ឪពុកម្ដាយរបស់ ឈឿន ភាំ គឺជាប្អូនស្រីរបស់ឪពុកម្ដាយរបស់លោក ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ឈឿន, គុល ឈឿន គឺជាបងរបស់ម្ដាយខ្ញុំបង្កើត ដែលជាឪពុករបស់លោក ឈឿន ភាំ ហៅ ទិន ណេត ។

**ស៖** ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីលោកមានសិទ្ធិក្នុងការមកផ្ដល់សក្ខីកម្ម និងមកស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត ។ លោកអាចបញ្ជាក់ជូនយើងខ្ញុំដែរឬទេថា លោកបានឆ្លៀតយកឱកាសមុនៗពេលដែលលោកចូលមកទីនេះ ហើយលោកបានឮទៅលើចម្លើយផ្សេងៗទាក់ទងទៅនឹងបុគ្គលដែលបានជាប់ឃុំនៅស-២១ តើមែនដែរឬទេ លោកធ្លាប់ឮចម្លើយនោះពីមុនៗមក?

**ឆ៖** សូមជម្រាបលោកមេធាវី រឿងនេះខ្ញុំមិនបានដឹងពីអ្នកណាដែលបង្គាប់បញ្ជាខ្ញុំនោះទេ ។ ខ្ញុំឃើញថា ដូចជាអ្នកពាក់ព័ន្ធជាប់ដូចជាបងខ្ញុំនេះ គឺខ្ញុំបានឃើញជាក់ស្ដែងផ្ទាល់នឹងភ្នែកព្រោះរស់នៅអង្គភាពជាមួយគ្នា និងកងជាមួយគ្នា ។ នៅ៣១៧ ដែលជាវរសេនាតូច៣១៧ នោះពិតប្រាកដមែន ខ្ញុំមិនបានពាក់ព័ន្ធពីអង្គការណា ឬក៏អ្នកណាដែរ ថាខ្ញុំនេះទទួលបានសំណុំរឿងពីឈ្មោះបងខ្ញុំនោះទេ ។ គឺខ្ញុំ

ទទួលបាននៅពេលថ្មីៗមុននេះដែរ ដែលខ្ញុំបានទទួលប្រវត្តិរូបបងខ្ញុំនេះក៏តាមរយៈអង្គការគាត់បានផ្តល់ឲ្យ ។

[១១:០៨:២៨]

**ស៖** ខ្ញុំជឿថា ដូច្នេះលោកយល់ខុសទៅនឹងសំណួររបស់ខ្ញុំដែលសួរទៅកាន់លោក សំណួរខ្ញុំនោះគឺខ្ញុំសួរច្បាស់ណាស់ ។ នៅពីរថ្ងៃមុនៗពេលដែលលោកមកអង្គុយនៅទីនេះ ថាតើលោកបានមកចូលរួមឬក៏ធ្លាប់ស្តាប់ចម្លើយដែលដើមបណ្តឹងរដ្ឋប្បវេណីមុនគាត់បាននិយាយអំពីការដែលគាត់ជាប់ឃុំនៅ ស-២១ ដែរ ឬទេ?

**ឆ៖** បាទ, មុននឹងខ្ញុំចូលរួមនៅកន្លែងនេះ គឺខ្ញុំបានមកទីនេះជាញឹកញាប់ដែរនៅទីនេះ ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ដូច្នេះសូមលោកជម្រាបយើងខ្ញុំ តើលោកបានស្តាប់ចម្លើយសាក្សីមួយណាដែរ? នៅពេលដែលលោកមកចូលរួមស្តាប់នៅទីនេះនោះ ។

**ឆ៖** បាទ គឺលើកទីមួយ គឺអ៊ំ ជុំ ម៉ី-- អ! សូមទោស អ៊ំ វ៉ាន់ ណាត, អ៊ំ ជុំ ម៉ី, អ៊ំ ប៊ូ ម៉េង ហើយនិង នង ចាន់ផល បាទ ។

[១១:១០:០០]

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណលោកច្រើនចំពោះការឆ្លើយបញ្ជាក់ ហើយខ្ញុំមិនមានសំណួរនោះទេ ។ លោកប្រធានសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ?

**កញ្ញា ទី ស្រ៊ីនណា៖**

សូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល នាងខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបញ្ជាក់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនូវចំណុចមួយ ដែលពាក់ព័ន្ធទៅនឹងកែប្រែឈ្មោះការប្រើប្រាស់ឈ្មោះរបស់គាត់ដែលមានការផ្លាស់ប្តូរនៅក្នុងជំនាន់នោះ តើមានរបៀបយ៉ាងដូចម្តេចដែរ? បើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសូមៗបញ្ជាក់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ សូមអរគុណ ។

[១១:១០:៥០]

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទេ ។ ការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភោគ ខន ឃើញថាដល់ទីបញ្ចប់ហើយ ។

អង្គជំនុំជម្រះសូមថ្លែងអំណរគុណដល់លោក ភោគ ខន ដែលបានអញ្ជើញមកចូលរួមនៅក្នុងការធ្វើសេចក្តីថ្លែងការណ៍បំភ្លឺដល់អង្គជំនុំជម្រះតាមការកោះអញ្ជើញរបស់អង្គជំនុំជម្រះសាលាដំបូង ។

ហើយអង្គជំនុំជម្រះ ក៏មានការកត់សម្គាល់អំពីភាពលំបាកប្រឈមរបស់លោកដែរនៅក្នុងការឆ្លើយនៅសំណួរជាច្រើនពីអង្គជំនុំជម្រះនិងភាគីដែលពាក់ព័ន្ធ ។ ហើយអង្គហេតុ រឿងហេតុដែលកើតឡើងដែលកើតឡើងអីជាច្រើនឆ្នាំមកហើយនោះ ហើយក៏ប៉ះពាល់ផ្នែកខាងអារម្មណ៍របស់លោកដែរដែលអតីតកាលបានរំឭកឡើងវិញ ។

ហើយឥឡូវនេះដល់ទីបញ្ចប់ហើយ ។ ហើយមន្រ្តីតុលាការ គឺសម្របសម្រួលឲ្យគាត់បានត្រឡប់ទៅផ្ទះវិញ ដោយធ្វើការទំនាក់ទំនងជាមួយនឹងខាងផ្នែកការិយាល័យគាំពារជនរងគ្រោះ ។

លោក ភោគ ខន អាចអញ្ជើញទៅផ្ទះបានហើយ ។ អង្គជំនុំជម្រះអស់សំណួរសួរចំពោះលោកទៀតហើយ ។

ហើយមន្រ្តីតុលាការសូមអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី E2-80 ជិន ម៉េត ចូលមកកាន់បន្ទប់សវនាការ ។

*(ដើមបណ្តឹងរដ្ឋប្បវេណីទីពីរចូលកាន់សវនាការ)*

[១១:១៤:០៨]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្រី ជិន ម៉េត តើលោកស្រីឈ្មោះ ជិន ម៉េត អ៊ីចឹងពិតមែនដែរទេ?

**អ្នកស្រី ជិន ម៉េត៖**

**ឆ៖** ចាស, មុនដែលខ្ញុំចូលបម្រើការងារកងទ័ពបដិវត្តន៍នារី នៅស្រុកខ្ញុំជីដូនជីតាខ្ញុំហៅខ្ញុំតែខ្មិៗ ទេ តែដល់ខ្ញុំចូលការងារបដិវត្តន៍ហ្នឹង ខ្ញុំដាក់ឈ្មោះ ឃឹម ម៉េត ។

**ស៖** ចុះឈ្មោះ ជិន ម៉េត នេះ? លោកស្រីប្រើពាក្យត្រកូល ជិន ហ្នឹងចាប់ពីពេលណាមក?

**ឆ៖** ចាស, ខ្ញុំប្រើឈ្មោះ ជិន ម៉េត នៅពេលដែលក្រោយរំដោះឆ្នាំ១៩៧៩ ខ្ញុំទៅស្រុកវិញជួបជុំឪពុកម្តាយខ្ញុំ ខ្ញុំឈប់ប្រើត្រកូលជីតា ខ្ញុំដាក់ត្រកូលឪពុកខ្ញុំ ជិន ម៉េត តែម្តង ។

**ស៖** អ៊ីចឹងបានន័យថាឈ្មោះ ឃឹម ត្រកូល ឃឹម ហ្នឹងគឺជាជីតារបស់លោកស្រី ជីតាខាងឪពុក អ៊ីចឹងមែនទេ?

**ឆ៖** ចាស, គឺជាតាឪពុក ខាងឪពុកខ្ញុំ ។

**ស៖** ចុះឈ្មោះត្រកូល ជិន ហ្នឹងអ្នកណាគេ ជិន នេះ? ជាឪពុករបស់លោកស្រីពិតមែនដែរទេ?

**ឆ៖** ចាស, គឺ ជិន ហ្នឹង គឺជាឪពុករបស់ខ្ញុំ ។ គាត់ត្រកូលគាត់ ឃឹម ជិន ។

**ស៖** លោកស្រីរកនឹកមើលក្រៅពីឈ្មោះ ម៉េត ខ្លួនលោកស្រីផ្ទាល់ហ្នឹង លោកស្រីប្រើឈ្មោះអ្វីផ្សេងទៀតទេ?

**ឆ៖** (មិនឮសំឡេង)--

**ស៖** រង់ចាំបន្តិចណ៎ា ចាំមើលក្បាលមេក្រូហ្នឹងមានពណ៌-- ភ្លើងពណ៌ក្រហមចាំ-- បាននិយាយទើបអាចអ្នកបកប្រែភាសានុំងអាចស្តាប់បាន ហើយបកប្រែភាសាពីរភាសាទៀត គឺភាសាបារាំង និងភាសាអង់គ្លេស ដើម្បីឲ្យអន្តរជាតិដែលបានអញ្ជើញចូលរួមនេះទាំងអ្នកចូលរួមនៅក្នុងកិច្ចដំណើរការដំណើរការនីតិវិធី ទាំងសាធារណជនបានស្តាប់យល់អំពីដំណើរការប្រព្រឹត្តទៅនៃសវនាការនេះ ។

តើមានឈ្មោះផ្សេងពី ម៉េត ដែរឬទេ? ដែលលោកស្រីធ្លាប់ប្រើ?

**ឆ៖** ចាស, លោកប្រធាន សូមទោសលោកប្រធានអំមិញខ្ញុំអត់បានមើល ។ នៅស្រុកប្អូនៗខ្ញុំវាហៅឈ្មោះ ខ្និ អត់កើត គេហៅខ្ញុំថា បងមិៗ ។

**ស៖** ដល់ឆ្នាំនេះលោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ចាស, នាងខ្ញុំមានអាយុ៥១ឆ្នាំហើយ ។

**ស៖** លោកស្រីមានទីលំនៅសព្វថ្ងៃនៅឯណា?

**ឆ៖** អាស័យដ្ឋានទីលំនៅនាងខ្ញុំសព្វថ្ងៃនៅភូមិត្នោតជ្រុំ៤ ឃុំសង្កាត់បឹងទំពុន ខណ្ឌមានជ័យ ។

[១១:១៨:១៧]

**ស៖** លោកស្រីប្រកបមុខរបររកស៊ីអ្វីដែរសព្វថ្ងៃ?

**ឆ៖** ខ្ញុំសព្វថ្ងៃមុខរបរជានារីភូមិ ជំនួយការឲ្យភូមិត្នោតជ្រុំ៤ ហើយមើលថែរក្សាកុមារនៅក្នុងសហគមន៍ក្រីក្ររបស់ខ្ញុំចំនួន១៨០នាក់ ហើយ-- ខ្ញុំបានសុំជំនួយពីអង្គការហ្នឹង ជាអង្ករ ជាលុយដើម្បីផ្តល់ឲ្យកុមាររៀននៅក្នុងសហគមន៍ខ្ញុំ ចំនួន១៨០នាក់ ។

**ស៖** និយាយពីស្រុកកំណើតរបស់លោកស្រីវិញ តើលោកស្រីមានស្រុកកំណើតនៅទីកន្លែងណា?

**ផ៖** ចាស, ខ្ញុំស្រុកកំណើតនៅភូមិជន្លួស សង្កាត់ទួលគ្រើល ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។

**ស៖** ឪពុកឈ្មោះអី? ហើយស្លាប់ ឬរស់សព្វថ្ងៃ?

**ផ៖** ឪពុកនាងខ្ញុំឈ្មោះ ឃឹម ជិន គាត់បានស្លាប់ពីឆ្នាំ២០០៣ ។

**ស៖** ចុះម្តាយលោកស្រីគាត់ឈ្មោះអ្វីដែរ ហើយគាត់ស្លាប់ឬរស់សព្វថ្ងៃ?

**ផ៖** ម្តាយនាងខ្ញុំឈ្មោះ ឡី មន គាត់បានស្លាប់តាំងពីខ្ញុំកើតបានបីខែ ។

[១១:២០:០២]

**ស៖** នៅក្នុងរឿងក្តីនេះដែលមានជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ហើយអង្គជំនុំជម្រះកំពុងតែធ្វើសវនាការនេះ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា លោកស្រីបានដាក់ពាក្យបណ្តឹងសូមតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ ។ សំណួរសួរថា ដល់ចំពោះមុខអង្គជំនុំជម្រះនាពេលនេះ ថាតើលោកស្រីប្តឹងទាមទារសំណងដោយខ្លួនឯងផ្ទាល់ ឬក៏លោកស្រីទុកផ្ទេរសិទ្ធិនៅក្នុងការប្តឹងទាមទារសំណងនេះ ជូនទៅមេធាវីដែលជាអ្នកតំណាងរបស់លោកស្រី?

**ផ៖** ចាស, ខ្ញុំដាក់ពាក្យនេះ គឺដើម្បីរកយុត្តិធម៌ឲ្យជនរងគ្រោះ ដែលបានស្លាប់ ហើយក៏ដូចជាខ្ញុំនៅរស់ ហើយនាងខ្ញុំនឹងប្រគល់ទៅឲ្យមេធាវី និងតុលាការជាអ្នកសម្រេច ។

**ស៖** តើលោកស្រីមានទំនាក់ទំនងយ៉ាងម៉េចទៅនឹងអង្គហេតុ ដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ? ដូចជាអង្គហេតុនៅមន្ទីរសន្តិសុខស-២១ ឬក៏អង្គហេតុជើងឯក ហើយអង្គហេតុមន្ទីរសន្តិសុខស-២១ ហ្នឹង មានអង្គហេតុច្រើនទៀត ។ បានន័យថា លោកស្រី រឿងរ៉ាវរបស់លោកស្រីផ្ទាល់ដែលកើតមានចំពោះខ្លួនឯងផ្ទាល់ ឬក៏ញាតិមិត្ត ឬក៏ក្រុមគ្រួសាររបស់លោកស្រី ដែលទទួលរងនូវ អំពីអយុត្តិធម៌នៅក្នុងសម័យបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ផ៖** ចាស, គឺខ្ញុំរងនេះ គឺដើម្បីខ្លួនខ្ញុំផ្ទាល់ផង និងមិត្តភ័ក្តនៅក្នុងអង្គភាពខ្ញុំដែលបានស្លាប់បាត់បង់អស់ផង ។

**ស៖** លោកស្រីមានការព្រឹត្តិហេតុ ហេតុការណ៍យ៉ាងម៉េច កើតឡើងចំពោះលោកស្រីផ្ទាល់ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ស-២១ ឬក៏មន្ទីរអប់រំកែប្រែសាជាថ្មីនៅព្រៃស ពីរហ្នឹង គឺលោកស្រីពាក់ព័ន្ធនឹងអង្គហេតុណាមួយ?

**ផ៖** ចាស, គឺការពាក់ព័ន្ធរបស់ខ្ញុំនេះ កាលដែលគេចាប់នាងខ្ញុំមក ខ្ញុំមិនបានស្គាល់ថា កន្លែងដែលដាក់ឃុំឃាំងហ្នឹងជា ស-២១ ឬក៏ទួលស្លែង ឬក៏ជាព្រៃស នាងខ្ញុំអត់បានស្គាល់ទេ ។

**ស៖** អ៊ីចឹងមាន បានន័យសេចក្ដីថា ការដែលលោកស្រីដាក់ពាក្យប្ដឹងហ្នឹង គឺដោយសារមូល-ហេតុរឿងពាក់ព័ន្ធផ្ទាល់របស់លោកស្រីហ្នឹង គឺលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ត្រូវបានកងកម្លាំងខ្មែរក្រហមហ្នឹង ចាប់ខ្លួនលោកស្រីយកទៅឃុំឃាំង និងសួរចម្លើយ ។ អ៊ីចឹងមែនទេ? ប៉ុន្តែទីកន្លែងណាច្បាស់លាស់ហ្នឹង គឺមិនចាំទេ អ៊ីចឹងមែនទេ?

[១១:២៣:៣៣]

**ឆ៖** ចាស, ខ្ញុំចាំច្បាស់ថា ខ្ញុំពេលដែលគេចាប់ខ្ញុំមកនៅពេលយប់ហ្នឹង គេក៏បានបញ្ជូនខ្ញុំមកមន្ទីរឃុំឃាំងហ្នឹង នៅក្នុងមន្ទីរឃុំឃាំងហ្នឹង គឺមានបន្ទប់ហើយ ពេលដែលខ្ញុំចូលទៅដល់ មានមិត្តនារីខ្ញុំពីរនាក់នៅក្នុងនោះទៀត តែខ្ញុំក៏មិនបានចាប់អារម្មណ៍ថា មន្ទីរនោះជាមន្ទីរឃុំឃាំងឈ្មោះអ្វីទេ ប៉ុន្តែខ្ញុំបានចាំថា ខ្ញុំចូលមន្ទីរឃុំឃាំងហ្នឹងនៅអគារបណ្ដោយថ្ងៃ នៅបន្ទប់ជិតជណ្ដើរ ។

**ស៖** លោកស្រីត្រូវបានកងកម្លាំងខ្មែរក្រហមចាប់ខ្លួនលោកស្រីយកមកឃុំឃាំងហ្នឹង អស់រយៈពេលប៉ុន្មានដែរ? ប្រហែលជាប៉ុន្មានដែរ តាមលោកស្រីចាំ?

**ឆ៖** ចាស, គេឃុំខ្លួនខ្ញុំរយៈពេលដប់ប្រាំថ្ងៃ ដប់ប្រាំយប់ ។

**ស៖** ចុះដែលលោកស្រីបាននិយាយថា មានការទទួលរងនូវអំពីអយុត្តធម៌ផ្សេងទៀត ដែលមានចំពោះមិត្តភ័ក្ដ ឬក៏គ្រួសារ ញាតិសន្ដានរបស់លោកស្រីហ្នឹង លោកស្រីអាចរៀបរាប់បានទេ តើអ្នកណាខ្លះទៅ ដែលទទួលរងនូវអំពើអយុត្តិធម៌ក្នុងសម័យនោះ ហើយលោកស្រីមកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងទាមទារសំណងដើម្បីអ្នកទាំងអស់នោះ?

**ឆ៖** ខ្ញុំដើម្បីទាមទាររកយុត្តិធម៌ឲ្យមិត្តភ័ក្ដរបស់ខ្ញុំ ដូចជានៅក្នុងអង្គភាពរបស់ខ្ញុំ រស់នៅក្នុងកងពលទី៣ លេខ៤៥០ នៅក្នុងកងនារីរបស់នាងខ្ញុំហ្នឹង ចាប់ចូលឆ្នាំ១៩៧៧ ប្រធានកង ប្រធានវរៈរបស់ខ្ញុំហ្នឹងបាត់បន្តបន្ទាប់រហូតជារៀងរាល់ខែ ។ ដល់ពេលខ្ញុំចេះតែបាត់ទៅ នាងខ្ញុំក៏បានសួរៗទៅមេមកថ្មីៗហ្នឹង គេថា មិត្តបងៗមិត្តឯងកាលមុន គេទៅរៀនសូត្រហើយ មិនបាច់សួររកអីទេ មិត្តឯងខំតែធ្វើការងារទៅ ទៅ នាងខ្ញុំក៏លែងសួរទៀតទៅ ។

**ស៖** អ៊ីចឹងអ្នកផ្សេងទៀតហ្នឹង គឺលោកស្រីមិនអាចរៀបរាប់ឈ្មោះជាក់លាក់ទេ គ្រាន់តែជាមិត្តភ័ក្ដដែលធ្លាប់ធ្វើការនៅក្នុងអង្គភាព នៅក្នុងកងពល កងទ័ពនារី ដែលបានបាត់ខ្លួនទៅតែប៉ុណ្ណោះ ។ អាចខុសគ្នាណាលោកស្រថា ប្រសិនបើលោកស្រីបង្ហាញឈ្មោះជាក់លាក់ អង្គហេតុជាក់លាក់នៅចំពោះបុគ្គលណាមួយ ដែលលោកស្រីអះអាងថា ជាញាតិសន្ដាន នោះអង្គជំនុំជម្រះនឹងសួរដេញដោលឲ្យបាន

ស៊ីជម្រៅ ច្បាស់លាស់ចំពោះជនរងគ្រោះ ដែលបាត់បង់ជីវិតទៅ ដែលលោកស្រីបានចង្អុល បាននិយាយទៅដល់នោះ ។ ផ្ទុយទៅវិញ ប្រសិនបើលោកស្រីនិយាយគ្រាន់តែត្រួសៗ គ្រាន់តែជាទូទៅទេ អង្គជំនុំជម្រះនឹងមិនដេញដោលដល់អ្នកដែលលោកស្រីនិយាយមានលក្ខណៈទូទៅនោះទេ ។ ផ្ទុយទៅវិញ ប្រសិនបើលោកស្រីនៅក្នុងជំហរថា គឺរឿងខ្លួនឯងផ្ទាល់ គឺអង្គជំនុំជម្រះ ឬក៏អង្គសវនាការទាំងមូលនឹងដេញដោលអំពីភាពពាក់ព័ន្ធទៅនឹងអង្គហេតុតែចំពោះរឿងរ៉ាវរបស់លោកស្រីផ្ទាល់តែប៉ុណ្ណោះ ។ លោកស្រីយល់បានទេ?

[១១:២៧:១៤]

**ឆ៖** ចាស, យល់ស្តាប់បាន ។

**ស៖** ឥឡូវ នៅក្នុងការប្តឹងទាមទារហ្នឹង ដោយមូលហេតុតែគ្រាន់តែផ្ទាល់ខ្លួនរបស់លោកស្រី ឬលោកស្រីប្តឹងក្នុងនាមបង្ហាញនូវអង្គហេតុនៃការដែលសាច់ញាតិរបស់លោកស្រីត្រូវបានគេចាប់ខ្លួនយកទៅសម្លាប់ ឬក៏កម្ទេច ឬក៏បាត់ខ្លួនរហូតដល់សព្វថ្ងៃ ដែលមានឈ្មោះជាក់លាក់ណាផ្សេងទៀតក្រៅពីលោកស្រីដែរឬទេ?

**ឆ៖** ចាស, នាងខ្ញុំដាក់នេះ គឺដើម្បីខ្លួនខ្ញុំផ្ទាល់ផង ហើយនិងបងៗខ្ញុំប្រាំនាក់ មានឈ្មោះ បង ណាំ, បងយ៉ាត, បងសែន, បងជឿន ហើយនិងបងឡា ដែលគាត់ជាប្រធានរបស់ខ្ញុំ ។

*(អ្នកបកប្រែ៖ លោកប្រធាន សូមឲ្យលោកស្រីអានឈ្មោះម្តងទៀត ទាន!)*

**ស៖** លោកស្រីនិយាយឈ្មោះអ្នកទាំងប្រាំនាក់អម្បាញ់មិញនេះឲ្យបានច្បាស់ ហើយគួរតែត្រូវប្រើប្រាស់ទាំងត្រកូលរបស់គាត់ផង ទីមួយ ។ ទីពីរ គឺបញ្ជាក់ភេទផង ។ ទីបី គឺបញ្ជាក់អំពីទំនាក់ទំនងជាមួយនឹងលោកស្រី ថាគាត់ហ្នឹងឈ្មោះ ណាំ ហ្នឹង ត្រូវជាយ៉ាងម៉េចជាមួយនិងលោកស្រី ឬក៏ឈ្មោះបន្តបន្ទាប់ទាំងប្រាំនាក់ហ្នឹង ស្រី ឬប្រុស ហើយឈ្មោះត្រកូលពេញ ហើយនិងគាត់មានទំនាក់ទំនងយ៉ាងម៉េចជាមួយលោកស្រី ជីដូនមួយ ជីទួតមួយ បងប្អូនបង្កើត ឪពុកមា អីអ៊ីចឹងនែ៎! ឲ្យបានច្បាស់ ។

**ឆ៖** ចាស, លោកប្រធាន! ខ្ញុំអត់បានស្គាល់ត្រកូលរបស់គាត់ទេ ព្រោះជំនាន់នោះ យើងមិនដែលដេញដោលសួររកត្រកូលទេ គឺហៅគេតែ បងៗ! គឺបង យ៉ត គឺគាត់ជាស្រីទេ គាត់ជាប្រធានវរសេនាតូចនៅកងនារី ហើយបង ជឿន ក៏គាត់ជានារីដែរ គាត់ជាអនុប្រធាននៅក្នុងអង្គភាពនារីដែរ ។ ហើយបង ណាំ គាត់ជាសមាជិក បន្ទាប់មក គាត់ក៏ជានារីដែរ ។ ហើយ បងឡា គាត់ជាប្រធានកងធំខ្ញុំផ្ទាល់ខ្ញុំរស់នៅជាមួយ ។ កាលពេលនោះ ពួកយើងមិនដែលប្រើត្រកូលទេ ហៅតែបងៗ ។

[១១:២៩:៤២]

**សៈ** ចុះទីប្រាំ, អំមិញបានប្អូននាក់ហើយ នៅមួយនាក់ទៀត ទីប្រាំអ្នកណាគេ?

**ផៈ** បងសែន ហ្នឹង ក៏គាត់ជាក្នុងចំណោមអ្នកគ្រប់គ្រងក្នុងវរៈអង្គភាពនារីដែរ គាត់ជាស្រីទេ លោកប្រធាន ។

**សៈ** អ្នកទាំងប្រាំដែលលោកស្រីរៀបរាប់ហ្នឹង តើគាត់មានការជាប់ញាតិសន្តានរបស់លោកស្រី ឬក៏គ្រាន់តែជា ជាមេកើយ ឬក៏ជាអ្នកធ្វើការជាមួយហ្នឹង នៅអង្គភាពកងពលស្ត្រីលេខ៤៥០ជាមួយគ្នាតែប៉ុណ្ណោះ?

**ផៈ** អ្នកទាំងប្រាំហ្នឹង គឺជាថ្នាក់ដឹកនាំនៅក្នុងអង្គភាពនារីរបស់ខ្ញុំហ្នឹង គាត់ក៏បានមើលថែខ្ញុំតាំងពីដែលបានចូលបម្រើមក គាត់មិនដែលបានប្រើអ្វីឲ្យធ្ងន់ធ្ងរចំពោះខ្ញុំទេ គាត់មានការអប់រំមកលើខ្ញុំច្រើន ។

**សៈ** មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកស្រីនៅឯណា? ហើយលោកស្រីធ្វើការងារអ្វីដែរ?

**ផៈ** មុនឆ្នាំ១៩៧៥ អ៊ូ!នាងខ្ញុំនៅចុងឆ្នាំ១៩៧៤ នៅក្នុងមូលដ្ឋានរបស់នាងខ្ញុំបានប្រមូលក្រុមនារីៗក្រោមអាយុ១៨ឆ្នាំហ្នឹង ដើម្បីមកបម្រើឲ្យកងទ័ពនារីបដិវត្តន៍ ។ ពេលនោះពួកខ្ញុំ នៅក្នុងភូមិរបស់នាងខ្ញុំ គេប្រមូលបាន២០នាក់ ហើយគេបញ្ជូនពួកនាងខ្ញុំមកដល់ខេត្តកំពង់ចាម នៅស្រុកជើងព្រៃ នៅស្រុកជើងព្រៃ ពួកនាងខ្ញុំឈរនៅហ្នឹង គេរៀបចំជាកង ជាក្រុមរួចហើយ ឲ្យពួកនាងខ្ញុំហាត់ៗជាយោធា រៀន ហាត់រៀនលូន រៀនដោះកាំភ្លើង រៀនលាងកាំភ្លើង រៀនដាក់មីន ដោះមីនអី រៀនចេះខ្លះអត់ខ្លះហ្នឹង អស់រយៈបីខែ បានគេបញ្ជូនកងនារីហ្នឹង មកនៅឈរនៅស្រុកបាធាយ។ ស្រុកបាធាយហើយពួកខ្ញុំ គេឲ្យជញ្ជូនគ្រាប់ ជញ្ជូនបាយទៅឲ្យសមរភូមិនៅភូមិកោះចិន សមរភូមិកំពង់រទេះ មុខកំពូល ភូមិសំបួរមាស គឺបណ្ដោយតាមខ្សែត្រៀមហ្នឹង ពួកនាងខ្ញុំ ពេលដល់ថ្ងៃល្ងាចឡើង បញ្ជូនបាយយកទៅឲ្យកងទ័ព ។ ពេលដែលកងទ័ពវាយរបួសទៅ ពួកនាងខ្ញុំសែងយុវជនដែលមានរបួសហ្នឹង មកដាក់ពេទ្យនៅជើងឆ្នុក ។

**សៈ** នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ លោកស្រីនៅឯណា? ហើយលោកស្រីធ្វើអ្វីដែរ?

**ផៈ** នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នាងខ្ញុំនៅឈរនៅមុខកំពូល ស្រុកមុខកំពូល ទល់គ្នានឹងព្រែកព្នៅ ។ ពេលដែលគេវាយចប់ នាងខ្ញុំនៅនឹងសមរភូមិហ្នឹងអាចមើលឃើញសភាពការណ៍ដែលគេ

រំដោះពេលនោះមេបានបាញ់សញ្ញាមួយគ្រាប់ថា បានរំដោះទីក្រុងភ្នំពេញហើយ នៅវេលាម៉ោងប្រាំបួនជាង ពួកនាងខ្ញុំនៅនឹងហ្នឹង សមរភូមិ មានកប៉ាល់ហោះ មានអីហោះ ខ្វាត់ខ្វែងលើដំបូល-- លើក្បាលហ្នឹង ពួកនាងខ្ញុំខំជ្រកសម្ងំ អត់ហ៊ានមាត់ មានអីទេ ខ្លាចក្រែងយន្តហោះគេទម្លាក់គ្រាប់បែកទៅស្លាប់អស់ ។ ដល់នេះនាងខ្ញុំចេះ នៅក្នុងកងនាងខ្ញុំ ក្រុមនាងខ្ញុំហ្នឹងដប់ពីរនាក់ រស់នៅនឹងមុខកំពូលហ្នឹង គេឲ្យនៅហ្នឹង ពេលគេឡើងមកអស់ នៅថ្ងៃ១៧,១៨ បានគេចុះទៅយកនាងខ្ញុំ ។ មានកាណូតមួយទៅដឹកពួកក្រុមនាងខ្ញុំមក ។

**ស៖** ដឹកមកនៅកន្លែងណា?

**ឆ៖** ចាស, ពីកាណូតហ្នឹង កប៉ាល់ហ្នឹង គេចុះទៅយកក្រុមនាងខ្ញុំទាំងដប់ពីរនាក់មក ឡើងមកចាំគាត់មុខវត្តគ្រួស ត្រើយម្ខាង ព្រែកព្នៅ ពីវត្តគ្រួស មក ។

**ស៖** ហើយចាប់ពីពេលនោះមក រហូតដល់ពេលដែលលោកស្រីអះអាងថា ត្រូវបានកងកម្លាំងខ្មែរក្រហមចាប់ខ្លួនលោកស្រីយកទៅឃុំឃាំងនោះ តើចន្លោះចាប់ពីពេលនោះ រហូតដល់ពេលថ្ងៃចាប់ខ្លួន តើលោកស្រីធ្វើអ្វី ហើយលោកស្រីនៅទីណាដែរ?

[១១:៣៤:៤២]

**ឆ៖** នៅពេលដែលពួកកងនាងខ្ញុំ គេប្រមូលមកដល់វត្តគ្រួសហើយ គេឲ្យយើងធ្វើដំណើរជាថ្មើរជើងៗ កាំភ្លើង ផ្ទុះសៀរ សាក់កាដូអី មានគ្រប់គ្នាទាំងអស់ ម្នាក់ៗសុទ្ធតែមានកាំភ្លើង ផ្ទុះសៀរដាក់ពីមុខ សាក់កាដូស្ពាយពីក្រោយ ហើយយើងធ្វើដំណើរមកព្រែកព្នៅ ច្រាំងចំរេះ រហូតមកដល់ស្ពានជ្រោយចង្វារ ហើយឈរជើងនៅហ្នឹង មេកងក៏បានបញ្ជាឲ្យពួកនាងខ្ញុំហ្នឹងជញ្ជូនជយភណ្ឌដើម្បីប្រមូលទុកម្ដុំ ។ ពេលប្រមូលជញ្ជូនជយភណ្ឌអស់ ត្រឹមស្ពានជ្រោយចង្វាររហូតមកដល់ព្រែកព្នៅ ស្ពានជ្រោយចង្វារគីឡូលេខ៦ រោងចក្រ សេង ថៃ ៩៧, ៩៩ រោងចក្រកៅស៊ូក្រែក រោងចក្រគីឡូលេខ៦ រហូតមកដល់ព្រែកព្នៅហ្នឹង មុខសញ្ញាកងនារីនាងខ្ញុំ ។

ពេលបោសសម្អាតមួយជួរហ្នឹងអស់ហើយ អ៊ំ!ប្រមូលជយភណ្ឌអស់ហើយ ពួកមិត្តបងហ្នឹងក៏បានឲ្យពួកនាងខ្ញុំហ្នឹងបោសសម្អាតម្ដង ។ បោសសម្អាតតាមផ្ទះប្រជាជន តាមអគារផ្ទះធំៗ សាលារៀនវត្តអារាមអី បោសឲ្យស្អាត ។ ហើយពួកនាងខ្ញុំឈរជើងជាក្រុមៗនៅតាម តាំងពីព្រែកព្នៅមកទល់នឹងស្ពានជ្រោយចង្វារចែកបីកងធំ ចែកជាក្រុមៗនៅតាមផ្ទះដាក់បណ្ដាក់គ្នារហូត ។

ដល់ក្រោយមកទៀត ពេលបោសសម្អាតអស់ហើយ ប្រធានកងក៏បានចាត់កម្លាំងនារីហ្នឹង ឲ្យ

ទៅធ្វើស្រែៗនៅទួលគោក បឹងបាយ៉ាបនៅទួលគោក ពួកនាងខ្ញុំចាប់ធ្វើស្រែនៅឆ្នាំ១៩៧៦ ។ ធ្វើស្រែប្រាំងផង ធ្វើស្រែវស្សាផង ហើយមានកងធ្វើជីផ្សេង ហើយពេលនុំង ពួកយើងធ្វើស្រែបានច្រើនណាស់ ស្រូវកើតខ្លាំងណាស់ ព្រោះយើងធ្វើដាក់ជីធម្មជាតិ ធ្វើដោយខ្លួនឯងតាមកងមួយៗធ្វើប្រលងប្រជែងគ្នា ដើម្បីយកស្នាដៃ ក្នុងមួយហិកតាឲ្យបានបីតោន ទៅបីតោនកន្លះ ។

ដូច្នេះប្រធានកងម្នាក់ៗធ្វើការងារហ្នឹង ដើម្បីយកគុណសម្បត្តិ និងស្នាដៃតាមអង្គភាព តាមកងនីមួយៗ ។ ពួកនាងខ្ញុំខំប្រឹងធ្វើអត់មាន មិនសូវមានពេលបានសម្រាកទេ ។ តែដល់ក្រោយមកទៀត ចុងឆ្នាំ១៩៧៧ ប្រហែលជាពាក់កណ្តាលឆ្នាំ គេក៏បានចាត់នាងខ្ញុំឲ្យមកនៅជ្រោយចង្វារវិញ ជិតគីឡូលេខ៦ ជិតរោងចក្រក្រែប កៅស៊ូក្រែប ។ គេឲ្យនាងខ្ញុំចិញ្ចឹមជ្រូកៗ ក្រុមនាងខ្ញុំ១២នាក់ហ្នឹង ចិញ្ចឹមជ្រូក៤០ក្បាលៗ នៅមាត់ទន្លេហ្នឹង ។ តែយើងអត់មានបទពិសោធន៍ក្នុងការចិញ្ចឹមជ្រូក ពេលជ្រូកវាកូនមកហើយ មេវាដេកសង្កត់លើ ងាប់កូនជ្រូកទៅ មេកងក៏ដកឲ្យខ្ញុំទៅនៅខាងគីឡូលេខ៦ ចុងគីឡូលេខ៦វិញច្រកស្រូវដាក់បាវ ហើយលីស្រូវដាក់ឃ្លាំង រហូតដល់គេចាប់ខ្លួន ។

**សៈ** លោកស្រីរៀបរាប់អំពីរឿងហេតុដែលគេចាប់ខ្លួនលោកស្រីយកទៅដាក់ឃុំឃាំង ទិដ្ឋភាពទាំងឡាយដែលលោកស្រីបានជួបប្រទះនៅក្នុងអំឡុងពេលដែលគេចាប់ឃុំឃាំងរបស់លោកស្រី រហូតដល់ពេលលោកស្រីបានចេញ ចាកចេញពីកន្លែងឃុំឃាំងនោះ ត្រឡប់មកជីវភាពប្រក្រតីឡើងវិញរហូតដល់ថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ តើលោកស្រីបានជួបប្រទះនូវបញ្ហាយ៉ាងម៉េចខ្លះចំពោះ ខ្លួនរបស់លោកស្រីផ្ទាល់?

[១១:៣៨:២៩]

**ឆៈ** ចាស, លោកប្រធាន ។ មុនពេលដែលគេចាប់ខ្លួននាងខ្ញុំ គេតាមដានប្រវត្តិរូបយើងសិន តាមដានប្រវត្តិរូបយើងចុះឡើងពីខេត្តមកអង្គភាពវិញ ពីអង្គភាពទៅខេត្ត គេតាមដានទៅ គេដឹងថាខ្ញុំ ឪពុកធ្វើការនិន្នាការរដ្ឋការចាស់ ជាមន្ត្រីរាជការពីដើម ។ ហើយគេសួរយើង គេធ្វើប្រវត្តិរូបយើង គេថតយើង ថតមួយដងជាពីរដង ក៏ខ្ញុំមិនដែលយកចិត្តទុកដាក់អីទេ ព្រោះវាកន្លងមកវាចេះតែបាត់មនុស្សអស់ហើយ ។ ដល់តែពេលក្រោយមកគេចាប់នាងខ្ញុំហ្នឹង នៅថ្ងៃទី១០ ខែ១១ហ្នឹង នៅវេលាយប់ទៅ នាងខ្ញុំនឹកឃើញថា ពេលដែលគេហៅទៅកសាងមួយដងជាពីរដងហ្នឹង មុខជាថ្ងៃណាពេលវេលានឹងដល់ខ្ញុំហើយ ព្រោះគេបាត់ខ្លួនអស់ហើយពីមុនមក អំ!អ្នកមុនៗ ។ ដល់ពេលគេចាប់នាងខ្ញុំហើយ គឺខ្ញុំកំពុងលីស្រូវហ្នឹង គេសួររកឈ្មោះ មិត្តម៉េត សួររកឈ្មោះនាងខ្ញុំហើយ គេថា នោះ មិត្តម៉េត លីស្រូវទៅលើ

ហើយទៅដាក់ជាន់លើហើយ ។ ខ្ញុំចុះមកវិញ សួរថា ហៅខ្ញុំមានការអីបង មិត្តយុវជនពីរនាក់នុ៎ង បានប្រាប់ខ្ញុំថា មិត្តម៉េត មិត្តឯងបង វិន ឲ្យហៅ ។ បងវិន ហ្នឹងគាត់ប្រធានកងពលថ្មី ទើបតែមកឈរនៅថ្មី គាត់មកពីខាងភូមិភាគនិរតី គាត់ទៅគ្រប់គ្រងនៅភូមិភាគឧត្តរយើងនៅកងពលទី៣ហ្នឹង ។ ទៅខ្ញុំក៏បុកពោះ ភ័យៗ នឹកឃើញថា ពេលនេះច្បាស់ជាគេចាប់អញយកទៅសម្លាប់ដូចអ្នកមុនៗហើយ ។ នាងខ្ញុំចាប់ផ្តើមដូចថា មានការប្រតិកម្មខ្លះ កណ្តាលអធ្រាត្រហើយ គេមកហៅ ។ ពេលនោះនាងខ្ញុំ គេថាទៅ ឡើងឡានទៅ ទៅផ្ទះបង វិន ផ្ទះបង វិន ហ្នឹងនៅជាប់គល់ស្ពានជ្រោយចង្វារហ្នឹង ។ ដល់ពេលជិះឡានមកគីឡូលេខ៦ មកដល់ផ្ទះបង វិន ហ្នឹងចូលក្នុងផ្ទះទៅអត់មានមនុស្សស្ងាត់ឈឹងៗ ទៅ ខ្ញុំសួរថា បងវិន ហ្នឹងគាត់ទៅណា? គាត់ហៅខ្ញុំមានការអីកណ្តាលយប់អាធ្រាធអ៊ីចឹង អឺ! មិត្តពីរនាក់គេអត់និយាយអត់អីទេ គេថាអង្គុយចាំគេបន្តិចទៅ ក្រែងលោកគាត់មក គាត់ជាប់ប្រជុំ ជាប់ការងារហ្នឹង ។ ខ្ញុំអង្គុយចាំឡើងងោក អត់ឃើញៗ ដឹងជាគេនិយាយគ្នាម៉េចទៀតទេ គេថាណាស់ហើយតោះ ទៅកន្លែងតែម្តងទៅៗគេក៏បានចាប់ខ្ញុំចូលក្នុងឡាន ហើយគេចង ចងដៃហើយគេបិទភ្នែកទៀត គេចងភ្នែកទៀត។ ខ្ញុំចាប់ផ្តើមភ័យមែនទែន ហើយគេអ្នកចាប់ហ្នឹង មានតែកុងឡានមួយ គេបើកឡានហើយ សន្តិសុខពីរនាក់ ហើយគេយកដាក់ឡានមក គេបើកមក មិនបើកទៅណាទេ ព្រោះជិតភ្នែកអស់ហើយ យើងមើលអត់ឃើញ ព្រោះខ្ញុំ មុខព្រួញ មុខសញ្ញាខ្ញុំ ខ្ញុំស្គាល់តែត្រឹមស្ពានជ្រោយចង្វារ គីឡូលេខ៦ រហូតដល់ព្រែកព្នៅ វត្តគ្រួស ហើយនិងទួលគោក ។ អាហ្នឹងមុខសញ្ញាអង្គភាពខ្ញុំរហូតទៅខាងពោធិចិនតុង ជម្ពូវ័ន្តយើងហ្នឹង កន្លែងមកទីក្រុងភ្នំពេញទៀត ពួកខ្ញុំមិនដែលបានចូលទេ ។

[១១:៤១:៣៤]

ដល់ពេលមកដល់ ចូលមន្ទីរឃុំឃាំង គេបញ្ចូលយើងនៅក្នុងបន្ទប់ គេស្រាយភ្នែកយើង តែចំណងគេនៅចងដដែល ពេលខ្ញុំចូលទៅដល់បន្ទប់ ឃើញមិត្តនារីខ្ញុំមកពីកងហ្នឹងគេនៅខាងទួលគោក គេនៅធ្វើស្រែនោះ មិត្តមឿន និងមិត្តយ៉ាត ធ្លាប់នៅជាមួយគ្នាក្នុងកងហ្នឹង ។ ដល់មកដល់ឃើញគ្នាយំៗ ដាក់គ្នាទាំងអស់គ្នាទៅថា អត់ដឹងមានរឿងហេតុអី បានជាគេចាប់មក ហើយសួរថា តើកន្លែងនេះជាកន្លែងអី? មិត្តពីរនាក់ហ្នឹងបានថា មិត្តឯងមិនបាច់និយាយ មិនបាច់មាត់អីទេ នៅឲ្យស្ងៀមទៅ ចាំស្តាប់សំណួររបស់គេសួរយើង ។ ទៅខ្ញុំក៏អត់មាននិយាយទាំងអស់គ្នានាំគ្នាយំទាំងអស់គ្នាក្នុងមន្ទីរឃុំឃាំងនុ៎ងតែដៃជាប់ចំណងទាំងអស់គ្នា ។

រហូតដល់ថ្ងៃទី៣ គេក៏ហៅនាងខ្ញុំទៅសួរ សួរហើយគេហៅចេញក្រៅ គេសួរហើយគេចងភ្នែក

យើងជិត ហើយបណ្ដើរទៅសួរហ្នឹងមិនដឹងបន្ទប់ណា មិនដឹងកន្លែងណា អត់ដឹង អត់ស្គាល់ទេ ហើយសួរសំណួររបស់គេហ្នឹង គេសួរយើងថា តើធ្លាប់បានចូលរួមនឹងការអប់រំបំពាក់បំប៉នអំពីខ្សែ *សេអ៊ីអា, កាហ្សេបេ* ដែរទេ? នាងខ្ញុំរកនឹកមិនឃើញសោះ ព្រោះពេលនោះពួកនាងខ្ញុំមិនដែលបានចូលប្រជុំសម្ងាត់ មិនដែលបានចូលកន្លែងណាក្រៅពីកន្លែងធ្វើស្រែ បាចទឹក បាចស្នាចដាក់ស្រែ ធ្វើជី ទៅប្រជុំធំៗមានតែមេៗទេ ឯយើងយុទ្ធនារីមិនដែលបានទៅប្រជុំឯណាទេ បើប្រជុំមានតែប្រជុំជីវភាព កសាងគ្នា ដាស់តឿនគ្នា ក្នុងការធ្វើការងារ ដើម្បីយកស្នាដៃរៀងៗខ្លួនតាមកង ។ មួយដងជាពីរដង គេសួរចម្លើយ គេធ្វើទារុណកម្ម ហើយពេលនោះខ្ញុំហ្នឹងភ័យពេក មិនបាច់ចាំវ៉ៃខ្លាំងទេ គេវ៉ៃល្មមៗក៏ខ្ញុំ សន្លប់បាត់ហើយភ័យពេក គេក៏យកមកទុកចោលវិញមក ។

ក្រោយមកទៀតសួរទៀត រយៈដប់ប្រាំថ្ងៃហ្នឹង គេសួរបីដង សំណួរតែងដែលៗហ្នឹង នាងខ្ញុំក៏មិនមានសំណួរអីឆ្លើយប្រាប់គេទេ ។ រហូតដល់ថ្ងៃទី១៥ ទី១៦ហ្នឹង គេក៏បានបញ្ជូននាងខ្ញុំមកដាក់ឡានវិញ ហើយចេញទៅក្រៅវិញ មិនដឹងចេញទៅណា នាងខ្ញុំថា ប្រហែលជាគេយកទៅសម្លាប់ហើយពេលនេះ ព្រោះយប់ឡើងដេកក្នុងបន្ទប់ នៅខាងបន្ទប់ទៅឮតែសំឡេងថ្ងូរស្រែកយំ ស្រែកឲ្យជួយ ទៅខ្ញុំមើលរកមើលវាមិនឃើញ ព្រោះបន្ទប់ហ្នឹងគេបិទជិតអស់ បង្អួច ទ្វារ អីគេចាក់សោរខាងក្រៅទៀត ឮតែស្នូរសំឡេងរងំ តែអត់ដឹងថាមន្ទីរឃុំឃាំងហ្នឹងជាទួលស្លែង ឬក៏ជាស-២១ ហ្នឹង ខ្ញុំអត់ស្គាល់ទេ គ្រាន់តែបានចូលមន្ទីរឃុំឃាំងហ្នឹង ក្នុងអគារហ្នឹងមានរាងបណ្ដោយថ្ងៃ ហើយខ្ញុំនៅក្បែរជណ្ដើរទៀត ខ្ញុំចាំបាន រយៈពេលដប់ប្រាំថ្ងៃ ដប់ប្រាំយប់ ។ ពេលដែលគេបញ្ជូននាងខ្ញុំមក ដាក់ឡានមក មកទាំងបីនាក់មិត្តមឿន មិត្តយ៉ាត មិត្តនារីនៅក្នុងកងជាមួយគ្នាហ្នឹង គេបញ្ជូនមក មកដល់កន្លែងកង១៧ ហ្នឹង មានបងស្រីប្រធានក្រុមម្នាក់រត់មកទទួលពួកនាងខ្ញុំពីលើឡាន មកដល់ឡានស៊ីផ្លេ "តេតៗ" ហើយគេឲ្យយើងចុះពីលើឡាន គេស្រាយចំណងដៃហ្នឹង ស្រាយភ្នែកទាំងអស់ថា មិត្តនារីឯងនៅហ្នឹងហើយ នៅមានគេមកទទួលហើយ ។ ពេលនោះបងស្រីមកទទួល ហើយចុះឈ្មោះ ធ្វើប្រវត្តិរូបយើង ចុះឈ្មោះ សួរឈ្មោះអីៗរួចអស់ហើយ គេក៏បញ្ជូននាងខ្ញុំទៅនៅហ្នឹងផ្ទះគេហើយ គេប្រគល់ចប ប្រគល់ប៉ែល ឲ្យយើងពូនរងដំឡូង ។ អត់មានឲ្យសម្រាកទេ ចាប់ផ្ដើមពលកម្មតែម្ដង ។ ហើយនាងខ្ញុំឃ្លានបាយអើយឃ្លាន ព្រោះយើងអត់បាយនៅក្នុងមន្ទីរឃុំឃាំងហ្នឹង គេឲ្យបបរហូបដែរ តែហូបអត់ចូល ព្រោះវានឹកឃើញតែចាំថ្ងៃស្លាប់ ។ តែយើងទាំងបីនាក់ហ្នឹងបាននិយាយគ្នាថា បើសិនជាស្លាប់ ស្លាប់ទាំងអស់គ្នា ព្រោះកាលដែលយើងនៅសមរភូមិ គឺយើងបានតស៊ូប្ដូរផ្ដាច់ទាំងអស់គ្នា ។

**ស៖** ជិន ម៉េត អាចរំងាប់អារម្មណ៍ ពង្រឹងស្មារតីបន្តិច ហើយឥឡូវនេះ គិតមើលថាតើអាចនិយាយរៀបរាប់បន្តទៀតបានទេ? ឬក៏សុំអង្គជំនុំជម្រះសម្រាកសិន ដើម្បីឱ្យបន្ធូរអារម្មណ៍?

**ឆ៖** ចាស, លោកប្រធាន! ពេលដែលខ្ញុំទៅរស់នៅនឹងកន្លែងកង១៧ហ្នឹងបានតែបីថ្ងៃៗ មិត្តមឿន និងមិត្ត យ៉ាត ហ្នឹងបាត់ខ្លួនរហូត ពេលនោះខ្ញុំបានសួរបងប្រធានហ្នឹង បងឈ្មោះបងញ៉ៅ ប្រធាននារីហ្នឹង សួរថាបងប្អូនខ្ញុំពីរនាក់ហ្នឹងមក ទៅណាហើយអត់ឃើញ ។ គេក៏ប្រាប់ថា គេទៅនៅកងផ្សេង មិត្តឯងម៉េចចេះដឹង និយាយច្រើនម្ល៉េះ សួរច្រើនម្ល៉េះ ។ នាងខ្ញុំយំរហូត ព្រោះកាលទៅមានតែគ្នាបីនាក់ អត់មានស្គាល់នរណាទាំងអស់នៅក្នុងកង១៧ហ្នឹង ។

**ស៖** ម៉េចទៅ អាចបន្តបានទេ ឬក៏សម្រាក សុំសម្រាកត្រឹមនេះសិន ចាំបន្តទៅរសៀល? អាចបន្តទៀតបានទេ ឬក៏សុំសម្រាក?

**ឆ៖** សុំបន្តបន្តិច ។ ពេលដែលបាត់ពួកមិត្តមឿន មិត្តយ៉ាត អស់ហើយ នាងខ្ញុំក៏រស់នៅជាមួយកងនារីនៅក្នុងកង១៧ហ្នឹង គេបញ្ចូលជាក្រុម នៅក្រុមបីៗពេលនោះ ឱ្យតែពេលម៉ោងពីរឡើងគេដាស់ឱ្យក្រោក បងៗនារីប្រធានកងហ្នឹងដាស់ឱ្យក្រោក ។ ក្រោកហើយតម្រង់ជួរទាំងយប់ហ្នឹង ម៉ោងពីរកន្លះម៉ោងបីចេញដំណើរឡើងទៅស្ទូងខែហ្នឹង ក្នុងខែរដូវស្ទូងដក ហើយនាងខ្ញុំរស់នៅធ្វើការងារហ្នឹងគឺថាវេទនាជាងស្លាប់ទៅទៀត ព្រោះកន្លែងលត់ដំហ្នឹង ហូបអត់ឆ្អែតហ្នឹង ខ្ញុំរស់នៅបានតែដប់ថ្ងៃទេ ក្តិតនាងខ្ញុំឡើងស្រួចដូចដូងទុំ ខំធ្វើការទាំងយប់ទាំងថ្ងៃដើម្បីកសាងខ្លួន ។ ហូបមិនដែលឆ្អែត ពេលហូបបាយម្តងៗថ្ងៃ ម៉ោងដប់មួយថ្ងៃត្រង់ គេយកបាយទៅឱ្យពួកមិត្តនារីមុនៗគេមានបទពិសោធន៍ ខ្ញុំទៅក្រោយគេអត់សូវមានបទពិសោធន៍ ។ គេហូបបាយមួយចាន អ៊ំ!បបរហ្នឹង គេដួសក្នុងដប់ពីរនាក់ហ្នឹងវាគវង់ជាក្រុម ហើយកាន់ចានស្លាបព្រាស្រេច គេដាក់បបរមួយវែកៗឱ្យគ្រប់ចានទាំងអស់ ហើយរៀបដាក់សម្លមួយចាន់ធំប៉ុណ្ណេះ ហើយបងស្រីគាត់ធ្លាប់មានបទពិសោធន៍នៅក្នុងក្រុមចាស់ៗហ្នឹង ខ្លះគាត់បេះបានម្អម ខ្លះគាត់បេះបានផ្កា ត្រកួនខ្មោច ផ្កាស្នោ ផ្កាអីហ្នឹង ពេលដែលគាត់ធ្វើការ ហើយគាត់ដើរទៅបត់ជើងអី គាត់បេះហោប៉ៅអាវ ហោប៉ៅខោមក ពេលហូបបាយ ខ្ញុំឃើញគេហ្នឹងបេះអាអស់នោះឯងដាក់ក្នុងចាន ហើយគេហូប ពេលនោះពួកយើងហូបបាយ អ៊ំ!ហូបបបរហ្នឹង ចុកបាយ ចុកបបរតែមួយម៉ាត់ទេ តែហុតសម្ល ខ្លះហុតដល់ដប់ម៉ាត់ ម្ភៃម៉ាត់ ដើម្បីយកទឹកសម្លនោះចម្អែត ហើយខ្ញុំថ្មីថ្មោងទៅក្រោយគេ ខ្ញុំអត់ដឹង ខ្ញុំរឹតហូបបបរទាល់តែអស់ សុំគេទៀត គេថាអត់មានរបបមានតែប៉ុណ្ណឹង ។ ទៅនាងខ្ញុំដឹង តាំងពីនុ៎ងមកនាងខ្ញុំដឹង មានបទពិសោធន៍ហ្នឹង ខ្ញុំធ្វើតាមដូចគេ ។ ពេលនោះយើងទាំង

អស់គ្នាមានការទ្រុឌទ្រោមយ៉ាងខ្លាំង ម្នាក់ៗខ្លះធ្វើស្ទូងស្រូវ សន្ទូបកណ្តាលស្រែក៏មាន ខ្លះដកសំណាប អីចឹង ដួលសន្លប់ក៏មាន យូរៗទៅក្នុងកងហ្នឹងបាត់បង់មនុស្សកាន់តែម្តងបន្តិចៗរហូតក្នុងកងហ្នឹងអស់ អ្នកចាស់ ។ រំលងបានប្រហែលបួនប្រាំថ្ងៃមានអ្នកថ្មីមកមួយឡានពីរឡានទៀត គេរៀបចំជាក្រុម ជាកងឱ្យទៀតមានគ្នាកាន់តែច្រើនឡើង ។ នៅធ្វើការយូរៗទៅបានប្រហែលជាបួនដប់ថ្ងៃបាត់មនុស្សនោះអស់ទៀត ។ ពួកនាងខ្ញុំចេះ តែឆ្ងល់ តែអត់ប៊ានសួរគេទេ ព្រោះមានបទពិសោធន៍មុនហើយ ។ ដល់ក្រោយមកទៀតនាងខ្ញុំទ្រុឌទ្រោមខ្លាំង នៅថ្ងៃមួយហ្នឹងមេកងខ្ញុំបានចាត់នាងខ្ញុំថា ក្រុមមិត្តម៉េត បួននាក់មកនេះ ។ នាងខ្ញុំក៏ទៅ ថាទៅធ្វើអីបង! តែគេថាមិត្តឯងគ្នាបួននាក់ហ្នឹងទៅសាបស្រូវ ទៅធ្វើថ្នាលសំណាប ធ្វើថ្នាលសំណាបទៅ ដល់គេឱ្យអូសនង្គ័ល គ្រាន់តែឱ្យអូសនង្គ័ល ពួកនាងខ្ញុំធ្លាក់ទឹកចិត្ត គ្នាបួននាក់ ម្នាក់អ្នកភ្ជួរ ពីរនាក់សង ខាងអូសនង្គ័ល ពេលនោះ តែបានដីស្រែហ្នឹងគេភ្ជួររួចម្តងស្រេចហើយកូនពកហ្នឹងគេឱ្យយើងធ្វើថ្នាលសំណាប ។ អូសតែបានពីរបីជុំ មិត្តនារីម្នាក់ហ្នឹងគាត់ឈឺផង ហើមជើងផង ទឹករោលហ្នឹង គាត់ដួលទៅ ដូចទាញយឺតខាងនាងខ្ញុំមកដួលទាំងអស់គ្នាទៅ ចៃដន្យអីពូដែលគាត់កាន់នង្គ័លហ្នឹង គាត់វ៉ៃម៉េច វ៉ៃមិត្តដែលដួលហ្នឹងសន្លប់ប្រកាច់ត្រង់ជើង នាងខ្ញុំភ័យខ្លាចពេក សំពះលូនសុំអង្វរទោសគេ អង្វរកគេម៉េច គេមិនព្រម គេដាក់ទាំងអស់គ្នាមក ពេលនោះពួកយើងទ្រុឌទ្រោមខ្លាំងនៅលើភ្លឺស្រែហ្នឹង សន្លប់ទាំងអស់គ្នា ហើយគេថាយើងធ្វើការគ្មានបានការទេ ធ្វើការប៉ុណ្ណេះធ្វើមិនកើត ។ ពេលនោះពួកនាងខ្ញុំឃើញបងស្រីម្នាក់ហ្នឹងនៅសន្លប់ស្ដូកស្ដឹងនៅភ្លឺស្រែ ពួកនាងខ្ញុំយំទាំងអស់គ្នា ឱបគ្នាហ្នឹង គេក៏បានអូសបំបែកយើងទាំងអស់ឱ្យមកក្រុម មកកងវិញ ។ ដល់ក្រោយមកទៀត គេឈប់ឱ្យទៅភ្ជួរស្រែ គេឱ្យទៅលើកទំនប់ ជីកប្រឡាយ លើកទំនប់ ជីកប្រឡាយ ពេលក្រោយពីសម្រាកឡើង ឧទាហរណ៍យើង ត្រូវលើកទំនប់ ត្រូវមានសម្ភារៈអីខ្លះ មានចប មានបង្គី មានដងវែក មានពូថៅសម្រាប់កាប់គល់ដែលវាទើសនៅតាមប្រឡាយហ្នឹង ។ ពេលនោះ ក្រុមនាងខ្ញុំទាំងអស់គ្នាហ្នឹងសកម្មប្រយុទ្ធខ្លាំងណាស់ព្រោះខ្លាចស្លាប់ ។ ម្នាក់ៗតាំងចិត្តថា ទោះបីជាយើងស៊ីមិនឆ្អែតក៏ដោយ ដើម្បីជីវិតយើងម្នាក់ៗយើងត្រូវតស៊ូ ពួកមិត្តអើយខ្ញុំនិយាយផង យំផងទាំងអស់គ្នា តែខ្ញុំវាខ្សោយពេក ព្រោះខ្ញុំវាមុននឹងគេ អ្នកមុនស្លាប់ហើយ នៅខ្ញុំ នៅអ្នកថ្មី ។ ដល់ពេលខ្ញុំរែកដីមិនរួច ខ្ញុំដួលសន្លប់ គេវ៉ៃខ្ញុំថែមទៀត ។

**សះ** ប៉ុណ្ណឹងសិនបានហើយ។ ឥឡូវនេះ ក៏ដល់ម៉ោងត្រូវពិសាអាហារថ្ងៃត្រង់ហើយដែរ អង្គជំនុំជម្រះប្រកាសសម្រាកពិសាអាហារថ្ងៃត្រង់ ហើយមុននឹងសម្រាក អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់

ចំពោះសាធារណជនដែលបានអញ្ជើញចូលរួមនៅក្នុងដំណើរការស្តាប់សវនាការផ្ទាល់នៅក្នុងសាលសវនាការនេះ អង្គជំនុំជម្រះបានកតសម្គាល់ឃើញថា ប៉ុន្មានថ្ងៃចុងក្រោយនេះ ហាក់ដូចជាមានបញ្ហាមិនមានសណ្តាប់ធ្នាប់នៅក្នុងការចូលរួម ដោយការចូលមកក្នុងកសាលសវនាការ មិនបានមុន ពេលអង្គជំនុំជម្រះចូលទេ អង្គជំនុំជម្រះបានកំណត់ម៉ោងជាក់លាក់ហើយ ប៉ុន្តែដល់ពេលអង្គជំនុំជម្រះ ចូលមកគឺសាធារណជនឃើញបន្តហូរហែមក១៥មីនុតក្រោយមកចូលមិនទាន់អស់ផង ។ អ៊ីចឹងរបៀបរបបនេះត្រូវរៀបចំឡើងវិញ ឲ្យមានមនសិការដោយខ្លួនឯង ដើម្បីគោរពពេលវេលា ហើយ អញ្ជើញចូលឲ្យបានមុនម៉ោងកំណត់ដែលអង្គជំនុំជម្រះបានជម្រាបជូនដំណឹងជាមុន ។

ទីពីរ បុគ្គលិកមន្ត្រីតុលាការដែលទទួលបន្ទុកកិច្ចការសម្របសម្រួល សូមរៀបចំលៃលកបញ្ហានេះឲ្យបានល្អ ហើយបើជួបប្រទះនូវបញ្ហាណាដែលវាមានបញ្ហាមិនច្បាស់លាស់អំពីពេលវេលា ឬក៏មូលហេតុអ្វីដែលនាំឲ្យមានការយឺតយ៉ាវក្នុងការវិលចូលមកក្នុងកាន់សាលសវនាការនោះ សូមពាក់ព័ន្ធជាមួយនឹងមកខ្ញុំផ្ទាល់ ឬក៏ជាមួយនឹងមន្ត្រីទទួលបន្ទុកទូទៅ នៃការរៀបចំសណ្តាប់ធ្នាប់នៅទីនេះ ដើម្បីរៀបចំឲ្យបានល្អ មិនអាចបណ្តែតបណ្តោយឲ្យសភាពការណ៍ដូចនេះនៅបន្តទៀតបានទេ ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកពិសាអាហារថ្ងៃត្រង់ ហើយអង្គសវនាការនឹងចាប់បន្តនៅរសៀលនេះ ចាប់ពីម៉ោងមួយ និងសាមសិបនាទីទៅ ។

ហើយមន្ត្រីតុលាការសម្របសម្រួលដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដើម្បីគាត់បានទទួលនៅកន្លែងសម្រាកសមរម្យ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់សម្រាកនោះវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីរសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង១១:៥៧ ដល់ម៉ោងម៉ោង ១៣:៣៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជិន ម៉េត តទៅទៀត ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ជិន ម៉េត ហើយឃើញថាមានស្ថានភាពល្អប្រសើរជាងព្រឹកមិញ ។ ហើយព្រឹកមិញដោយសារមានការរន្ធត់ចិត្តខ្លាំងផង ហើយជិតដល់ម៉ោងផង អង្គជំនុំជម្រះបានសម្រេចសម្រាកមុនម៉ោង

កំណត់ ។ ហើយឥឡូវនេះ តើលោកស្រីអាចនិយាយរៀបរាប់ អំពីហេតុការណ៍នានាដែលលោកស្រីបាន ជួបប្រទះជាបន្តទៀតនៅក្នុងជីវិតរបស់លោកស្រី ដែលបានរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ រហូតដល់ពេលលោកស្រីបានវិលមកក្នុងជីវភាពស្ថានភាពធម្មតាឡើងវិញ ។

លោកស្រីចាប់បន្តពីព្រឹកមិញ ។

**ឆ៖** ចាស, លោកប្រធាន ។ នៅពេលចូលឆ្នាំ១៩៧៨ នៅក្នុងកង១៧ នាងខ្ញុំហ្នឹង គេបានចាត់តាំងឲ្យទៅធ្វើស្រែ ធ្វើស្រែហ្នឹង យើងដើរធ្វើគ្រប់កន្លែងទាំងអស់ តាំងពីវត្តក្រពើហារ វត្តស្ដែង វត្តច្រើនវត្តណាស់ នាងខ្ញុំស្គាល់មិនអស់ទេ ។ ពេលនោះ ពួកកងនាងខ្ញុំហ្នឹង គឺត្រៀមសម្រាប់ប្រដាប់ប្រដាធ្វើស្រែហ្នឹងមានចប មានបង្គី មានឈើច្រាន ដងរែក សង្រែកសម្រាប់រែកកណ្ដាប់ ។ មុនពេលដែលធ្វើដំណើរទៅចេញទៅធ្វើការ ពេលសម្រាកយើងសម្រាកម៉ោងប្រាំ ម៉ោងប្រាំមួយ ជួនសម្រុកធ្វើការខ្លាំងទៅម៉ោងប្រាំបួនដល់ម៉ោងដប់ ។ ហើយពេលដែលក្រោក ម៉ោងពីរ, ពីរកន្លះ ឡើងមេដាស់ ប្រធានកងដាស់ឲ្យហៅ អំហៅតាមក្រុមនីមួយៗឲ្យក្រោកឡើងដើម្បីលុបមុខ រៀបចំសម្ភារៈសម្រាប់ធ្វើពលកម្មហ្នឹង តាមក្រុមនីមួយៗ គឺត្រៀមតម្រង់ជួរតាមគេ ជួនទម្រាំក្រុមគេផ្សេងទៀត ជុំគ្នាយើងអង្គុយចាំគេឡើងចង់ងោកម្នាក់ៗ ។ ហើយជួនពេលយប់ណា ថ្ងៃណាហ្នឹងនៅក្នុងកន្លែងក្រុមនីមួយៗហ្នឹង នៅតាមផ្ទះហ្នឹងគេមានបាត់ បាត់ដូចជាបាត់ ផ្លែខ្នុរ បាត់ផ្លែចេក ឬផ្លែល្ហុងទុំអី បងប្រធាននារីនៅគ្រប់គ្រងហ្នឹងគាត់ដើរថើបមាត់យើងនារីៗទាំងអស់គ្រប់ក្រុមតែម្ដង ។ គាត់ដើរថើបដើរហិតមាត់យើង បើសិនជានរណាម្នាក់មានក្លិន ក្លិនផ្លែឈើហ្នឹង គេនឹងយកទៅគេអត់ដឹងយកទៅណាទេ គេថាយកទៅអប់រំ បាត់ខ្លួនទៅ ។ ហើយពួកខ្ញុំដែលនៅធ្វើហ្នឹង ខំធ្វើការ ។ ចេញដំណើរម៉ោងបី បើកន្លែងឆ្ងាយៗ ដើរទល់ម៉ោងបួន ម៉ោងប្រាំ បានដល់កន្លែងធ្វើការ ។ ខ្លះដើរងោកធ្លាក់ទឹកប្រឡាយ ខ្លះទៀតឈឺជើងដើរមិនរួចហើមចេញទឹក ។ ពេលដែលធ្វើស្រែទឹកវារោលទៅ កាលណាគេប្រើជីធម្មជាតិច្រើនទៅ ទឹកហ្នឹងវាទៅជារោលជើង មិត្តនារីយើងទាំងអស់គ្នាហ្នឹង ។ មិត្តនារីខ្លះហើមជើង ឡើងប្រេះចេញទឹក ចេញឈាមទៅអត់រួចគេរើបង្ខំ ។

[១៣:៣៨:៣៨]

ហើយបើចំពោះខ្លួននាងខ្ញុំវិញ នៅក្នុងក្រុមនាងខ្ញុំ ខ្លះទៀត កើតថៃចេញពីក្នុងខ្លួនតែម្ដងរមាស់ត្រង់ណាអេះទៅចេញថៃមក ។ ហើយនាងខ្ញុំវិញនៅក្នុងកន្លែងហ្នឹង រយៈពេលកន្លះឆ្នាំ ។ ខ្លួននាងខ្ញុំមើលមិនយល់ទេស្គមនៅស្បែកនិងឆ្អឹង ហើយមុខនាងខ្ញុំកើតសុទ្ធស្រែងទាំងអស់ សុទ្ធស្រែង មើលមុខមើល

អត់ស្គាល់ទេ ។ បើបងប្អូនដែលធ្លាប់ស្គាល់ខ្ញុំ គេថាយើងនឹងវាជិតស្លាប់ហើយ វានៅតែថ្ងៃស្លាប់ហ្នឹង ។ ហើយពេលធ្វើការយើងខំស្ទូងក្នុងស្រែ ស្ទូងស្រូវគេចែកមុខសញ្ញាគ្នា ឲ្យស្ទូងចែកជាក្រុម ។ ដំបូងគេមានបទពិសោធន៍ឲ្យយើងធ្វើក្នុងមួយហិចតាគេដាក់មួយក្រុមហ្នឹងប្រាំនាក់ឲ្យធ្វើបាន ។ ពេលនោះ ពួកនារីខ្ញុំទាំងអស់គ្នា ធ្វើទៅមិនរួចទេ លោកប្រធានអើយ ។ ណាមួយខ្លួនស្គមស្គាំង ណាមួយឃ្លានអាហារ ណាមួយទៀតជើងដៃហ្នឹងវាកើតរមាស់ទឹករោល ឈឺ ស្ទូងផង ខ្លះអុកគូទនៅហ្នឹងទឹក តែចេះតែខំប្រឹង ព្រោះមានមេក្រុមមួយគេឈរមើលពីលើ ហើយគេឲ្យយើងស្ទូងជារបៀបក្រឡាឈើត្រង់អ៊ីចឹង ហើយនិងស្ទូងហ្នឹង មានបច្ចេកទេសគេតាមដានយើងទៀត ដូចថា មុខចាប់ផ្ដើមមុខខ្ញុំទីមួយ ទីពីរ ទីបី ហ្នឹងក្រុមយើងហ្នឹង ។ តាមដានមើលសន្ទូងហ្នឹងលាស់ទៀត រយៈពេលមួយអាទិត្យទៅដប់ថ្ងៃកាលណាមុខមិត្តនារីណា ដែលស្ទូងហើយស្រូវហ្នឹងវាលាស់ វាអត់លាស់ វារាងក្រហម គេថាយើងហ្នឹងខ្លាំង ស្ទូងច្បត់គល់ស្រូវអត់ឲ្យលាស់ដើម្បីបំផ្លិចបំផ្លាញរបស់បក្ស ។ ដូច្នេះ ពួកនាងខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង ព្រោះនៅពេលធ្វើការហូបមិនឆ្អែត ពេលហូបបាយមិនដែលមានបាយទេ មានតែបបរ ។ បបរសម្រេចតែថា មួយវែកក្រឡមហ្នឹង គោះឃ្លោកដាក់ចាន ហូបបបរមួយម៉ាត់ ហូបសម្លប្អូនដប់ម៉ាត់ ។ ពេលដែលហូបរួច អង្គុយសម្លឹងមើលមាត់គ្នា ធ្មេញម្នាក់ៗឡើងខ្មៅក្រិប មាត់ម្នាក់ៗខ្មៅក្រិប មិនដឹងជាជាតិស្អីសម្លម្ជូបហ្នឹង ។ ពេលនោះហើយអារម្មណ៍មិត្តនារីយើងទាំងអស់គ្នា មានការភ័យខ្លាចយ៉ាងខ្លាំង ។ ធ្វើការទាំងបង្ខំ មិនមានសិទ្ធិអ្វីទាំងអស់ ពេលឈឺគ្មានថ្នាំពេទ្យគ្រប់គ្រាន់ ។ មានថ្ងៃមួយពួកនាងខ្ញុំភ័យពេក នៅក្នុងក្រុមខ្ញុំមានបួននាក់មួយពួកហ្នឹង គេរៀបជាពួកក្នុងមួយក្រុមមានបីពួក ។ នាងខ្ញុំបួននាក់ហ្នឹង បានសម្រេចចិត្តនិយាយគ្នាថា យើងបើសិនពិបាកពេក យើងនាំគ្នាទៅសម្លាប់ខ្លួន ។ ពេលនោះមានមិត្តនារីម្នាក់ហ្នឹង គេបានថា ជីវិតជាការតស៊ូយើងមិនត្រូវចេះតែនឹកឃើញចង់សម្លាប់ខ្លួនទេ ព្រោះជីវិតយើងនៅវែងឆ្ងាយណាស់ ។

[១៣:៤២:១១]

នាងខ្ញុំពីរនាក់ឈ្មោះ បង គានៗ គាត់កើតឫសដូងច្រមុះ ទៅគាត់ថា មិត្តម៉េត មិត្តឯងតាមខ្ញុំទៅវត្តក្រពើហា គេឲ្យជម្រះស្មៅ មិត្តមេក្រុមខ្ញុំឲ្យជម្រះស្មៅនៅក្នុងវត្ត ដើម្បីដាំដំឡូង ។ រួចគេថា ដើមកន្ទួតហ្នឹងពូកែណាស់ កាលណាស្ងោរសំបកកន្ទួតមក បុកឲ្យល្អិតហើយដាក់ត្រាំទឹក បើសិនជាឆ្អែតវិញគេឲ្យផឹកតែពីរបីលិតហ្នឹង វាលិតតែពីរបីរដងហ្នឹង មួយម៉ោងក្រោយមក វាអាចនឹងស្លាប់ ។ ពេលនោះពួកនាងខ្ញុំពីរនាក់ហ្នឹង បានសហការគ្នាថា បើសិនជារស់នៅទៅទៀត ក៏យើងវេទនា ពិបាកនឹងការរស់

នៅ នឹងការស៊ីចុកគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់ ។ ខ្ញុំ និងបងគាន បានសម្រេចចិត្ត យកចប ចបកាប់ ហ្នឹងស្មោះសំបកកន្ទួត ហើយយកមកត្រាំល្អួចដាក់ត្រាំ ដាក់ក្រោមគ្រែដេក ។ ពេលយប់ប្រហែលជាម៉ោងពីរ ពួកនាងខ្ញុំទាំងពីរនាក់ហ្នឹង ផឹកៗឡើងឆ្អែតទាំងពីរនាក់ ហើយដេកទទូរភ្នួយ ថាចាំស្តាំមើលតើវាស្លាប់ ឬវាយ៉ាងម៉េចពេលណា? តែជាចៃដន្យលោកប្រធាន ពេលដែលខ្ញុំទាំងពីរនាក់ហ្នឹង ដេកលើគ្រែតែមួយពីរនាក់ហ្នឹង ហូបទឹកហ្នឹងទៅវាមិនស្លាប់វាបែរវាមានកម្លាំងទៅវិញ ។ ដល់ម៉ោងគេហៅទៅធ្វើការទៀត ដល់ម៉ោងពេលភ្លឺទៅធ្វើការទៀត ទៅទៀតហើយ ទៅធ្វើការទៀត យើងនឿយហត់ណាស់ពេក ព្រោះវាសម្រាកបានតិច ស៊ីមិនឆ្អែត ។

មានថ្ងៃមួយ នាងខ្ញុំដើរឆ្លងប្រឡាយទៅ ធ្លាក់ទឹកប្រឡាយទៅ មេគេហ្នឹងបានអូសនាងខ្ញុំច្រាសជើង ។ អូសនាងខ្ញុំច្រាសជើងពីទឹកប្រឡាយមក យកមកដាក់លើប្រឡាយហើយបានមួលក្តិច ថាយើងនេះជាមនុស្សរឹងរូស ហើយជាមនុស្សប៉ិនធ្វើពុតត្បុតខ្ជិលធ្វើការងារ ។ តែមិត្តគាន ហ្នឹងគាត់អត់បានមកធ្វើការទេ ព្រោះគាត់ហើមជើង ហើយគាត់កើតឫសដូងច្រមុះទៀត ច្រមុះគាត់ឡើងស្អុយ ។ គាត់សុំច្បាប់គេសម្រាក ហើយខ្ញុំក៏ទៅធ្វើការក្រោកពីការដែលគេអូសមកដាក់លើប្រឡាយហើយ ខ្ញុំក៏ខំដើរត្រុកៗតាមគេពីក្រោយទៅស្ទូង ។ ស្ទូងស្រូវនៅចុងឆ្នាំពាក់កណ្តាលឆ្នាំ១៩៧៨ ពួកនាងខ្ញុំនៅធ្វើការតាមផ្លូវវត្តក្រពើហា រហូតដល់ព្រែកហូរ ព្រែកអីពួកខ្ញុំដើរស្ទូងចល័តរហូត គេខ្វះកម្លាំងខាងណាគេហៅយើងទៅខាងនុ៎ង ដើម្បីសម្រុកធ្វើឲ្យគ្រប់ផែនការសម្រេចបីតោនក្នុងមួយហិចតា ឬមួយហិចតាបីតោនទៅបួនតោន បីតោនកន្លះទៅបួនតោន ។

[១៣:៤៥:២៥]

ពេលនោះ នាងខ្ញុំមកផ្ទះវិញ ពេលដល់ម៉ោងសម្រាកមកផ្ទះវិញ មកដល់បាត់ បងគៀន អត់ឃើញ ។ គាត់ថាសុំច្បាប់គេឈឺសម្រាក បាត់បងគាន ទៀត អត់ឃើញខ្ញុំក៏មិនប៉ានសួរគេទេ។ មានបងស្រីមួយហ្នឹងគាត់នៅនឹងក្រុមពួកខ្ញុំហ្នឹងគាត់ថា មិត្តម៉េត មិត្តគាន ឃើញបងស្រីម្នាក់ហ្នឹងគេយកទៅបាត់ហើយថា យកទៅព្យាបាលជំងឺគាត់ ព្រោះជើង គាត់ឡើងរលួយប្រេះចេញទឹក ចេញខ្ទុះ នាងខ្ញុំក៏មិនមាត់ មិនស្តីអីទេព្រោះខ្ញុំក៏វាជិតងាប់ដែរហ្នឹង ។ ដល់ក្រោយមកទៀតនៅចុងឆ្នាំ ខ្ញុំអត់ចាំខែមិនដឹងខែប៉ុន្មានទេ តែខែរដូវស្រូវផើមហើយ ស្រូវហាលផ្កា បែកខ្លះ ខ្លះរាងអោនគ្រាប់មេៗ ។ គេឲ្យនាងខ្ញុំទៅលើកទំនប់ជីកប្រឡាយទៀត មួយក្រុមនាងខ្ញុំទៅទាំងអស់គ្នា ហ្នឹងសុទ្ធតែពួកថ្មីអ្នកចាស់បាត់អស់ហើយ។ មកពួកថ្មី នៅចាស់បីនាក់ខ្ញុំ តែប៉ុន្មាននាក់ទេ ខ្ញុំអត់ស្គាល់ឈ្មោះគ្រាន់ស្គាល់មុខគ្នា ។

ហើយទៅលើកទំនប់ជីកប្រឡាយខ្ញុំចាំបានថា ជីកប្រឡាយលើក ទំនប់ហ្នឹងនៅស្ពានព្រែកជ្រៃ យើងសព្វថ្ងៃធ្វើអាងទឹក ។ ពេលនោះ ប្រធានកងគេបានដាក់មេក្រូមួយបោះបង្គោលយ៉ាងខ្ពស់ដាក់មីក្រូ ហើយពួកមិត្តយុវជនយុវនារីគ្រប់កងអង្គភាពទាំងអស់ មកសម្រុកលើក ទំនប់ជីកប្រឡាយហ្នឹង ។ តែខ្ញុំជាអកុសលខ្ញុំវាទៅមិនរួចនឹងការរែកដី បើគេឲ្យគ្រាន់តែចូកដីដាក់បង្គី ខ្ញុំ ទៅរួច ដល់រែកដីឡើងទំនប់ខ្ញុំទៅអត់រួច ព្រោះជើងខ្ញុំវាហើមហើយវាប្រេះចេញទឹកខ្លាំងពេកខ្ញុំទៅអត់រួច ខ្ញុំរែកដី ខ្ញុំដួលៗ ទៅមេកងខ្ញុំថា មិត្តម៉េត មិត្តឯងយ៉ាងម៉េច? ខ្ញុំថា បងអើយខ្ញុំទៅមិនរួចទេ បើបងឯង ចង់ធ្វើម៉េចខ្ញុំធ្វើទៅ ខ្ញុំទៅមិនរួចទៀតទេ ។ រែកបានប្រហែលជាម៉ោងដប់ គាត់ក៏បានរុញច្រានខ្ញុំទៅនៅក្បែរភ្លឺស្រែហ្នឹង ខ្ញុំថាបងអើយខ្ញុំសុំសម្រាកបន្តិចមក ព្រោះខ្ញុំទៅអត់រួចទៀតទេ បើសិនជាបងចង់ធ្វើម៉េចធ្វើទៅ ។ គេអត់មាត់ទេ គេថាមិត្តឯងត្រូវតែប្រឹង បើមិនប្រឹងទេប្រយ័ត្នបាត់ខ្លួន ។

[១៣:៤៨:៥៣]

ដល់ពេលខ្ញុំគេឲ្យមកអង្គុយលើភ្លឺស្រែនៅខាងប្រឡាយម្ខាង ។ ខ្ញុំអង្គុយទៅមានយុវជនម្នាក់ហ្នឹងដើរមកថា មិត្តឯងយ៉ាងម៉េចបានមិនខំធ្វើការនឹងគេ ជិតដល់ម៉ោងបាយហើយ ។ ខ្ញុំថាបងអើយខ្ញុំទៅមិនរួចទេ ខ្ញុំសុំសម្រាក។ ហើយមានមិត្តនារីម្នាក់ទៀតមួយទៀតទៅមិនរួចដែរ គេអូសមកដាក់ក្បែរ ខ្ញុំនឹងអូសដាក់ក្បែរខ្ញុំហ្នឹងអង្គុយទាំងអស់គ្នា ត្បោកក្បាលជង្គង់នៅភ្លឺស្រែឯណោះមើលមុខគ្នាទៅមិនរួច បើថាឲ្យខ្ញុំធ្វើអីក៏ធ្វើដែរ ខ្ញុំរែកដីទៅមិនរួចទេ ។ ដល់យុវជននោះដើរមកលែងគេដាក់យើងផ្ទួសៗ គេគ្មានអាណិតស្រណោះយើងទេ វ៉ៃយើងទៅ ពួកខ្ញុំពីរនាក់ហ្នឹងភ័យពេកថា បើគេសម្លាប់ៗឲ្យហើយទៅ កុំឲ្យពិបាករស់នៅតទៅទៀត ។ គេគ្រាន់តែដាក់ផ្ទួសទៅ គេដើរហួសទៅទៀតទៅ ។ ខ្ញុំភ័យពេក ខ្ញុំសន្លប់នៅហ្នឹងភ្លឺស្រែហ្នឹងតែហ្នង ។ សន្លប់ហ្នឹងមិនមែនសន្លប់ងាប់ទេ គឺសន្លប់ដូចថាភ័យវាតក់ស្លុតពេក ។ ឮមាត់គេថា ដល់ម៉ោងបាយហើយគេហូបបាយហើយ មកអត់រួចទេ លោកប្រធាន ខ្ញុំក្រោកមកអត់រួចទេខ្ញុំនៅដេកស្ដូកស្ដឹងហ្នឹង ។ គេហូបបាយអស់ គេចែកបបរចែកអីគ្នាហូបអស់ទៅ ។ ពេលខ្ញុំ ដឹងខ្លួនក្រោកអង្គុយទៅប្រធានក្រុមខ្ញុំហ្នឹងគេថា ម៉េចស្រួលខ្លួនឬនៅមិត្តនារី? ខ្ញុំថា បងឯណាបាយរបបខ្ញុំឲ្យខ្ញុំសុំហូបមក ។ គេថាអត់មានទេ ព្រោះមិត្តឯងនេះវាឈឺញឹកញាប់ច្រើនជាងគេណាស់ហើយ ។ ហើយមិនមានអ្នកថ្មីឯណា មិត្តឯងអ្នកចាស់ទៀតមកតាំងពីឆ្នាំ១៩៧៧ ។ គេឲ្យធ្វើគំរូគេបែរជាឈឺបន្តិចឈឺៗ។ ខ្ញុំថាខ្ញុំទៅមិនរួចទេ ខ្ញុំដល់ក ខ្ញុំទៅមិនរួចទេ ។ គេអត់មាត់ទេ គេថាបើទៅមិនរួចនៅស្ងៀមនៅហ្នឹងហើយ ចាំបន្តិចទៀតចុះធ្វើការហ្នឹងគេទៀតដល់ម៉ោង ។ ខ្ញុំនឹកឃើញសព្វគ្រប់ ខ្ញុំថាបើគ្មានបាយស៊ីទេ

លែងខ្លាចអ្នកណាទាំងអស់ ។ ប្រធានកង ប្រធានវរៈ ប្រធានអីក៏ដោយ ខ្ញុំលែងខ្លាចទាំងអស់ ខ្ញុំថាខ្ញុំសុំដើររកអីស៊ីខ្លួនខ្ញុំហើយ ។ ទោះបីស៊ីអីក៏ដោយ ទៅរើសសំបកក្រសាំងស៊ី ទៅរើសត្នោតទុំស៊ី អង្គុយស៊ីតែចៃដន្យដែរ ខ្ញុំបានត្នោតទុំមួយនៅក្បែរប្រឡាយហ្នឹង ខ្ញុំទៅរើសត្នោតហ្នឹងមានគ្រាប់តែមួយចំហៀងទេ មួយចំហៀងទៀតកណ្តុរកកេរអស់ហើយ ។ ខ្ញុំបក ខ្ញុំអង្គុយជញ្ជក់ត្នោតទុំ ទោះបីតែមានដង្កូវមានអីខ្ញុំខំជញ្ជក់រហូតដូចថាដើម្បីឲ្យមានកម្លាំង ។ នៅពេលហ្នឹងគេចុះធ្វើការព្រឹបៗ គេរែកដី មេក្រូគេចាក់បទចម្រៀងបដិវត្តន៍ហ្នឹង ពួកមិត្តព្រឹបៗអី ។ គេឃើញខ្ញុំនៅហូបត្នោតទុំគេអត់មាត់ទេ គេដើរមិត្តឯងប្រុងប្រយ័ត្នខ្លួន ខ្ញុំថាដំណាក់កាលនេះហើយខ្ញុំលែងខ្លាចងាប់ហើយបងអើយ ។ គេឲ្យខ្ញុំលូនកាត់ទំនប់ឡើងពីប្រឡាយមកលើទំនប់ ចុះពីទំនប់ចូលប្រឡាយ ហើយបានឲ្យខ្ញុំស្រែកថា សូមមិត្តនារីទាំងអស់គ្នាកុំធ្វើតម្រាប់តាមខ្ញុំ ព្រោះខ្ញុំនេះជាមនុស្សធ្វើការមិនកើត មនុស្សខ្ជិលធ្វើការ។ ខ្ញុំសុខចិត្តលូនបន្តិចៗ ខ្ញុំស្រែកប្រាប់គេអ៊ីចឹង ។ ហើយពួកមិត្តហ្នឹងឈរមើលខ្ញុំទាំងអស់គ្នា ខ្លះលីចប ខ្លះរែកបង្គី ខ្លះរែកដីឡើងទំនប់ហើយឈរមើលខ្ញុំ មួយៗគ្រវីក្បាល តែរាងយើងទាំងអស់គ្នាហ្នឹងមានតែស្បែកដណ្តប់ឆ្អឹងទេម្នាក់ៗនោះ។ ដល់នោះខ្ញុំឈប់លូន លូនអស់កម្លាំងទៅមិនរួចខ្ញុំសន្លប់ទៀតហើយ ។ ខ្ញុំសន្លប់ទៀត ខ្ញុំដឹងថាខ្ញុំច្បាស់ជាស្លាប់ហើយពេលនេះ អត់ដល់ល្ងាចទេ ព្រោះថ្ងៃនោះវាជ្រេហើយ ។ ឃ្លានបាយ នៅភ្លឺស្រែហ្នឹង ខ្ញុំទៅរើសអាត្នោតដែលខ្ញុំហូបពីថ្ងៃ ខ្ញុំរើសជញ្ជក់រហូតទៅ ព្រោះមិត្តគេសម្រាក ។ ដល់ពេលខ្ញុំនៅហ្នឹងភ្លឺស្រែហ្នឹង ខ្ញុំអង្គុយហូបត្នោត ខ្ញុំថា ខ្ញុំអត់ខ្លាចអ្នកណាទាំងអស់ ខ្ញុំលែងខ្លាចហើយ បើស្លាប់ក៏ស្លាប់ចុះ ព្រោះអ្នកដែលមកទាំងអស់គ្នាជាមួយខ្ញុំវាបាត់មុខអស់រលីងហើយនៅតែខ្ញុំ ។ អ្នកឃើញមកនៅខែទីមួយ ខែទីពីរ ជារៀងរាល់ខែជារៀងរាល់សប្តាហ៍ ឃើញតែមុខយ៉ាងយូរដប់ថ្ងៃបាត់មុខអស់មកអ្នកថ្មីទៀត ។

[១៣:៥៤:០៨]

ពេលនោះហើយខ្ញុំថា លែងខ្វល់ខ្ញុំអង្គុយហូបហើយធ្វើមិនដឹង ខ្ញុំមិនបាច់មើលអ្នកណាទាំងអស់ ទោះបីមេកងដើរកាត់មុខខ្ញុំ ខ្ញុំលែងខ្លាចលែងគោរពវា វាដល់កហើយ ខ្ញុំថាស្លាប់ក៏ស្លាប់ចុះ ដាក់មួយត្បូងចបឲ្យងាប់ក៏ងាប់ទៅ ។ ដល់តែពេលគេទៅផ្ទះអស់ ទៅកន្លែងអស់ មានបុរសពីរនាក់ហ្នឹងគេដើរមកហើយបានហៅខ្ញុំ មកដល់ទាញត្នោតទុំហ្នឹងពីដៃខ្ញុំក្រវាត់ចូលទឹកប្រឡាយក្នុង ។ ថាម៉េចហើយមិត្តនារីទៅដល់ផ្ទះឬអត់? ខ្ញុំថា ខ្ញុំទៅមិនរួចទេ ខ្ញុំសុខចិត្តលូននៅងាប់នេះងាប់ចុះ ខ្ញុំទៅមិនរួចទេ បងអើយ ជើងខ្ញុំប្រេះចេញទឹក ទឹកវាស៊ីនោះ រយះច្រវែបជើង ច្រវែបមេជើងខ្ញុំរលួយ កូនជើងខ្ញុំរលួយ។ គាត់ថាមក

ទៅជាមួយគាត់ៗនឹងនាំទៅ ។ ដឹកដៃខ្ញុំឡើងអូសទៅតាមភ្លឺស្រែហ្នឹងទឹងណាត់ទីណែងទៅ ។ ខ្ញុំទៅនឹងគេ ។ ពេលនោះ គេអត់យកខ្ញុំទៅនៅក្រុមខ្ញុំ ទៅកងខ្ញុំចាស់ទេ គេយកខ្ញុំទៅដាក់កន្លែងផ្សេងទៀត ។ ពួៗពីរនាក់ហ្នឹងគាត់យកទៅដាក់អត់ដឹងកន្លែងណាទេ ខ្ញុំចេញពីកន្លែងកង១៧ ទៅ ។ ដល់ទៅដល់កន្លែងហ្នឹង ជាកន្លែងគេដាំបន្លែ ។ ខ្ញុំនៅហ្នឹងមានបងស្រីៗ កាលនោះខ្ញុំនៅក្មេងដែរ ។ បងស្រីៗហ្នឹងចំណាស់ខ្ញុំសព្វថ្ងៃហ្នឹង ។ គេមកទទួលខ្ញុំហើយគេឲ្យខ្ញុំមុជទឹកផ្លាស់អាវផ្លាស់សំពត់ហើយ គេឲ្យបាយហូប ។ គេថា មិត្តនារីឯងហូបឲ្យឆ្អែតទៅនឹងអាលធ្វើការ ។ ខ្ញុំធ្វើការអី? ថ្ងៃល្ងាចណាស់ទៅហើយ ។ ថ្ងៃណាមិត្តនារី យើងសម្រុកខំធ្វើទំនប់ (ខ្ញុំនិយាយសាឡើងវិញ) ឲ្យរួចមុនផែនការលោកប្រធាន ក្នុងប្រឡាយហ្នឹងក្បែរមាត់អាង ហើយប្រឡាយហ្នឹងគេឲ្យចាក់ឲ្យបំពេញ បើធ្វើមុនរួចផែនការ ហ្នឹងបានសម្រាក ។ មិត្តនារីយើងទាំងអស់គ្នាហ្នឹងគេខំសម្រុកធ្វើរួចមុនផែនការគេបានសម្រាកពីម៉ោងបីកន្លះ ប្រហែលជាម៉ោងបីកន្លះហ្នឹងថ្ងៃនៅខ្ពស់ដែរ។ គេសម្រាកអស់ទៅនៅខ្ញុំហ្នឹង ។

ដល់ខ្ញុំ (សុំមិននិយាយអាហ្នឹង និយាយមកដល់កន្លែងខ្ញុំដាំបន្លែ) បងស្រីបីបួននាក់ហ្នឹងគេឲ្យខ្ញុំហូបឆ្អែតហើយគេក៏នាំខ្ញុំទៅកូនរោងមួយ គេប្រាប់ មានគ្រាប់ត្រឡាច គ្រាប់ល្ពៅ គ្រាប់ត្រសក់ គ្រាប់សណ្តែក ហើយមានស្ពៃ មានកំណាត់ស្ពៃ មានអីគេក៏គេប្រាប់ពីរបៀបបណ្តុះ ។ គេឲ្យយើងលាងឲ្យស្អាតហើយយកមកដាក់ហ្នឹងកំណាត់ហ្នឹង បណ្តុះគ្រាប់ហ្នឹង ហើយបង្កប់នៅដីខ្សាច់ ។ ខ្ញុំក៏ធ្វើតាមគេ ។ ព្រឹកឡើងបងៗហ្នឹងឲ្យខ្ញុំរែកទឹកចាក់ទឹកដំណាំ ឡើងពីមាត់ទន្លេ មាត់ស្ទឹង ខ្ញុំចាំមិនបានទេ នៅលើកោះដែលខ្ញុំនៅបានរយៈប្រហែលបួនប្រាំថ្ងៃបានខ្ញុំឮ គេនិយាយថា នៅស្រុកស្អាងកោះធំគេថានៅកោះធំៗ ។ ខ្ញុំនៅដាំបន្លែហ្នឹងបានប្រហែលជាបីខែ ខ្ញុំបានហូបឆ្អែត ដេកបានពេញភ្នែក ។ ហើយក្រោយមកទៀតដាំបន្លែបានកើត លោកប្រធានខ្ញុំដាំបន្លែកន្លែងខ្ញុំ ហ្នឹងមានស្ពៃក្តោប ឆៃថាវ សណ្តែកកួរ ល្ពៅ ត្រឡាចមានគ្រប់មុខ ។ ដល់ខែគេប្រមូលផលឡានគេចូលដឹក ពួកមិត្តចូលប្រមូលដឹកដាក់កូនឡានដឹកយកទៅបាត់អស់។ ទៅក្រោយមកទៀតពួកខ្ញុំដាក់ដាំម្តងទៀត ។ ខ្ញុំដាំបន្លែហើយពីរថ្ងៃគេអត់ឲ្យខ្ញុំនៅទំនេរទេ ឲ្យខ្ញុំទៅត្បាញកន្ទេលទៀត ត្បាញកន្ទេលត្នោត ។

[១៣:៥៨:២០]

ហើយរំលងក្រោយមក ពួកយើងទើបដាំបណ្តុះគ្រាប់បានប្រហែលជា បន្លែប្រហែលជាបានមានដុះស្លឹកដុះអីបានឮសំឡេង គេថាយួនចូលដល់ភ្នំពេញហើយ ។ ពេលនោះ ឮផ្ទុះគ្រាប់នៅទីក្រុងភ្នំពេញហ្នឹងបងស្រីៗនៅជាមួយខ្ញុំថា មិត្តម៉េត រៀបចំអីវ៉ាន់ទៅយើងនៅមិនបានទេ ត្រូវតែចេញពីទីនេះ ។

រៀបចំសាក់កាដូ អីរៀងខ្លួនទៅគេយកទូកចម្លងមកត្រើយម្ខាង ។ យប់ប្រហែលជាម៉ោងប្រាំពីរ គេថារថក្រោះ យួនមក ភ្លើងរថក្រោះគ្រាប់ចេះតែមក រត់ ពួកខ្ញុំរត់កាត់មិនដឹងឯណាយប់ ពេលដែលខ្ញុំរត់កាត់នោះស្រូវ ទុំពេញស្រែ រត់កាត់ចាក់បណ្តោយទៅជើងវិញ ចេះតែរត់ទាំងយប់ទាំងថ្ងៃ ខ្លះដួលជាន់គ្នី ជាន់គ្នាហ្នឹង អត់មានអ្នកណាប្រមូលកៀរគរអីទេ ពេលដែលរត់ហ្នឹង រត់រៀងខ្លួនយកតែព្រះអាយុរៀងខ្លួនមក ។

ពេលរត់ទៅដល់ពេលយប់នាំគ្នាដេកតាមចម្ការឪឡឹក ។ ប្រជាជនតាមខ្ទមស្រែប្រជាជន ។ រត់ៗទៅៗដល់បានទៅដល់ស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង គេហៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងហ្នឹង។ ទៅដល់មានវត្តគេមួយ មានបងយុវជនជាប្រធានកងហ្នឹង គាត់កាន់មីក្រូមួយហើយប្រកាស ប្រកាសថា មិត្តនារី មិត្តយុវជនទាំងអស់គ្នា ដែលយើងបានរត់មកបែកបាក់ដាច់កង ដាច់អង្គភាព យើងនឹងប្រមូលគ្នាឲ្យបានច្រើនជួបជុំគ្នាវិញ ហើយរៀបជាក្រុម រៀបឲ្យមានកងមានក្រុមហើយ យើងនឹងចាប់ផ្តើមប្រមូលផលនៅស្រុកយើងកំពង់ត្រឡាចហ្នឹង ស្រូវគេទុំ អាខ្លះស្រូវគេឡើងដុះសាទុំ ។ ទៅពួកខ្ញុំគេឲ្យទៅជញ្ជូនស្រូវតាមឃ្លាំង ក្រុមខ្ញុំ បានបែបអត់បានដប់នាក់អីទេ បានតែប្រាំពីរនាក់ ។ អត់ស្គាល់គ្នាសោះទៅជាប់គ្នានៅឯកន្លែងស្រុកកំពង់ត្រឡាចនុំង គេរៀបនាំគ្នាទៅជញ្ជូនស្រូវម្នាក់ឲ្យបានមួយបេ ក្នុងមួយថ្ងៃឲ្យបានប្រាំជើង-- មួយព្រឹកឲ្យបានប្រាំជើងយកមកដាក់ក្នុងឃ្លាំងនៅក្បែរស្រុកកំពង់ត្រឡាចហ្នឹងមានឃ្លាំងគេមួយ ។

[១៤:០០:៤៨]

ដល់ផុតពីជញ្ជូនប្រមូលផលស្រូវ ជញ្ជូនសណ្តែងដីៗដាក់ឃ្លាំង ឈប់ពីជញ្ជូនសណ្តែងដីដាក់ឃ្លាំងរៀបចំជាក្រុមហើយឲ្យយើងជញ្ជូន កិនស្រូវកិនអង្ករ កិនស្រូវកើតជាអង្ករដាក់ច្រកបេ ច្រកអី ឲ្យជញ្ជូនឡើងទៅព្រៃដាក់ទុកដាក់នៅតាមព្រៃ មានរោងមានឃ្លាំងគេនៅក្នុងព្រៃហ្នឹង ។ ចូលទៅជ្រៅៗហើយជញ្ជូនដាក់ពេលនោះគឺ កងទ័ពវៀតណាម កាលនោះអត់ហៅវៀតណាមទេ គេហៅយួន ។ យួនឡើងមកដល់ពួកមិត្តប្រាប់ថា យួនជិតមកដល់ហើយមិត្តយើងរត់បន្តទៅទៀត ។ ពួកមិត្តខ្ញុំគ្នាប្រាំពីរនាក់ហ្នឹងយើងបានចាប់ដៃគ្នាថា សុំស្គាល់គ្នាធ្វើជាបងប្អូន ។ យើងទៅត្រង់ណាទៅទាំងអស់គ្នា ពួកខ្ញុំនៅជាមួយគ្នារហូត ។ ដល់រត់កាត់ស្រុកកំពង់ត្រឡាចទៅទៀត អត់បានធ្វើទ័ពនឹងគេទៀតទេ ។ នារីខ្លះគេបញ្ចូលក្នុងកង តែពួកខ្ញុំគេចអត់រត់ទេ-- អត់ចូលនឹងកងគេទេ ខ្ញុំរត់រហូត រត់ទៅពេលដែលរត់ទៅឮឡានឮសំឡេងរថយន្ត ហើយនិងគេប្រកាសមីក្រូថា "បងប្អូនដែលបានរត់បែកបាក់កងអង្គភាពអីសូមបងប្អូន

មកចូលរួមជាមួយយើងវិញ កងទ័ពយើងរំដោះប្រជាជន ស្រោចស្រង់ប្រជាជនឲ្យរស់រានមានជីវិត" ។ ពេលនោះមានឡានគេទៅផុតអ៊ីចេះទៅ ពួកខ្ញុំនឹងជុំគ្នានៅក្រោមដើមឈើមួយ ហើយបានជំនុំគ្នាថា តើយើងគួរទៅមុខ ឬទៅក្រោយវិញ? មានបងយុវជនម្នាក់ហ្នឹងគាត់ថា យើងមិនអាចទៅក្រោយវិញទេ ព្រោះអីយើងខ្លាចថា យួនកាលណាវាចូលមកវាចាប់ មិនថានារី ថាបុរសទេ វាចាប់ហើយវាដាំៗ ក្បាល ដាក់ក្បាលយើងជុំគ្នាជាបីមុំទៅដាំទឹក ទឹកតែ ទឹកក្ដៅវាសម្រាប់ផឹកហ្នឹង ។ ហើយគេនិយាយមួយទៀតថា កាលណាយួនចាប់នារីៗបដិវត្តន៍បានហ្នឹង វារំលោភៗរួចហើយវាអារ-កនឹងធាងត្នោត ។ ពេលនោះពួកខ្ញុំភ័យខ្លាចខ្លាំងអត់ប៊ានទេ ការរំលោភពួកយើងមិនដែលជួបប្រទះ យើងខ្លាចយើងចេះតែទៅទៀតហើយ ណាមួយខ្លាចគេអាកនឹងធាងត្នោតហ្នឹងថ្មើរណាងាប់ ខំតស៊ូតាំងពីនៅព្រៃសរស់រានមានជីវិតរត់មកដល់កន្លែងនេះទៅមិនឲ្យអ្នកណាអាកស្រួលៗទេនេះ ។ ចេះតែរត់ទៅ រត់ទៅជួបគ្នាខ្លះមានកូនខ្លះមានប្ដីហើយយួនចេះតែដេញតាមឡើងភ្នំទីណាត់ទីណែងគ្រប់ច្រកល្ហកទាំងអស់ ។ ខ្លះងាប់ខ្លះរស់ ខ្លះងាប់អង្គុយ ខ្លះងាប់អង្រឹង ។

ដល់ពាក់កណ្ដាលឆ្នាំ១៩៧៩ ហ្នឹងពួកនាងខ្ញុំឡើងដល់ភ្នំឱរ៉ាល់ មានមេកងមួយនាំដល់ភ្នំឱរ៉ាល់ពេលនោះខ្ញុំឈឺ ដាច់អស់អង្ករក្រុមខ្ញុំប្រាំពីរនាក់ហ្នឹង អស់អង្ករ អស់អំបិល អស់អីហូបហើយនាំគ្នាជីកក្ដួចត្រាំធ្វើក្ដួចហូប ។ ហូបក្ដួចធ្វើមិនល្អពុលក្ដួចហ្នឹងជិតងាប់ម្នាក់ៗទៀត ។ អស់អត់ប៊ានហូបក្ដួចនាំគ្នាទៅជីកទំពាំងយកមកត្រាំហូបទំពាំងស្លឹកព្រិច ។ ហើយពួកទ័ពវៀតណាម ពួកយើងនៅនឹងជើងភ្នំនឹងទ័ពឡើងព្រួសៗទៅពួកយើងពួននៅកន្ទៀតៗភ្នំតែអត់ឃើញយើងទេ គ្រាន់តែពួកខ្ញុំថា ពួកខ្ញុំថា "ឱ! គុណបុណ្យជីដូនជីតាម៉ែឪអើយ! ជួយខ្ញុំផង ម្ចាស់ទឹកម្ចាស់ដីនៅព្រៃភ្នំនេះជួយខ្ញុំផង ដើម្បីកុំឲ្យយួនឃើញ" ។ យើងពួនគេដើរសឹងជាន់យើង តែគេមើលយើងអត់ឃើញទេ ។

[១៤:០៤:៣៣]

ដល់ពេលក្រោយមកទៀត ខ្ញុំធ្លាក់ខ្លួនឈឺៗ ហើយពួកមិត្តទាំងហ្នឹង គេមកប្រមូលថាអ្នកណាដែលបានឡើងមកដល់ជើងភ្នំឱរ៉ាល់ហើយ គេប្រមូលទៅដើម្បីឆ្លងដែន ខ្ញុំថា "ខ្ញុំនៅទៅមិនរួចទេបងខ្ញុំចាប់ផ្ដើមឈឺទៅហើយ ។ គ្រុនចាញ់ផង ហើយខ្ញុំឈឺជើងផង បងឯងទៅណាទៅទៅ ទុកតែដែកកេះហើយនិងឆ្នាំងបាយឲ្យខ្ញុំមួយបានហើយ" ។ គេទុកឲ្យខ្ញុំនៅតាមជំរំ នៅតាមរោងគេក្នុងព្រៃដើមស៊ុទ្ធតែដើមឫស្សី ។ ខ្ញុំរស់នឹងទំពាំងនិងស្លឹកព្រិច ខ្ញុំរស់នៅនឹងអូរនឹងមានទឹកជ្រោះមួយនៅពីរនាក់កុមារម្នាក់ ។ កុមារហ្នឹងតូចអាយុប្រហែលជាប្រាំពីរឆ្នាំ ហើយនិងពូៗពីរនាក់ទៀតគាត់របួសៗក្បាល ហើយគាត់មាន

ឆ្នាំងមានកាំបិតមានអី ។ យើងនៅជាមួយគ្នាហ្នឹង ដល់កងទ័ពមកប្រមូលពីលើមក គេមកប្រមូលយើងឲ្យទៅទៀតគេថានៅមិនបានទេមិត្តនារី តែនៅយូរមិនដឹងជាយួនចាប់ មិនដឹងជាសត្វខ្លាសត្វដំរីវាខាំទេ ព្រោះនៅព្រៃភ្នំនេះសម្បូរសត្វសាហាវណាស់ ។

[១៤:០៥:៤៣]

ខ្ញុំទៅ ថាទៅមិនទៅគេអត់បង្ខំអត់អីទេ ស្រេចនឹងយើងស្ម័គ្រចិត្តទៅដើរបន្តិចៗទៅតាមគេ ។ គេទៅនៅដល់កន្លែងគេមានមិត្តនារីយុវជនច្រើន គេថាជាជំរំរបស់កងទ័ព ។ ខ្ញុំនៅនោះបាន មិនដឹងជាប៉ុន្មានខែទេ ខ្ញុំចាំមិនបាន ។ ខ្ញុំភ័យខ្លាចពេក ព្យាបាលជើងគេមើលជើងមើលអីខ្ញុំជាហើយគេឲ្យលាបថ្នាំលាបអីជាហើយគេថា “យើងនឹងទៅមុខទៀត” ពេលនោះខ្ញុំនឹកឃើញថា បើសិនជាទៅមុខទៀតខ្ញុំមិនដឹងជាទៅដល់ណាទេ ។

ខ្ញុំបានលួចគេចខ្លួនមកនៅនឹងជើងភ្នំជាមួយនឹងប្រជាជន ។ ប្រជាជននឹងប្រហែលមានបីបួនប្រាំគ្រួសារ ។ ខ្ញុំក៏មកនៅជាមួយប្រជាជនហ្នឹងលាក់ខ្លួន រួចគេហៅសួរថា មានបាត់មិត្តនារីមានឃើញអត់? មិត្តនារីម្នាក់ ហើយប្រជាជននឹងក៏គាត់ជួលលាក់ដែរ គាត់ថាអត់ដែលឃើញមានអ្នកណា មាននារីណាមកនេះទេ មានតែកូនចៅ ។ គេដើរផែកមើលឲ្យគេកូនចៅ ខ្ញុំពួនទៅរួចខ្លួន ។

ដល់ក្រោយមកទៀតបានកងទ័ពវៀតណាមឡើងទៅគេវ៉ៃបាញ់តដៃគ្នាហ្នឹងក្នុងក្លាំងៗគ្រាប់ផ្លោងទៅផ្លោងមកហ្នឹង ។ ខ្ញុំក៏បានយួនចាប់ពេលនោះ ពេលនោះយួនគេឃើញខ្ញុំដែរ គេថាខ្ញុំជាកងទ័ពខ្មែរក្រហម ។ ទៅគេក៏បានចាប់ខ្ញុំយកមក ចាប់ខ្ញុំយកមក ខ្ញុំបានដោយទាំងក្មេងអាយុប្រាំពីរឆ្នាំម្នាក់ហ្នឹងយកមកដែរ ។ ខ្ញុំយកមករហូតខ្ញុំចិញ្ចឹម ខ្ញុំឲ្យស៊ី ខ្ញុំអត់ហ៊ានស៊ីខ្លួនឯងទេ មានចំណីចំណុកអីខ្ញុំឲ្យទៅវាស៊ីហ្នឹង ។ ដល់យួនគេចាប់មកគេបញ្ជូនមកៗដល់គេហៅភូមិរំទោល នៅត្រពាំងក្រឡឹងហ្នឹង ឃើញមន្ទីរគេយ៉ាងធំបណ្ដោយប្រហែលហាសិបម៉ែត្រមន្ទីរជំរំគេហ្នឹង ។

[១៤:០៧:៣៥]

មកដល់ហ្នឹងមិត្តនារីស្រីៗហ្នឹង វាខ្មែរគេចេះបកប្រែចេះនិយាយខ្មែរច្បាស់ គេសួរថា “មិត្តឯងមកពីណា?” ខ្ញុំថា “ខ្ញុំអត់ដឹងមកពីណាទេ គឺមកពីភ្នំយួនបានចាប់ខ្ញុំមក” ។ គេថា “អ្នកមិនបាច់ភ័យទេ បើអ្នកឯងបានមកជាមួយកងទ័ពវៀតណាមកម្ពុជាហើយ អ្នកឯងអាចរស់រានមានជីវិតហើយ” ។ ខ្ញុំភ័យៗនោះឃើញថា ពេលយួនចាប់ខ្ញុំ ខ្ញុំចាំមើលថាពេលណាដែលយួនវារំលោភខ្ញុំ ។ នៅពេលណាដែលយួនអារ-កខ្ញុំ ខ្ញុំចេះចាំរង់ចាំមើលយប់គេចងអង្រឹងឲ្យខ្ញុំដេក ។ ខ្ញុំដេកហើយខ្ញុំភ័យខ្លាច ខ្ញុំយកកំណាត់

កៅស៊ូរុំខ្លួន ខ្ញុំខ្លាចយួនរំលោភ តែដល់ពេលភ្ញាក់ឡើងអត់មានអ្នកណាក្បែរយើងទេស្ងាត់ឈឹង ហើយមានតែកូនក្មេងម្នាក់ដែលដេកក្បែរខ្ញុំហ្នឹង ។ ដល់បានរយៈពេលបីថ្ងៃនៅជំរំ គេហៅភូមិរំទោលហ្នឹង ភូមិរំទោលនៅត្រពាំងក្រឡឹងហ្នឹង នៅជើង នៅនឹងព្រៃអត់ទាន់ឡើងមកភូមិស្រុកប្រជាជនទេ ហ្នឹងមានតែកងទ័ពវៀតណាមកម្ពុជានៅនឹងជំរំ ។ ដល់បីថ្ងៃក្រោយមក បានគេបញ្ជូនខ្ញុំមកនឹងខេត្តមកភូមិត្រពាំងក្រឡឹងហ្នឹងមានទ័ពខ្មែរជាច្រើន គេបានសួរនាងខ្ញុំ ។ គេចុះសួរ-- ចុះប្រវត្តិរូបថា មិត្តនារីឯងមកពីខាងណា? នៅស្រុកណា? នៅខេត្តណា? ទៅដល់ណាមកវិញ បានស្គមមើល-- គេថាមើលតែព្រាយមកពីព្រៃភ្នំ ។

កាលនុំងនាងខ្ញុំស្គមទ្រុឌទ្រោមដូចកាលដូចនៅព្រៃសដែរហ្នឹង ។ សួរទៅប្រាប់ប្រវត្តិរូប ចុះប្រវត្តិរូបអីអស់ ពួកទាហានហ្នឹងគេបញ្ជូនមកតាមៗផ្លូវរហូតគេឲ្យយើងដើរមក ។ គេមានសរសេរជាសំបុត្រ សរសេរក្រដាសហ្នឹងដាក់ថា បើឃើញឈ្មោះនាងខ្ញុំអីទៅដល់ភូមិណា បើទាហាន ឬកងឈ្លបសេនាជនហ្នឹង ឃើញគាត់ដល់ណាចែកបាយចាយម្ហូបគាត់ហូបផង ។

[១៤:០៩:៣៨]

ខ្ញុំមកដល់ចូលខេត្តកំពង់ស្ពឺពេលយប់ មេភូមិហ្នឹងគេឃើញខ្ញុំមកគេខ្លាចៗយើងបង្កប់ខ្លួនម៉េចៗ គេសុំឆែកមើលអីទាំងអស់ ។ ឆែកមើលហើយដល់អត់ឃើញមានអី គេឃើញខ្ញុំហុចលិខិតហ្នឹងទៅមេភូមិក៏គេឲ្យខ្ញុំទៅដេកគេ គេឲ្យបាយឲ្យអីហូប ។ ព្រឹកឡើងខ្ញុំក្រោកឡើងឃើញទាហានគេយួនហ្នឹងហាត់ព្រាតនៅតាមភូមិនៅខេត្តកំពង់ស្ពឺហ្នឹង ។ ខ្ញុំក៏បានមកបន្តទៀត ដើរមករហូតពីរនាក់ក្មេងហ្នឹង ដល់ក្មេងហ្នឹងវាដើរ ដើររល់ល្ងាច ដើរតាមផ្លូវជាតិរហូត កូនក្មេងហ្នឹងវាមកអត់រួចវាសោះវាពេក ខ្ញុំឃើញគេបរទេះគោនឹងរទេះកង់ឡាន រទេះគោ ហើយខ្ញុំក៏បានសុំថា “ពូខ្ញុំសូមផ្ញើកូនមនុស្សនេះមួយផងវាទៅអត់រួចទេ ឲ្យជិះរទេះផងចាំដល់ទៅមុខពូឯងដាក់ទុកឲ្យខ្ញុំ ខ្ញុំនឹងយកវាទៅទៀត ព្រោះកូនខ្ញុំហ្នឹងខ្ញុំរើសបាននៅហ្នឹងព្រៃភ្នំទេ” ។ គេពីរនាក់ប្ដីប្រពន្ធហ្នឹងគេក៏លើកកូនហ្នឹងដាក់រទេះមក ខ្ញុំក៏ដើរតាមពីក្រោយស្ពាយអង្រឹង ហើយនិងអង្ករប្រហែលបួនប្រាំកំប៉ុងខ្ញុំដាក់ក្នុងថង់យួរមក ។

ដល់មកដល់ភូមិគេខ្ញុំសួររកថា “ឃើញមានពូម្នាក់និងមីងម្នាក់គាត់-- ខ្ញុំផ្ញើក្មេងម្នាក់ដាក់ហ្នឹងរទេះហ្នឹងមកភូមិទេ” សួរគេអត់មាននរណាឃើញទេ គ្មានអ្នកណាស្គាល់ទាំងអស់ ។ ទៅខ្ញុំក៏បែកពីក្មេងហ្នឹងរហូត ។ ខ្ញុំសុំគេដេកនៅនឹងភូមិ នៅផ្សារខេត្ត ដេកមួយយប់នឹងរោងគេលក់អីវ៉ាន់ គេចៀនចេកចៀនរោងគេហ្នឹង ។ ដេកអត់មានអ្នកណាសួរនាំអីទាំងអស់ ភ្លឺឡើងក្រោបឡើងខ្ញុំដើរមកទៀត ខ្ញុំដើរពេញ

មួយថ្ងៃវល់ល្ងាច ។ ខ្ញុំដើរមកដល់ភូមិអូរដឹម ឃុំកន្ទោក ភូមិអូរដឹម ខ្ញុំមកទៀតមកដល់មុខទៀតដល់ផ្លូវបំបែកចោមចៅជម្ពូវ័ន្តហ្នឹង មានអ៊ំស្រីម្នាក់គាត់លក់នៅហ្នឹងផ្សារ គាត់សួរថា "នាងៗឯងមកពីណា? ទៅណា?" ខ្ញុំថា "ខ្ញុំមកមកពីភ្នំយួនចាប់ខ្ញុំមក ។ ខ្ញុំអត់ដឹងទៅណាទេ ខ្ញុំរកផ្លូវទៅស្រុកមិនឃើញទេអ៊ំ" ។ ទៅយាយហ្នឹង ក៏គាត់មានចិត្តធម៌ដែរ គាត់ថា "បើនាងឯងអត់មានញាតិសន្តានបងប្អូនទេ នៅនឹងអ៊ំនេះហើយ ផ្ទះអ៊ំមានផ្ទះនៅ" ។ ខ្ញុំខ្លាចគេទៀត ខ្ញុំខ្លាចគេយកខ្ញុំទៅណាទៅណី ទៅឲ្យទាហាន ទៅឲ្យយួនអីគេសម្លាប់ខ្ញុំភ័យពេក ខ្ញុំថា "ខ្ញុំអត់ទៅទេ ខ្ញុំសុខចិត្តដើរដល់ណាផុតត្រឹមណាឲ្យចោលត្រឹមណាឲ្យវាងាប់ត្រឹមណាត្រឹមនោះទៅ ខ្ជិលរកបងប្អូនមិនឃើញ" ។ គាត់ក៏ថា "មកនៅនឹងគាត់មកគាត់ធានា" ។ ដល់គាត់យកខ្ញុំមកនៅ ភូមិផ្ទះគាត់នៅនឹងជម្ពូវ័ន្ត ជិតភូមិព្រៃស្វាយនៅនឹងជម្ពូវ័ន្ត ជិតភូមិអូរដឹមជាប់គ្នាហ្នឹង ។ ខ្ញុំនៅនឹងគាត់បានមួយខែៗមានមេភូមិមេក្រុមគេហ្នឹង គេមកសួរប្រវត្តិខ្ញុំ និងម៉ែចិញ្ចឹមខ្ញុំហ្នឹង។ គេសួរទៅគាត់នឹងធានាអះអាងថា ជាកូនចិញ្ចឹម បើសិនជាមានសកម្មភាពអីៗ គាត់សុខចិត្តទទួលទាំងអស់ សូមឲ្យមេភូមិនឹងទទួលស្គាល់ផង ។ ទៅនាងខ្ញុំក៏នៅជាមួយគាត់នឹងធ្វើស្រែគេៗធ្វើស្រែប្រវាស់តាមក្រុមតាមអីហ្នឹង ឆ្នាំ១៩៧៩ ខែ១០ ខ្ញុំមកដល់នៅជម្ពូវ័ន្តនៅចោមចៅ ។

[១៤:១២:៥៦]

ដល់ក្រោយមកទៀតម៉ែធម៌ខ្ញុំហ្នឹង គាត់ចេញចូលៗនៅបន្ទាយជម្ពូវ័ន្តហ្នឹង បន្ទាយទាហានហ្នឹង គាត់ចេញចូលៗ គាត់រកស៊ីអីខ្ញុំអត់ដឹងទេ ជារឿងរបស់គាត់ ។ គាត់លេងបៀ លេងអាប៉ោងអីខ្ញុំអត់ដែលដឹងទេ ព្រោះខ្ញុំទៅស្ទូងរហូត ។ ដល់បានប្រហែលជាបីខែខ្ញុំនៅគាត់ អត់ដល់បីខែទេ លោកប្រធានខ្ញុំនឹងគាត់តាំងពីខ្ញុំស្គម ខ្ញុំនៅ គេបំប៉នខ្ញុំ គាត់ហ្នឹងបំប៉នខ្ញុំឲ្យហូបសុទ្ធតែសាច់គោរបាយម្ហូបឆ្ងាញ់ៗខ្ញុំហូបៗរហូតចង់ហាល់ជិតងាប់ តែខ្ញុំអត់មាននឹកនាអីទៀតទេ ។ ខ្ញុំថាខ្ញុំប៉ុណ្ណេះខ្ញុំរស់រានមានជីវិតហើយខ្ញុំលែងស្លាប់ហើយ ។ ខ្ញុំនៅនឹងប្រជាជនគេមកសួរខ្ញុំគ្រប់គ្នាសួរថា "នាងឯងនៅឯណា? មកពីណាហ្នឹង?" ខ្ញុំប្រាប់ថា "ខ្ញុំនៅខេត្តកំពង់ធំ តែខ្ញុំអត់ដឹងរកផ្លូវទៅខេត្តកំពង់ធំអត់ឃើញទេ មិនដឹងនៅប្រឡោះណាវិញទេ ខ្ញុំរង--

**ប្រធានអង្គជំនុំ៖**

**ស៖** បានហើយត្រឹមប៉ុណ្ណឹងហើយ ។ ដូចជាកំសត់ណាស់មែនទេ? ឥឡូវស្តាប់សំណួរយើងម្តងណា ។ ឥឡូវបកក្រោយវិញ ទីមួយសំណួរសួរថា ថ្ងៃដែលគេចាប់ខ្លួនលោកស្រីយកទៅឃុំឃាំងហ្នឹងថ្ងៃចាប់ហ្នឹងនៅថ្ងៃខែឆ្នាំណាច្បាស់លាស់? ហើយចាប់នៅពេលវេលាម៉ោងប៉ុន្មាន?

**ឆ៖** ចាស, លោកប្រធាន! នៅពេលដែលគេចាប់នាងខ្ញុំ ចាប់នៅវេលាម៉ោងដប់ពីរយប់ ក្នុងខែ ១១ ឆ្នាំ៧៧ ។

**ស៖** ចាំថ្ងៃដែរទេ?

**ឆ៖** ថ្ងៃ១០ លោកប្រធាន ។

**ស៖** នៅពេលដែលគេចាប់ខ្លួនហ្នឹង គេបានដាក់ខ្នោះ ឬក៏ចងស្លាបសេកដែរទេ? ឬក៏ចង់កំណាត់រុំមុខដែរទេមុននឹងបញ្ជូនចូលទៅកន្លែងឃុំឃាំង?

[១៤:១៥:០៧]

**ឆ៖** ចាស, នៅពេលដែលគេចាប់នាងខ្ញុំមកពីកន្លែងលីស្រូវហ្នឹង មកចូលផ្ទះ បងវិន ហ្នឹង គេអត់ទាន់មានចង មានអីទេ ។ គេឲ្យខ្ញុំមកជួបហ្នឹង បងវិន សិន ព្រោះបងវិន អ្នកបញ្ជាឲ្យទៅចាប់ខ្ញុំ ទៅហៅខ្ញុំមក ។ ដល់ពេលនាងខ្ញុំនៅអង្គុយចាំជាមួយសន្តិសុខហ្នឹង យូរទៅៗឡើងងុយដេកអត់ បងវិន ក៏បានឮសន្តិសុខហ្នឹង គេថា "ទៅឡើងឡានទៅ" ពេលដែលឡើងឡានទៅបានគេចងនាងខ្ញុំ ចងភ្នែក ហើយចងស្លាបសេកទៀត ។

**ស៖** ហើយគេបញ្ជូនមកដាក់ឡាន បញ្ជូនមកកន្លែងឃុំឃាំង អ៊ីចឹងមែនទេ?

**ឆ៖** ចាស, ពេលគេបញ្ជូនមកដាក់ឡាន ឡានហ្នឹងឡានអាសេៗកង់១០ ។ ឡានធំ តែយើងជិះនៅកាប៊ីនមុខជាមួយសន្តិសុខពីរនាក់ ហើយនិងតៃកុងឡានម្នាក់ ។ កាលខ្ញុំគេមិនទាន់ចងភ្នែកខ្ញុំ ខ្ញុំមើលឃើញ មនុស្សតែពីរនាកទី កាំភ្លើងម្នាក់មួយដើម ស្ពាយសងខាង ម្នាក់នៅខាងទ្វារម្ខាង ម្នាក់ទៀតទ្វារម្ខាង តៃកុងឡានកណ្តាល ខ្ញុំឈរក្បែតៃកុងឡាន ។ គេចងខ្ញុំហើយ គេចងភ្នែកទៀត បានគេបញ្ជូនមកដល់កន្លែងឃុំឃាំង ។

**ស៖** មកដល់កន្លែងឃុំឃាំងហ្នឹង មុននឹងចូលទៅកន្លែងឃុំឃាំងហ្នឹង តើគេបានប្រព្រឹត្តយ៉ាងម៉េច? គេធ្វើយ៉ាងម៉េចចំពោះលោកស្រីដែរ ឬទេ?

**ឆ៖** ចាស, មុនដែលចូលមន្ទីរឃុំឃាំងហ្នឹង គេអត់ទាន់មានធ្វើទារុណកម្មអីទេ ។ គេបានបណ្តើរខ្ញុំមកប្រហែល ដើរប្រហែលជាដប់នាទីជាង ដើរមួយសន្ទុះធំដែរបានដល់បន្ទប់ ។ ពេលដល់បន្ទប់ហើយគេក៏បានបើកទ្វាររុញច្រានខ្ញុំចូលបន្ទប់ហ្នឹង គេស្រាយ គេស្រាយតែមុខទេ តែចំណងដៃនៅចងជាប់ស្រាយតែមុខ ។ ពេលដែលខ្ញុំចូលទៅដល់ក្នុងបន្ទប់ហ្នឹងបានខ្ញុំឈ្ងោក អើតទៅឃើញមិត្តនារី មិត្តយ៉ាត និងមិត្តមឿន ហ្នឹង នៅកងជាមួយខ្ញុំដែរ ប៉ុន្តែគេនៅខាង ធ្វើស្រែនៅខាងទួលគោក ។ នៅអង្គុយហ្នឹង

បន្ទប់ហ្នឹង គេចង តែភ្នែកអត់ចងទេ បើកមើលឃើញស្គាល់គ្នា ។

**ស៖** លោកស្រីមកដល់កន្លែងឃុំឃាំងហ្នឹង នៅវេលាម៉ោងប្រហែលប៉ុន្មានដែរ?

**ឆ៖** ចាស, មកដល់មន្ទីរឃុំឃាំងហ្នឹង ភ្លឺៗហើយលោកប្រធាន ។

[១៤:១៨:00]

**ស៖** ភ្លឺច្បាស់ហើយនៅ ឬក៏ទើបតែភ្លឺព្រាងៗទេ?

**ឆ៖** ភ្លឺព្រាងៗអត់ទាន់ច្បាស់ទេ ។

**ស៖** ពេលគេបញ្ជូនមកដល់ គេមានធ្វើអ្វីដូចជាការស្រង់នូវជីវប្រវត្តិរបស់លោកស្រី ឬក៏ថតរូបរបស់លោកស្រីដែរឬទេ មុនពេលបញ្ជូនចូលទៅឃុំខ្លួននោះ?

**ឆ៖** ចាស, អត់មានទេ ។ តាមខ្ញុំចាំអត់មានទេ តែកាលខ្ញុំនៅអង្គភាពហ្នឹង ការធ្វើប្រវត្តិរូបហើយនិងថតហ្នឹងជាញឹកញាប់ហើយ ។ នៅក្នុងកងរបស់ខ្ញុំ គេថត គេធ្វើប្រវត្តិរូបសាចុះសាឡើង ធ្វើឡើងយើងធុញទ្រាន់ ។

**ស៖** អ៊ីចឹង ក្នុងអំឡុងពេលដែលលោកស្រីនៅក្នុងការឃុំឃាំងអស់រយៈពេលកន្លះខែហ្នឹង គេអត់បានដកស្រង់នូវប្រវត្តិរូបរបស់លោកស្រីទេ ហើយការថតរូបក៏អត់មានដែរ អ៊ីចឹងមែនទេ?

**ឆ៖** ចាស, លោកប្រធាន ។

**ស៖** ពេលអំឡុងពេលដែលគេឃុំឃាំងលោកស្រីដប់ប្រាំថ្ងៃ ដប់ប្រាំយប់នោះថា សួរថាតើខ្នោះ-ចំណងដៃដែលគេចងសេកលោកស្រីហ្នឹង ត្រូវបានគេដោះលែងឬទេ? ឬក៏គេទុកអ៊ីចឹងរហូតទាំងដប់ប្រាំយប់ ដប់ប្រាំថ្ងៃ?

**ឆ៖** ចាស, គេចងនាងខ្ញុំរយៈបីថ្ងៃបីយប់ ។ ចងជាប់ ពេលគេយកទៅសួរ គេចងភ្នែក ចងដៃពេលសួររួចមកបន្ទប់វិញ គេស្រាយភ្នែកហើយឲ្យចូលអង្គុយក្នុងបន្ទប់ធម្មតា ។

**ស៖** នៅក្នុងបន្ទប់ដែលគេឃុំឃាំងលោកស្រីបន្ទប់ធំដែរ ឬក៏បន្ទប់តូច? ហើយមានអ្នកឃុំឃាំងជាប់ឃុំឃាំងជាមួយលោកស្រីប៉ុន្មាននាក់ទៅ? ក្នុងអំឡុងពេលដែលលោកស្រីជាប់ឃុំឃាំងនៅទីនោះ ។

**ឆ៖** ចាស, នៅក្នុងបន្ទប់ហ្នឹង បន្ទប់មិនធំទេ ល្មម ប៉ុន្តែបើសិនជាផ្ទះរបស់យើងសព្វ ប៉ុនបន្ទប់ជួលគេ ។ ហើយខ្ញុំចូលទៅមិត្តនារីខ្ញុំពីរនាក់ បីនាក់ទាំងខ្ញុំ អត់មានអ្នកណាទៀតទេ ។

**ស៖** ហើយបន្ទប់ហ្នឹង គឺនៅផ្ទាល់ដី ឬក៏បន្ទប់នៅជាន់លើទីមួយ ទីពីរ ទីបី?

**ឆ៖** ចាស, បន្ទប់ហ្នឹង នៅជាប់ដីជាន់ក្រោម ។

**ស៖** អគារហ្នឹង មានៗបន្ទប់ជាន់លើទៀតដែរឬទេ? ឬក៏សង់ផ្ទាល់ដី ហើយជាប្រភេទអគារទាប? បានន័យថា មានតែដំបូលទេ ។

**ឆ៖** អគារមានជាន់ៗទៅលើ ព្រោះខ្ញុំ ពេលដែលខ្ញុំនៅដេកយប់ស្ងាប់ទៅ ខ្ញុំឮស្នូរសំឡេងស្រែកពីលើខ្ញុំ សំឡេងថ្នូរ សំឡេងស្រែក ពីលើពួកខ្ញុំនៅ ហើយពួកខ្ញុំបីនាក់ហ្នឹង បាននិយាយគ្នាថា “តើកន្លែងនេះជាកន្លែងស្អីគេ? កន្លែងឃុំឃាំងអី? គុកអីគេ?” ព្រោះអត់ស្គាល់ ។

[១៤:២២:០២]

**ស៖** អគារដែលលោកស្រីអះអាងថា គេយកលោកស្រីទៅឃុំឃាំងហ្នឹង ធ្វើអំពីអ្វីទៅ? ធ្វើអំពីថ្ម ឬក៏ធ្វើអំពីឈើ?

**ឆ៖** ចាស, អគារហ្នឹងធ្វើអំពីថ្ម ហើយមានចាក់ការ៉ូ ដាក់ការ៉ូទៀត ហើយបង្អួចមានចម្រឹងដែក ។ បង្អួចពីរ មុខមួយ ក្រោយមួយ ហើយមានដាក់ចម្រឹងដែកខ្ទាស់ជិត ។

**ស៖** អំម្បាញ់មិញនេះ លោកស្រីបាននិយាយថា កាលពីព្រឹកលោកស្រីបាននិយាយថា អគារដែលគេដាក់ឃុំឃាំងលោកហ្នឹង គឺជាអគារបណ្តោយថ្ងៃ ។ អ៊ីចឹងមែនដែរទេ?

**ឆ៖** ចាស, គឺអគារបណ្តោយថ្ងៃហើយ នៅក្បែរជណ្តើរទៀត ។

**ស៖** លោកស្រីអាចពន្យល់បានទេ អាម៉េចហៅថា អាគារសង់បណ្តោយថ្ងៃហ្នឹងវាៗយ៉ាងម៉េច? ស្ថានយ៉ាងម៉េចទៅបានលោកស្រីអះអាងថាអគារហ្នឹង អគារបណ្តោយថ្ងៃ?

**ឆ៖** ចាស, អគារបណ្តោយថ្ងៃ គឺសង់ពីកើតទៅលិច ។ ថ្ងៃដើរពីកើតវាទៅលិច គឺអគារហ្នឹងគឺបណ្តោយអ៊ីចឹងតែម្តង ។

**ស៖** ក្រៅពីអគារមួយ ដែលលោកស្រីអះអាងថា គេយកលោកស្រីទៅឃុំឃាំងទីនោះ តើលោកស្រីកត់សម្គាល់ថា នៅទីនោះ ឬក៏ក្បែរទីនោះមានអគារអ្វីផ្សេងទៀតដែរឬទេ? លោកស្រីមានកត់សម្គាល់បញ្ហានេះដែរឬទេ?

**ឆ៖** ចាស, ខ្ញុំនៅចាំបានថា អគារបណ្តោយថ្ងៃហ្នឹង ហើយមានអគារផ្សេងទៀត ហើយនៅក្នុងជុំវិញមន្ទីរឃុំឃាំងហ្នឹង គេព័ន្ធដោយរបងសង្ក័សីព័ន្ធជុំវិញ ហើយយ៉ាងខ្ពស់ ។

**ស៖** លោកស្រីបានជាប់ឃុំឃាំងនៅទីនោះ តើលោកស្រីបានឮ ដែលឮសំឡេង ឬក៏បានកត់សម្គាល់នូវព្រឹត្តិការណ៍ណាមួយថា មានកុមារនៅទីនោះដែរឬទេ?

**ឆ៖** ខ្ញុំនៅក្នុងបន្ទប់ទីមួយ ខ្ញុំឮមាត់ក្មេងស្រែកយំ ឮជ្រូកស្រែក ហើយនៅក្នុងមន្ទីរឃុំឃាំងហ្នឹង ធុំក្លិនអត់ល្អសោះ ។ ធុំក្លិលស្អុយដូចអាចម៍ជ្រូក ហើយធុំក្លិនដូចគំរង់ស្អីម្យ៉ាង ដូចយើងថា ចាប់មិនបាន មិនដឹងក្លិនស្អី ។

[១៤:២៥:១៩]

**ស៖** ពេលគេចាប់លោកស្រី ឬក៏នាំលោកស្រីទៅដល់កន្លែងឃុំឃាំងហ្នឹង គេបានប្រាប់ទេ ថាតើ លោកស្រីមានកំហុសអ្វី ឬក៏មានរឿងអ្វីបានជាគេចាប់? តើគេមានប្រាប់អំពីមូលហេតុនៃការចាប់ខ្លួន ដែរទេ?

**ឆ៖** ចាស, លោកប្រធាន គេអត់មានសួរ អត់មានប្រាប់ទេ ។

**ស៖** ចុះពេលសួរចម្លើយដែលលោកស្រីបានអះអាងព្រឹកមិញថា អ្នកសួរចម្លើយនៅទីនោះ បាន សួរចម្លើយលោកស្រីរហូតដល់បីដង ។ សំណួរសួរថា អ្នកដែលសួរចម្លើយលោកស្រីហ្នឹង ជាមនុស្ស ប្រុស ឬក៏មនុស្សស្រី? ហើយមានគ្នាប៉ុន្មាននាក់ក្នុងពេលសួរចម្លើយម្តងៗ?

**ឆ៖** ចាស, នៅពេលសួរចម្លើយហ្នឹង មានគ្នាពីរនាក់ តែសំឡេងដែលសួរហ្នឹង នាងខ្ញុំចាំបានថា អត់មនុស្សចាស់ទេ គឺក្មេង អាយុប្រហែល ១៦, ១៧ឆ្នាំ អ្នកដែលសួរចម្លើយនាងខ្ញុំ ។

**ស៖** ជាមនុស្សប្រុស ឬក៏ជាស្ត្រី?

**ឆ៖** ជាមនុស្សប្រុស លោកប្រធាន ។ អត់មាននារីទេសួរខ្ញុំនោះ ។

**ស៖** ពីរនាក់សួរយ៉ាងម៉េចទៅ? ម្នាក់សួរ ម្នាក់សរសេរ? ឬក៏ម្នាក់សួរ ម្នាក់ឈរគំរាមកំហែង ឬក៏ប្រព្រឹត្តធ្វើអំពើអីផ្សេងទៀតចំពោះលោកស្រី?

**ឆ៖** ចាស, នៅពេលដែលគេសួរហ្នឹង ខ្ញុំមិនបានមើលឃើញថា គេសរសេរ ឬគេកត់អីទេ ព្រោះគេចងភ្នែកជិតអស់ហើយ ។ គ្រាន់តែសួរហើយយើងសួរថា "តើអ្នកធ្លាប់បានចូលរួមប្រជុំកន្លែង ស្ងាត់ មានគេអប់រំបំពាក់បំប៉នផ្នែកខាងខ្សែ *សេអ៊ីអា, កាហ្សេបេ* អីនោះ ដែរឬទេ នៅក្នុងកង?" នាងខ្ញុំ ថា "ខ្ញុំមិនដែលធ្លាប់ស្គាល់ ខ្សែ *សេអ៊ីអា, កាហ្សេបេ* នោះយ៉ាងម៉េចទេ ព្រោះនាងខ្ញុំនៅក្នុងកងមានតែ មួយមុខ គឺបើថាធ្វើស្រែដឹងតែធ្វើស្រែ ។ ស្ទូងដឹងស្ទូង ដកដឹងដក បាច់ទឹកស្នាចបញ្ចូលស្រែ ដឹងតែបាច់ ទឹក ។ អត់ស្គាល់ទេ ខ្សែ *សេអ៊ីអា* មិនដឹងយ៉ាងម៉េច" ។

**ស៖** ក្នុងអំឡុងពេល គេសួរចម្លើយលោកស្រី តើគេបានដាក់ខ្នោះជើងលោកស្រីដែរទេ?

**ឆ៖** ចាស, ចំពោះនាងខ្ញុំអត់ដាក់ទេ ។ តែគេចងដៃរឹតយ៉ាងតឹង ហើយគេធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរដែរ ពេលនោះនាងខ្ញុំភ័យខ្លាច គេវ៉ៃតែម្តង ឡើងពីរដង ចូលបីដងនាងខ្ញុំសន្លប់បាត់ទៅហើយ ។ ខ្ញុំភ័យខ្លាចពេក ។

**សៈ** អ្នកសួរចម្លើយហ្នឹង ចងដៃលោកស្រីយ៉ាងម៉េច? ដែលចងថាតឹងហ្នឹង ចងមកមុខ ឬក៏ចងព័ន្ធដៃទៅក្រោយ? ហើយចងនឹងរបស់អីទៅ? ជាខ្នោះដៃ ឬក៏ជាខ្សែ?

[១៤:២៨:៥៨]

**ឆ៖** ចាស, គេចងជាខ្សែៗលីឡុង ។ ចងទៅក្រោយយ៉ាងតឹង ។

**សៈ** អំមិញលោកស្រីប្រើពាក្យថា គេបានធ្វើទារុណលើលោកស្រី ម៉េចបានជាលោកស្រីអះអាងថាគេធ្វើទារុណកម្ម? តើបុគ្គលិកនៃអ្នកសួរចម្លើយហ្នឹង គេបានប្រព្រឹត្តសកម្មភាព ឬអំពើហិង្សាយ៉ាងម៉េច មកលើខ្លួន រូបរាង្គកាយរបស់លោកស្រី?

**ឆ៖** ចាស, ពេលដែលគេសួរយើងហើយ យើងឆ្លើយ ឆ្លើយសំណួរម្តង ឆ្លើយតែពីរដងទៅដាក់គេវ៉ៃៗហ្នឹងមិនមែនរំពាត់ខ្សែតីទេ គឺវ៉ៃក្នុងកូនដំបងតូចល្មម ។ បើវ៉ៃហ្នឹងខ្សែតី គឺឮឆ្វាចៗ តែនេះវ៉ៃហ្នឹងដំបងឮតែដុកៗ ។ ដាក់ហើយមួយទៀតកជើងនាងខ្ញុំមិនដឹងជាគេចាប់នឹងដែកដង្កាប់អីទេ គឹកជើងនាងខ្ញុំហ្នឹងដាច់សាច់ ហើយឈឺ នាងខ្ញុំឈឺ នាងខ្ញុំស្រែកថាអាដៃនាងខ្ញុំហ្នឹង គឺដាច់រលាកនៅស្នាមទាល់សព្វថ្ងៃ ដែលវាចងរឹតតឹងពេកហ្នឹង ។ ពេលនុំង ពេលដែលគេសួរ ហើយគេវ៉ៃ ហើយយើងអត់មានសំណួរអីឆ្លើយប្រាប់គេទៀត គេដាក់យើងផ្ងសៗទៀតទៅ ហើយមានជះទឹក ទឹកហ្នឹងពេលដែលយើងលិតទៅដូចជាទឹកអំបិល ដូចជាទឹកសាប៊ូ ជះដាក់មុខដាក់ក្បាលស្រោចពីលើមក ។

**សៈ** ក្នុងការសួរចម្លើយលោកស្រីម្តងៗហ្នឹង តាំងពីពេលចាប់ផ្តើមសួរ និងបានធ្វើអំពើហិង្សាទៅលើរាងកាយលោកស្រីហ្នឹងរយៈពេលប៉ុន្មានទៅបានជារហូតដល់លោកស្រីសន្លប់ហ្នឹង? រយៈពេលប៉ុន្មានទៅមួយលើកៗ? មួយព្រឹក មួយថ្ងៃ ឬក៏មួយម៉ោងពីរម៉ោង? និយាយពីពេលគេសួរ ហើយនិងគេបានប្រើអំពើហិង្សាក្នុងការសួរចម្លើយ ។

**ឆ៖** ចាស, គេសួរហ្នឹងគេប្រើទារុណកម្មហ្នឹងមិនយូរទេលោកប្រធាន គឺខ្ញុំតាមការឈឺចាប់របស់ខ្ញុំ ហើយនិងការបាត់ឈឺចាប់វិញប្រហែលជាសាមសិបនាទី លើសបន្តិចបន្តួច ។

**សៈ** ចុះលោកស្រីសន្លប់ដល់ពេលដឹងខ្លួនវិញ ពេលដែលត្រឡប់ទៅកន្លែងឃុំឃាំងគេធ្វើយ៉ាងម៉េច? គេសែងទៅ ឬក៏គេបណ្តើរលោកស្រីដូចដែលគេបណ្តើរមកសួរចម្លើយ?

**ធ៖** ចាស, នៅពេលដែលនាងខ្ញុំសន្លប់ទៅ គឺមិនមានសន្លប់មិនដឹងស្មារតីទេ ព្រោះភ័យពេកសន្លប់ទៅ តែដល់គេថាយកទៅកន្លែងគេក៏ចាប់ស្មាដៃម្ខាង ម្នាក់ក្រៀកហ្នឹង គេអូសយើងទៅបោះនឹងបន្ទប់ទុកទៅ ហើយគេស្រាយភ្នែកយើងបំភ្លឺ ។ ពេលគេចេញមកវិញ គេបិទទ្វារចាក់សោខាងក្រៅ ។ នាងខ្ញុំនៅដេកនៅហ្នឹងស្លូកស្លឹងទៅ ។

**ស៖** កន្លែងដែលគេសួរចម្លើយលោកស្រីហ្នឹងនៅទិសខាងណានៃអគារដែលទីកន្លែងដែលគេឃុំឃាំងលោកស្រី? ហើយមានចំងាយប៉ុន្មានពីកន្លែងឃុំឃាំង?

**ធ៖** តាមខ្ញុំចំណាំបាន ដើរសម្រឹបជើងស្ទូរជើង ដើរទៅទិសខាងជើង ហើយមិនឆ្ងាយប៉ុន្មានទេ ។ បើយើងដើរវិញប្រហែលជាមួយសន្ទុះដែរដល់កន្លែងគេ ។

**ស៖** ពាក្យមួយសន្ទុះហ្នឹងមិនដឹងឲ្យនិយមន័យថាម៉េចច្បាស់ទេ ។ អ៊ីចឹង បើដើរគិតជាជំហានប្រហែលជាប៉ុន្មានជំហានដល់?

**ធ៖** ចាស! ដើរហ្នឹងប្រហែលជាម្ភៃ-សាមសិបជំហានដល់ ។

**ស៖** ចុះកន្លែងដែលរស់នៅនោះ តើកន្លែងបត់ជើងបត់ដៃ បត់ជើងតូចបត់ជើងធំនោះយ៉ាងម៉េចដែរ? នៅកន្លែងណាទៅ?

**ធ៖** ចាស,លោកប្រធាន! ពួកខ្ញុំនៅក្នុងបន្ទប់នារីទាំងបីនាក់ហ្នឹងពេលដែលបត់ជើងពួកខ្ញុំឈឺតែបត់ជើងយប់ទេ ពេលដែលឈឺបត់ជើងពួកយើងធាក់ទ្វារហ្នឹងក្ទុងៗក្ទាំងៗក៏គេទៅសសៀរៗហ្នឹងអ្នកយាមហ្នឹងគេសួរថា “មានបញ្ហាអី កើតអីមិត្តនារី?” ពួកខ្ញុំថា “ឈឺបត់ជើង” ទៅគេក៏បើទ្វារ ហើយចងភ្នែកយើងបណ្តើរចេញមកក្រោមកឲ្យទៅបត់ជើង តែកន្លែងបត់ជើងហ្នឹងមិនដឹងជាបង្គន់ មិនដឹងជាអីលោកប្រធានខ្ញុំមើលមិនឃើញ ។

[១៤:៣៤:៥៤]

**ស៖** អ្នកយាមហ្នឹងមនុស្សប្រុស ឬមនុស្សស្រី?

**ធ៖** ចាស, អ្នកយាមហ្នឹង គឺប្រុស ។

**ស៖** ចុះងូតទឹក គេឲ្យងូតទឹកយ៉ាងម៉េច?

**ធ៖** ខ្ញុំទាំងបីនាក់ហ្នឹងនៅក្នុងមន្ទីរឃុំឃាំងដប់ប្រាំថ្ងៃហ្នឹង នាងខ្ញុំអត់ដែលងូតទឹកទេ ។ ទោះបីគេឲ្យងូត ក៏នាងខ្ញុំមិនទៅងូតដែរ ។

**ស៖** គេមានបានឲ្យអនុញ្ញាតឲ្យងូតទឹកដែរទេ?

**ឆ៖** គេហៅមិត្ត មឿន និងមិត្តយ៉ាត ឲ្យទៅងូតទឹកដែរ តែពេលដែលមិត្តមឿន និងមិត្តយ៉ាតទៅងូតទឹកទៅ អ៎!មិត្តមឿន ចេញទៅងូតទឹកមុនទៅមកវិញ ដូចមានអារម្មណ៍អត់ល្អវាថា "មិត្តម៉េត មិត្តយ៉ាត បើសិនជាគេហៅទៅងូតទឹកមិនបាច់ទៅទេ សុខចិត្តអត់ បើងាប់ក៏ងាប់ទៅមិនបានងូតទឹកក៏ងាប់ទៅចុះ មិនបាច់ងូតមិនបាច់អីទេ" ។

**ស៖** គេប្រាប់មូលហេតុអីដែរទេ?

**ឆ៖** ចាស, វាអត់មាននិយាយប្រាប់អីទាំងអស់ គ្រាន់ហាមថា បើសិនជាគេឲ្យទៅងូតទឹកមិនបាច់ងូតទេ សុខចិត្តនៅនឹងកន្លែងឃុំឃាំងហ្នឹង ។

**ស៖** អ៊ីចឹងបានសេចក្តីថា លោកស្រីជាមួយនឹងមិត្តភក្តពីរនាក់ទៀតក្នុងអំឡុងពេលនៃការឃុំឃាំងនោះ គេអត់មានហាមប្រាមលោកស្រីជាមួយមិត្តភក្តរបស់លោកស្រីមិនឲ្យនិយាយគ្នាទេ មែនទេ ព្រោះលោកស្រីនិយាយគ្នាជាច្រើនអំពីបញ្ហាអីផ្សេងៗអាចជជែកគ្នាបាន ។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស, លោកប្រធាន! នាងខ្ញុំអាចនិយាយគ្នាបាន តែយើងមិនមាននិយាយដោយចំហឮៗទេ គឺយើងគ្រាន់តែសម្លឹងគ្នាហើយអាចប្រាប់គ្នាជាសញ្ញា ព្រោះខ្លាចគេនៅខាងក្រៅឮ ។

**ស៖** ចុះរបបហូបចុកវិញហូបយ៉ាងម៉េចដែរ មួយពេលហ្នឹងប៉ុន្មានដង មួយថ្ងៃប៉ុន្មានពេល ហើយមួយពេលៗហ្នឹងរបបបានហូបបាយ ឬក៏បបរ ឬក៏ម្ហូបអ្វីទេ ហើយទៀងទាត់ទេ?

**ឆ៖** ចាស, លោកប្រធាន ។ ថ្ងៃដំបូងនាងខ្ញុំទៅ គេឲ្យហូបបបរ ក្នុងនោះមានកាគេ កា-- បើយើងនៅសមរភូមិវិញ គេហៅកាបត់ដាក់នឹងចង្កេះហ្នឹងមានដៃមានអីហ្នឹង ពេលហ្នឹងគឺយើងដកដៃកាទៅ គេដួសបបរដាក់ឲ្យ ហូបទៅ តែពួកខ្ញុំហូបអត់កើតទេរយៈពេលពីរបីថ្ងៃ ។ ពួកខ្ញុំអត់អាហារហូបអត់កើត គេឲ្យហូបមួយថ្ងៃពីរដង តែពួកនាងខ្ញុំហូបអត់កើតទេ បបរហ្នឹងនៅទុកព្រឹកដល់ល្ងាច ល្ងាចដល់យប់ សុំតែទឹកហូបទេ ។

[១៤:៣៨:០៦]

**ស៖** អ៊ីចឹងបានសេចក្តីថា របបដែលគេផ្តល់ឲ្យហ្នឹង ក្នុងអំឡុងពេលឃុំឃាំងហ្នឹងគឺពីរពេល ហើយមួយពេល គឺមានបបរមួយកា អ៊ីចឹងមែនទេ?

**ឆ៖** ចាស, លោកប្រធាន ។ មួយពេលហ្នឹងបបរវាអត់ពេញកាទេ គេដាក់តែមួយវែកក្រឡួមហ្នឹង គេដួសដាក់កាឲ្យឈ្ងុ តែមួយហ្នឹង ប្រវែងណោះពីក្តិតកា ។

**ស៖** ហើយកាហ្នឹងគេមានស្លាបព្រា ហើយគេយកត្រឡប់ទៅវិញទៀតពេលហូបរួចនោះ ឬក៏កានិងស្លាបព្រាហ្នឹង គេទុកនៅកន្លែងយើងឃុំឃាំងហ្នឹងរហូតដល់ពេលរបបមកដល់យើងយកដាក់បបរដែលគេចែកឲ្យ?

**ឆ៖** ចាស, កានិងស្លាបព្រាហ្នឹង គឺនៅនឹងកន្លែងដែលគេដាក់ឲ្យយើងហូបហ្នឹង ពេលដែលយើងហូបចាន អ៎! កានិងស្លាបព្រាហ្នឹងនៅនឹងកន្លែងដដែល ដល់ល្ងាចឡើងគេយកម្ហូបមកឲ្យទៀត គេចាក់ចោលអាចាស់ទៅ គេឲ្យអាថ្មីទៀត ។

**ស៖** អម្បាញ់មិញនេះ គឺលោកស្រីបាននិយាយពាក់ព័ន្ធនឹងការចូលមកដក់កន្លែងឃុំឃាំងហ្នឹង គឺគេដាក់បញ្ចូលឃុំឃាំងតែម្តងដោយមិនបានថតរូប ឬក៏ដកស្រង់នូវប្រវត្តិរូបផ្សេងៗរបស់លោកស្រីទេ ប៉ុន្តែនៅក្នុងពាក្យបណ្តឹងគឺមានឯកសារចំនួនពីរដែលពាក់ព័ន្ធជាមួយនឹងឯកសាររបស់លោកស្រី ហើយចាំលោកស្រីចាំមើល៍ តើឯកសារនេះវាពាក់ព័ន្ធយ៉ាងម៉េចចំពោះលោកស្រី ។

(មន្ត្រីសោតទស្សន៍ធ្វើការបញ្ចាំងនូវរូបថតដែលមានឯកសារលេខ ERN00343199 ជាភាសាខ្មែរនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។ )

លោកស្រី ជិន ម៉េត មើលរូបនេះមើល តើជារូបភាពអ្នកណាគេ? លោកស្រីស្គាល់ទេ?

**ឆ៖** ចាស, ជារូបនាងខ្ញុំផ្ទាល់តែម្តង ។ ពេលនោះ ខ្ញុំអាយុ១៩ឆ្នាំ ។

**ស៖** ម៉េចបានលោកស្រីដឹងថា លោកស្រីកាលណោះអាយុ១៩ឆ្នាំ តើរូបថតនេះ ថតនៅក្នុងឆ្នាំណា?

[១៤:៤១:១៧]

**ឆ៖** ចាស, រូបថតនេះថតនៅឆ្នាំ១៩៧៧ ហើយនិង៧៨ ពេលខ្ញុំនៅអង្គភាពក៏គេបានថតនាងខ្ញុំញឹកញាប់ដែរ ហើយពេលដែលខ្ញុំទៅនៅមន្ទីរស-២១ ក៏មេក្រុម មេកងខ្ញុំបានហៅខ្ញុំមកធ្វើប្រវត្តិរូប ហើយគេរូបនាងខ្ញុំដែរ ។

**ស៖** នៅស-២១ នៅមជ្ឈមណ្ឌលណាទៅដែលគេថាមេកងឲ្យធ្វើប្រវត្តិរូប ហើយថតរូបនោះ? នៅស-២១ ឬក៏នៅព្រៃស ។

**ឆ៖** នៅព្រៃសលោកប្រធាន នាងខ្ញុំនៅកង១៧ ប្រធានកងហ្នឹងឈ្មោះ បងញ៉ ។

**ស៖** អំពីកាលពីលោកស្រីនិយាយថា កាលពីលោកស្រីទៅនៅកង១៧ហ្នឹង លោកស្រីស្គមខ្លាំងណាស់ ហើយមុខសុទ្ធ កើតស្រែងទៀត ហើយមើលរូបនេះដូចជាមិនស្គមពេកដូចលោកស្រីនិយាយទេ

មែនទេ ឬក៏រូបហ្នឹងហើយ? ពេលលោកស្រីស្គមគឺមានកម្រិតប៉ុណ្ណឹង?

**ឆ៖** ចាស, ពីថតហ្នឹងគឺគេមិនមែន ពេលដែលនាងខ្ញុំទៅដល់កន្លែងកង១៧ហ្នឹង បងស្រីហ្នឹង រយៈពីរបីថ្ងៃបានបីថ្ងៃហ្នឹង គេបានហៅនាងខ្ញុំមកកន្លែងរោង កន្លែងគេធ្វើការដូចទីស្នាក់ការគេអ៊ីចឹង ហើយគេបានកត់ប្រវត្តិរូបហើយ គេថតទៀត ។

**ស៖** (មន្ត្រីខាងសោតទស្សន៍បន្តទៅឯកសារដែលមានលេខ ERN00343200) ។ លោកស្រីមើលរូបថតនេះ តើរូបថតអ្នកណាគេ? រូបថតលោកស្រី ឬនិងប្រវត្តិរូបផង តើជារបស់អ្នកណាគេ?

**ឆ៖** ចាស!រូបថតនេះជារូបថតខ្ញុំ បើតាមខ្ញុំចាំបាន ការធ្វើប្រវត្តិរូបនេះធ្វើនៅអង្គភាពចាស់ ធ្វើនៅកន្លែងកងពល៤៥០ កងពលទី៣ កង៤៥០នាងខ្ញុំហ្នឹង ហើយនៅក្នុងចុងឆ្នាំ១៩៧៧ គេបានហៅខ្ញុំក្នុងមួយខែបីដងធ្វើប្រវត្តិរូប ហើយថតរូបទៀត ។ ហើយគេសួរដូចប្រវត្តិរូបនៅក្នុង សួរពីភូមិកំណើត ស្រុកខេត្ត ក្រុង ហើយនិងមុខរបរឪពុកម្ដាយហ្នឹង ។ ឪពុកម្ដាយរស់ឬស្លាប់? មុខរបរការដែលខ្ញុំ នាងខ្ញុំចូលបម្រើបដិវត្តន៍ហ្នឹង នាងខ្ញុំដាក់ប្រវត្តិរូបខ្ញុំកសិករក្រ តែពេលដែលគេតាមដានប្រវត្តិរូបនាងខ្ញុំទៅ គេទៅដល់ផ្ទះនាងខ្ញុំ គេបានស៊ើបប្រជាជននិងប្អូននៅហ្នឹង គេថា វាជាកូនប៉ូលិស សែហ្វ ជិនៗ ហ្នឹង គាត់នៅធ្វើការនៅភ្នំពេញ គាត់មិនដែលមកនៅស្រុកទេ តែកូនហ្នឹងគឺរស់ដោយសារជីដូនចិញ្ចឹមទេ អត់មានពាក់ព័ន្ធអីជាមួយឪពុកទេ តែឪពុកហ្នឹងផ្ដល់ជាសម្ភារៈ ជាលុយកាក់មកចិញ្ចឹមកូនហ្នឹង ។ ទៅបានគេដាក់ខ្ញុំថាវណ្ណៈកសិករកណ្ដាល ថ្នាក់កណ្ដាលទៅវិញ ។

[១៤:៤៥:១៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដើម្បីជាប្រតិចារឹក ខ្ញុំចង់បង្ហាញថា ខ្ញុំចង់បញ្ជាក់ថា ឯកសារដែលបង្ហាញនៅលើនេះ គឺបានបង្ហាញបានបកប្រែជាភាសាអង់គ្លេស ហើយមានលេខ ERN00347466 ដល់លេខ00347467 ។ ឯកសារអម្បាញ់មិញនេះ គឺជាឯកសារប្រវត្តិរូបដែលមានលេខ E2/80/4.2 ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលម៉ោងសម្រាកហើយអង្គជំនុំជម្រះប្រកាសសម្រាក់ម្ភៃនាទី រហូតដល់ម៉ោងបី ប្រាំនាទី សូមអញ្ជើញ សូមបន្តដំណើរការសវនាការទៀត ។ អ៊ីចឹង សូមសាធារណជនអញ្ជើញចូលមក

កាន់សាលសវនាការឲ្យបានមុនម៉ោងកំណត់ ។

មន្ត្រីតុលាការសម្របសម្រួលដល់ដើមបណ្តឹងរូបនេះឲ្យបានមានកន្លែងសម្រាកសមរម្យ ។

*[សវនាការសម្រាកពីម៉ោង១៤:៤៧នាទី ដល់ម៉ោង ១៥:០៨ នាទី]*

**សួរដោយប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចពិភាក្សាដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ជិន ម៉េត ។

**ស៖** ជិន ម៉េត នៅក្នុងអំឡុងពេលនៃលោកស្រីជាប់ឃុំឃាំងនៅកន្លែងដែលគេចាប់ដាក់ឃុំឃាំងលោកស្រីដប់ប្រាំថ្ងៃ ដប់ប្រាំយប់នោះ តើលោកស្រីដឹងថា មានរឿងហេតុយ៉ាងម៉េចចំពោះមិត្តលោកស្រីពីរនាក់ដែលទៅជាប់ទីនោះ មុនលោកស្រីដែរឬទេ?

**ឆ៖** ចាស, លោកប្រធាន មិត្តមឿន មិត្តយ៉ាត ពីរនាក់ដែលគាត់ទៅមុនខ្ញុំ ក៏ខ្ញុំអត់ដឹងរឿងរបស់គេដែរ មិនដឹងគេមានបញ្ហាអ្វីទេ បានគេទៅជាប់មុនខ្ញុំនៅក្នុងបន្ទប់ហ្នឹង ។

**ស៖** យើងចង់ដឹងថា បុគ្គលិកនៅទីនោះគេបានប្រព្រឹត្តអ្វីខ្លះលើពីរហ្នឹង គឺមិត្តមឿន ហើយនិងមិត្តយ៉ាត ដែលលោកស្រីអះអាងថាស្គាល់គ្នាពីមុនមកនោះ ហើយជាប់ឃុំឃាំងនៅទីនោះមុនលោកស្រីនោះ?

**ឆ៖** ចាស, នាងខ្ញុំមិនបានដឹងអ្វីទាំងអស់ ព្រោះអត់ប៉ានសួរគ្នាទេ ពេលដែលគេសួរមិត្តយើងម្នាក់ៗ ពេលចូលទៅវិញ អត់ដែលប៉ានសួរគ្នាថា គេធ្វើយ៉ាងម៉េចៗ លើរាងកាយគេម្នាក់ៗហ្នឹង នាងខ្ញុំអត់ដែលបានសួរគេទេ ។

**ស៖** គេនាំគាត់ទាំងពីរនាក់ទៅសួរចម្លើយដូចលោកស្រីដែរឬទេ? ក្នុងអំឡុងពេលដែលលោកស្រីទៅនៅទីនោះដប់ប្រាំថ្ងៃ ដប់ប្រាំយប់នោះ តើលោកស្រីឃើញគេនាំគាត់ទៅសួរចម្លើយដែរឬទេ?

**ឆ៖** ចាស, គេនាំដែរ ពេលដែល នេះគេហៅទៅម្តងម្នាក់លោកប្រធាន ។

**ស៖** ពេលគាត់ត្រឡប់មកវិញ ឃើញស្ថានភាពរូបរាងកាយគាត់យ៉ាងដូចម្តេចដែរឬទេ?

**ឆ៖** ចាស, បើមិត្តមឿន វិញ គាត់រាងតូចល្អិតផង ហើយគាត់រាងឈឺផង ពេលមកវិញ គាត់ដូចមានអាការៈភ័យខ្លាច ហើយទ្រុឌទ្រោម អឺ! គាត់យំរហូត គាត់អត់មាននិយាយទាំងអស់ ហើយក្បាលគាត់គ្រវីជាប់រហូត ។

**ស៖** ចំពោះលោកស្រីផ្ទាល់ ដែលគេបានប្រព្រឹត្តិមកលើលោកស្រីនៅក្នុងអំឡុងពេលសួរចម្លើយ ៣លើក ដោយមានការវាយនឹងដំបង ហើយមានជះទឹកដែលលោកស្រីអះអាងថា ប្រហែលជាទឹកអំបិល ឬក៏ទឹកលាយសាប៊ូ ។ តើគេបានប្រព្រឹត្តធ្វើប្រើអំពើហិង្សាលើរាងកាយលោកស្រី តាមទម្រង់ផ្សេងទៀត ដែរឬទេ? ដូចជាឆក់ខ្សែភ្លើងអីជាដើម តើមានដែរឬទេ?

[១៥:១២:៣៥]

**ឆ៖** ការឆក់ខ្សែភ្លើង ឬលើរាងកាយនាងខ្ញុំគ្មានទេ គ្រាន់តែគេជះទឹកសាប៊ូ ហើយនិងទឹកត្រី ព្រោះកាលណាដែលគេជះទឹកមក យើងលិឍ យកអណ្តាតលិឍទៅ មានជាតប្រៃ ហើយនិងមានជាតិធុំក្លិនសាប៊ូ អាសាប៊ូដុំយើងពីជំនាន់នោះ គេប្រើតែសាប៊ូដុំ ធុំក្លិនទឹកសាប៊ូ តែការប្រើទារុណកម្ម លើកទីមួយ លើកទីពីរ លើកទីបី គឺដូចគ្នាដដែល ។

**ស៖** ទិដ្ឋភាពផ្សេងទៀត ក្រៅពីគេប្រព្រឹត្តចំពោះលោកស្រី ហើយនិងមិត្រភក្តិលោកស្រីពីរនាក់ ដែលបានទៅជាប់ឃុំឃាំងនៅទីនោះជាមួយលោកស្រី តើលោកស្រីបានឃើញ សង្កេតឃើញទិដ្ឋភាពនៃនាក់ជាប់ឃុំឃាំងផ្សេងទៀត តើគេប្រព្រឹត្តយ៉ាងណាចំពោះពួកគេ?

**ឆ៖** ចាស, លោកប្រធានសូមបញ្ជាក់ថា តើលើពួកគេមាននារីពីរនាក់ដែលនៅជាមួយខ្ញុំ ឬក៏គេនៅក្រៅឃុំផ្សេងទៀត ។

**ស៖** អ្នកឃុំឃាំងផ្សេងទៀត ដែលលោកស្រីឮមាត់ស្រែកផ្នែកខាងលើលោកស្រីហ្នឹង តើលោកស្រីឃើញទិដ្ឋភាពនៃការប្រព្រឹត្តអំពើផ្សេងដោយបុគ្គលិកនៃមន្ទីរឃុំឃាំងនៅទីនោះ ចំពោះពួកគេក្រៅពីលោកស្រី ហើយនិងមិត្រភក្តិលោកស្រីហ្នឹង តើលោកស្រីបានឃើញទិដ្ឋភាពអីផ្សេងដែរទេ ក្នុងការប្រព្រឹត្តអំពើដោយបុគ្គលិកចំពោះអ្នកដែលជាប់ឃុំឃាំងទាំងនោះ?

**ឆ៖** លោកប្រធាន! ពួកនាងខ្ញុំនៅក្នុងបន្ទប់ គឺឮបានតែឮសំឡេងទេ គឺមិនអាចមើលឃើញអ្វីទាំងអស់ ។ គ្រាន់តែឮសំឡេងនោះ សំឡេងទុក្ខសោក សំឡេងឈឺចាប់ សំឡេងថ្ងូរ ដូចរៀបដាច់ខ្យល់អ៊ីចឹងពេលដែលឮសំឡេងទៅ នាងខ្ញុំដេកផ្ទាល់ហ្នឹងឥដ្ឋ និងការ៉ូហ្នឹងទៅ ស្តាប់ទៅ ឮសំឡេងហ្នឹងដូចមានការទុក្ខសោក ឈឺចាប់យ៉ាងខ្លាំង ។

**ស៖** លោកស្រីគិតមើលថា នៅក្នុងអំឡុងពេលលោកស្រីជាប់នៅទីនោះ គឺនៅក្នុងបន្ទប់តូចល្មមហ្នឹង គឺមានតែបីនាក់ទេ គឺលោកស្រី ហើយនិងមិត្រភក្តិលោកស្រីពីរនាក់ទៀត ។ តើលោកស្រីមានព័ត៌-មាន ឬក៏ស្តាប់នូវសំឡេងនៅទីនោះ មានកន្លែងផ្សេងទៀត បន្ទប់ផ្សេងទៀត ក្រៅពីបន្ទប់លោកស្រីហ្នឹង

តើមានមនុស្សស្ត្រីនៅជាប់ឃុំឃាំងនៅទីនោះដែរឬទេ?

**ឆ៖** ចាស,លោកប្រធាន នៅខាងស្តាំដៃខ្ញុំ បន្ទប់ខាងស្តាំដៃ នាងខ្ញុំឮមាត់រអ៊ូៗជាស្ត្រីដូចនាងខ្ញុំដែរ ។

[១៥:១៥:៤៦]

**ស៖** លោកស្រីបានអះអាងថា គេបានបញ្ជូនលោកស្រីចេញពីទីនោះទៅកាន់អង្គភាពថ្មីមួយទៀត គឺកង១៧ ។ ទីមួយសួរថា តើការបញ្ជូនចេញនោះ គេបញ្ជូននៅពេលណា ហើយការបញ្ជូនចេញហ្នឹងដោយរបៀបណា?

**ឆ៖** ចាស,លោកប្រធាន នៅពេលដែលគេបញ្ជូនពួកខ្ញុំចេញទៅក្រៅហ្នឹង ពេលនោះពួកនាងខ្ញុំទាំងបីហ្នឹងមានអារម្មណ៍ថា យើងបើគេបញ្ចេញពីនេះ ប្រហែលជាគេកទៅសម្លាប់ចោលហើយ ព្រោះពេលដែលចេញមកគេចងគ្នា ចងដៃជាប់ទាំងអស់គ្នា ហើយយកមកដាក់ឡាន ។ ដាក់ឡាន ចូលក្នុងឡានហើយចេញទៅ ។ ពេលព្រឹក តែម៉ោងប៉ុន្មានៗ នាងខ្ញុំអត់បានចាំទេ ។

**ស៖** ហើយចាកចេញ-- រថយន្តហ្នឹងចាកចេញពីកន្លែងឃុំឃាំងហ្នឹងទៅឆ្ងាយទេ ទើបគេដោះលែងលោកស្រីនោះ?

**ឆ៖** ពេលដែលឡើងរថយន្តទៅ រថយន្តនោះបើកទៅ ចេញដំណើរទៅ តាមខ្ញុំស្តាប់ សំឡេងរថយន្តចេញទៅត្បូងវិញ ចេញទៅឆ្ងាយ ជិះទម្រាំតែយើងរោយចង្កេះរោយខ្នង ។ ដល់ពេលនោះឮសំឡេងច្របាច់ស៊ីផ្លេឡានហ្នឹង ទេតៗ! ឃើញបត់ចុះបត់ឡើងៗ ចូលទៅដល់កន្លែងហ្នឹង គេហៅមិត្តនារីហ្នឹងមក ។ ហៅហើយគេឈប់ឡានលោកប្រធាន ។

**ស៖** ហើយឃើញធ្វើម៉េចទៀត ឈប់ឡានហើយ?

**ឆ៖** ពេលដែលឡានឈប់ហើយ អ្នកដែលសន្តិសុខការពារពួកខ្ញុំបីនាក់ហ្នឹងក៏បានស្រាយចំណងដៃ ហើយស្រាយភ្នែកយើងហើយថា "មិត្តនារីឯង ខ្ញុំប្រគល់ឲ្យគេនៅកន្លែងនេះហើយ" ។

**ស៖** ចុះពីរនាក់ទៀត មិត្រភក្តិលោកស្រីគាត់ទៅណា?

**ឆ៖** ចាស, ពីរនាក់ហ្នឹង ចុះនៅជាមួយគ្នាតែម្តងលោកប្រធាន នៅកង បញ្ចូលក្នុងកង បងញ៉ូនៅ១៧ហ្នឹងជាមួយគ្នាហ្នឹង ។

**ស៖** ទៅដល់ជួបស្ត្រីហ្នឹង គេនាំលោកស្រីធ្វើដំណើរបន្តទៅទៀត ឬក៏ទៅដល់ហ្នឹង ទីតាំងការដែលគេប្រគល់ការងារឲ្យលោកស្រីធ្វើ ហើយរស់នៅទីនោះតែម្តង? ឬក៏ត្រូវធ្វើដំណើរជាបន្តទៅទៀត

ហើយបើធ្វើដំណើរទៀត ដោយមធ្យោបាយអ្វីទៅ? ហើយអំឡុងពេលប្រហែលប៉ុន្មានបានទៅដល់អង្គភាព ដែលលោកស្រីបានរស់នៅ និងធ្វើការនៅទីនោះ?

[១៥:១៩:១០]

**ឆ៖** ចាស, នៅពេលដែលបងស្រីហ្នឹង គាត់មកទទួលពួកនាងខ្ញុំទាំងបីនាក់ហើយ គាត់ក៏បានកត់ឈ្មោះ កត់អីនាងខ្ញុំហើយ គាត់ថា "មិត្តឯងនាំគ្នាអង្គុយម្ដុំត្រង់ហ្នឹងហើយ ចាំគេហៅមិត្តនារីផ្សេងទៀតយកសម្ភារៈមកឱ្យធ្វើ" ពេលនោះពួកខ្ញុំអង្គុយទល់ខ្នងគ្នា ហើយដៃខ្ញុំដំបៅ ហើយជើងខ្ញុំក៏ដំបៅដែរ ហើយមិត្តមឿន និងមិត្តយ៉ាត នោះខ្នងគាត់បែកជាំ បែកឈាម ។ ហើយពួកយើងហ្នឹងបានលាត់ខ្នងឱ្យគ្នាមើល ហើយខ្ញុំលាត់ដៃ លាត់ជើងឱ្យមើលទៅថា "អី! ប្រហែលជាយើងបានរួចផុតពីស្លាប់ហើយមកនៅនេះ! ចាំមើលគេឱ្យយើងធ្វើអ្វី?" ដល់មួយសន្ទុះក្រោយមក ឃើញមិត្តនារីហ្នឹងកាន់ចប កាន់ចប ហើយនិងប៉ែលម្នាក់មួយៗមក យកមកហុចឱ្យពួកខ្ញុំថា "នែ៎! មិត្តនារីឯងយកចបនេះទៅ ហើយពូនរងដំឡូងក្នុងម្នាក់ឱ្យបានដប់រង" ដំឡូងហ្នឹងនៅផ្ទះៗ ហ្នឹងនៅក្នុង ដំឡូងដាំជុំវិញផ្ទះហ្នឹង ។ ពួកខ្ញុំក៏ចាប់ផ្ដើមពូនរងដំឡូងហ្នឹងតែម្ដង គេអត់មានឱ្យ បាយស៊ីទេ គេឱ្យធ្វើពលកម្មសិន ។

**ស៖** អ៊ីចឹងកន្លែងនោះ គឺកន្លែងដែលលោកស្រីរស់នៅ និងធ្វើការទីនោះរហូត មុនពេលលោកស្រីចាកចេញទៅស្រុកដាំបន្លែ ស្រុកស្អាងដើម្បីដាំបន្លែមែនទេ ដែលគេហៅថា កង១៧នោះ មែនទេ?

**ឆ៖** ចាស, លោកប្រធាន ខ្ញុំទៅនៅអត់មានផ្លាស់ទីតាំងទៅណាទៀតទេ នៅផ្ទះហ្នឹងរហូត តែប្លែកត្រង់ថា ផ្ទះហ្នឹងគេធ្វើតំរៀបជួរគ្នាដូចជាផ្ទះរបបបួនប្រាំ បួននិងប្រាំម៉ែត្រហ្នឹង តែជុំវិញសុទ្ធដំណាំគេ មានចេក មានដំឡូង ខ្នុរ ហើយពេលដែលពួកនាងខ្ញុំរស់នៅហ្នឹង ទៅដំបូងក្រុមខ្ញុំមានគ្នាដប់ពីរនាក់។ នៅបាន ពួកនាងខ្ញុំទៅនៅទាំងបីនាក់ហ្នឹងជាក្រុមជាមួយគ្នា តែបានតែពីរយប់ទេ មិត្តយ៉ាត មិត្តមឿនបាត់ខ្លួនទៅ ។ ហើយក្រុមផ្សេងទៀត ខ្ញុំមើលទៅឃើញស្ថានភាពដូចគ្នា បាត់យូរៗ បាត់ខ្លួន យូរបាត់ខ្លួនអស់ ប្លែកៗអ្នកថ្មីមកទៀត បាត់អ្នកចាស់អស់ ។

**ស៖** លោកស្រីស្គាល់អតីតគុកព្រៃសដែរទេ?

**ឆ៖** នាងខ្ញុំអត់ដែលស្គាល់ថា គុកព្រៃសហ្នឹងនៅកន្លែងណា គុកស-២១ ហ្នឹងនៅកន្លែងណា ទេកាលនោះ តែពេលដែលរស់នៅយូរៗទៅបានឮពួកមិត្តដែលនៅជាមួយគ្នាហ្នឹង គេថាកន្លែងនេះជាកន្លែងគុកព្រៃស គេហៅថា កន្លែងលត់ដំ សម្រាប់អ្នកដែលធ្វើខុស ។

**ស៖** យើងមិនសួរអ៊ីចឹងទេ យើងសួរចង់ដឹងថា ទីតាំងគុកព្រៃស នៅក្នុងរបបចាស់ហ្នឹងណា ពី របប លន់ នល់ របប សីហនុ មកនុ៎ង ពីមុនឆ្នាំ១៩៧០ ១៩៧៥ ហ្នឹងគឺមានគុកមួយ គុកនៅទីនោះ គេធ្វើយូរហើយ ហើយគេហៅថា គុកព្រៃស តើលោកស្រីស្គាល់ទីតាំងគុកព្រៃសនោះដែរឬទេ? ទីតាំងចាស់ចាស់ណា គុកចាស់?

**ឆ៖** ចាស, នាងខ្ញុំមិនដែលស្គាល់ទេ ព្រោះនាងខ្ញុំមិនដែលបានដើរដល់ ហើយមិនដែលបានស្គាល់ធ្លាប់ស្គាល់នៅជុំវិញទីក្រុងផង ។ អត់ដែលស្គាល់ទេ លោកប្រធាន ។

[១៥:២២:៤៧]

**ស៖** ចំណុចដែលលោកស្រីទៅរស់នៅទីនោះ ដែលលោកស្រីអះអាងថា មានផ្ទះដូចៗគ្នា ឬក៏ផ្ទះ គំរូដូចៗគ្នា ដែលមានដំណាំដំឡូងអីនៅព័ទ្ធជុំវិញផ្ទះ ហើយលោកស្រីអះអាងថា លោកស្រីនៅទីនោះរហូតដែលបញ្ជាក់ថាគឺជានៅក្នុងកង១៧ ។ សំណួរសួរថាអាទីតាំងត្រង់នុ៎ងកន្លែងនុ៎ងគេហៅភូមិសាស្ត្រនុ៎ងគេហៅអីទៅ គេឲ្យឈ្មោះថាម៉េចដែរ?

**ឆ៖** ខ្ញុំមិនបានស្គាល់ថាឈ្មោះភូមិនោះ ជាឈ្មោះភូមិអ្វីទេ តែនៅជិតវត្តក្រពើហា ហើយភូមិដាច់ៗពីគ្នាមានតែវាលស្រែ ហើយមានភូមិគេដាច់ៗគ្នា ហើយមានកង កង១៧ មានកង១៦ អ៊ំ១៤ ។ ហើយកងផ្សេងទៀតនាងខ្ញុំអត់ដឹងទេ ទាល់តែពេលដើរធ្វើការទៅបានជួបគ្នា តែអត់ស្គាល់ថាភូមិហ្នឹងគេហៅភូមិអីទេ លោកប្រធាន ។

**ស៖** នៅវត្តក្រពើហាហ្នឹងនៅខាងណាស្ទឹង? មានស្គាល់ឃើញស្ទឹងទេ មានស្ទឹងមួយមែនទេ? នៅខាងណាស្ទឹង?

**ឆ៖** ចាស, វត្តក្រពើហា បើខ្ញុំចាំបាននៅខាងជើងស្ទឹង ។

**ស៖** ហើយលោកស្រី ទីតាំងលោកស្រី ដែលថានៅកង១៧ហ្នឹង នៅខាងណា? នៅនឹងវត្តក្រពើហា នៅខាងជើងស្ទឹងហ្នឹង ឬក៏នៅខាងត្បូងស្ទឹង?

**ឆ៖** ចាស, នៅខាងជើងស្ទឹងដែរ តែនៅភូមិដាច់ៗពីគ្នា ។

**ស៖** នៅចម្ងាយប្រហែលជាប៉ុន្មានពីវត្តក្រពើហា?

**ឆ៖** នៅឆ្ងាយប្រហែលជាប្រាំ ប្រាំមួយគីឡូពីគ្នាដែរ ។ បើនាងខ្ញុំដើរធ្វើស្រែ ដើរធ្វើស្រែទៅ ថា មិត្ត ក្រុមមិត្តនារីឯងទៅខាងវត្តក្រពើហា យើងដើរទៅប្រហែលជាមួយព្រឹក មួយម៉ោងទៅពីរម៉ោង ដើរហ្នឹង ដើរយ៉ាងស្វាហាប់ យ៉ាងលឿនៗ បានដើរទៅជិតវត្តហ្នឹង ។

**ស៖** នៅទីនោះគេ តើមានមនុស្សប្រភេទណាខ្លះដែលរស់នៅទីនោះ ដូចជាមនុស្ស បុរស ស្ត្រី កុមារ ហើយមនុស្សចាស់ជាដើម តើមានមនុស្សប្រភេទណាខ្លះនៅទីនោះ?

**ឆ៖** អ្នកដែលនៅរស់នៅតាមកងនីមួយៗនៅទីនោះ មានគេចែកជាកង មានអ្នកគ្រប់គ្រងមើលកុមារមួយកងផ្សេង តែអត់ដឹងកងគេលេខប៉ុន្មានទេ ហើយកងនារីដែលមានប្តី មានកូន គេដាក់កង ១៤ ។ ឯចំណែកខ្ញុំជានារីអត់ទាន់មានប្តី គេហៅកងនារី កងស្រួច គេដាក់កង១៧ ។ ហើយឯបុរសវិញនាងខ្ញុំមិនដឹង មិនស្គាល់ទេ មិនដែលស្គាល់កន្លែងបុរសនៅទីណាទេ ។

[១៥:២៦:៣០]

**ស៖** ក្នុងអំឡុងពេលដែលលោកស្រីរស់នៅទីនោះ តើពេលយប់គេដាក់នៅ ឲ្យដេកនៅកន្លែងណា ហើយគេចាត់វិធានការយ៉ាងម៉េចខ្លះ ចំពោះមនុស្សទាំងអស់នុ៎ង រួមទាំងលោកស្រីផង?

**ឆ៖** ចាស, នៅពេលដែលគេសម្រាកផុតពីម៉ោងពីធ្វើការ នៅពេលសម្រាក គឺគេឲ្យសម្រាកជាក្រុម ហើយក្នុងមួយក្រុមមានដប់ពីរនាក់ៗ ពួកខ្ញុំសម្រាកនៅជាន់ក្រោមគេមានដាក់គ្រែ ។ ផ្ទះហ្នឹងផ្ទះឈើគេធ្វើ ដូចផ្ទះរបបអឺចឹង វាមានអាលើហ្នឹងមានរនាបឫស្សីគេមានបាំងជញ្ជាំងស្លឹកត្នោត ប្រក់ស្លឹកត្នោត ហើយក្រោមហ្នឹង គេមានរ៉ែគ្រែៗ ជើងគ្រែហ្នឹងជាប់ៗនឹងដីហ្នឹង គេបោះជាប់ៗដី គេបោះរនាបឫស្សីទៅដេកមួយគ្រែពីរនាក់ៗ ហើយក្រុមទីមួយដេកខាងក្រោម ក្រុមទីពីរដេកខាងលើ ខាងផ្ទះមួយដេកពីរក្រុម ហើយមានមេក្រុម មេកង គេឲ្យយាម ដាក់វេណយាមពួកនាងខ្ញុំហ្នឹង ។

**ស៖** មេក្រុម មេកង លោកស្រីហ្នឹងបានន័យថា សុទ្ធតែជាមនុស្សស្រីទាំងអស់មែនទេ?

**ឆ៖** ចាស, មេក្រុម មេកងខ្ញុំសុទ្ធជាមនុស្សស្រីទាំងអស់ ហើយសុទ្ធតែនៅលីវ អត់មាននរណាមានប្តីទេ ។

**ស៖** មេកងធំជាងគេហ្នឹងនៅទីនោះ កង១៧ហ្នឹង ឈ្មោះអីច្បាស់លាស់?

**ឆ៖** ខ្ញុំស្គាល់តែមេកងតូចទេ ឈ្មោះ បងញ៉ ហើយមួយទៀតឈ្មោះ បងអាង ហ្នឹងមេកងតូចក្នុង គ្នាចំណោមសាមសិបនាក់ជាងហ្នឹង គាត់ពីរនាក់ហ្នឹងគ្រប់គ្រង ក្តាប់ ។

**ស៖** លោកស្រីដឹងទេថា មនុស្សទាំងអស់ដែលនៅជាមួយលោកស្រីសុទ្ធតែជាស្ត្រី សុទ្ធតែជានារី នោះគាត់ជាជនស៊ីវិល ឬក៏ជាអតីតសុទ្ធតែជាចេញមកពីប្រភពកងទ័ពដូចលោកស្រីដែរ?

**ឆ៖** តាមដែលពួខ្ញុំនៅយូរៗទៅស្គាល់គ្នាទៅ សួរគេទៅ ខ្លះគេថា គេមកពីក្រសួង ខ្លះគេថា មកពីកន្លែងចិញ្ចឹមសត្វ មកពីកន្លែងកសិកម្ម ខ្លះគេថាគេមកពីខេត្ត ។

**ស៖** ចុះរបបធ្វើការងារនៅទីនោះ ការងារគេប្រគល់ឲ្យការងារធ្វើហ្នឹងយ៉ាងម៉េចដែរ? ហើយកំណត់ពេលវេលាពេលម៉ោងធ្វើការងារអីយ៉ាងម៉េច?

**ឆ៖** ចាស, ពេលធ្វើការងារ គេកំណត់ឲ្យយើងថា ដឹងតែម៉ោងបួនភ្លឺដើរ បើថាស្ទូងស្រូវ ដឹងតែដល់ ភ្លឺស្រែម៉ោងបួនភ្លឺ មុននឹងមកដល់ភ្លឺស្រែ មកពេលដែលយើងក្រោកពីដេក តម្រង់ជួរហើយរៀបចំសម្ភារៈ បើថាស្ទូងមានឈើច្រាន ហើយនិងចប ហើយម៉ោងបួនភ្លឺដឹងតែដល់ភ្លឺស្រែម្ដង ចាប់ផ្ដើមស្ទូង ហើយពេលសម្រាកម៉ោងប្រាំពីរជាង គេឲ្យសម្រាកដប់នាទី ។ សម្រាកដប់នាទី ហើយចុះធ្វើទាល់ដល់ម៉ោងដប់មួយថ្ងៃត្រង់ សម្រាកហូបបាយ សម្រាកហូបបាយ ហូបបបរហ្នឹង ដល់ម៉ោងមួយចុះធ្វើទៀត តែពេលល្ងាចអត់មានពេលសម្រាកទេធ្វើទាល់ដល់ បើសម្រុក ឧទាហរណ៍ថាបើធ្វើស្រែក្នុងមួយហិចតាហ្នឹងមួយក្រុមហ្នឹងថាបើរួចមុនផែនការម៉ោងប្រាំ ហើយយើងបានសម្រាកតាំងមុនពេលដែលកំណត់ ។ បើធ្វើមិនរួចទេស្ទូងទាល់តែយប់ម៉ោងប្រាំមួយ ម៉ោងប្រាំពីរធ្វើទាល់តែរួចហ្នឹង បាន១សម្រាកហើយហូបបាយ បានដេកតែម្ដង ។

[១៥:៣១:១៦]

**ស៖** អំមិញលោកស្រីនិយាយពីរឿងរបបហូប ហូបបាយ ឬក៏ហូបបបរ ដូចជានិយាយទាំងពីរពាក្យ ឬក៏ហូបបាយផង ហូបបបរផង?

**ឆ៖** ចាស លោកប្រធានអត់មានបាយហូបទេ ជំនាន់នោះតែបបរទេ តែខ្ញុំធ្លាប់និយាយហូបបាយ យើងនេះទៅ ច្រឡំថាហូបបាយ ហូបតែបបរទេ បបរក្នុងម្នាក់មានតែមួយវែកក្រឡូមយើងទេ ។ អត់ មានថែមទេ តែសម្ល គឺមានថែមច្រើន ។

**ស៖** លោកអាចរៀបរាប់អំពីឈ្មោះភូមិសាស្ត្រ នៅតំបន់ដែលលោកស្រីទៅនៅក្នុងកង១៧ ភូមិសាស្ត្រនានានៅជុំវិញតំបន់ទីនោះ ដែលលោកស្រីបានទៅធ្វើការ ទៅជីកទំនប់ ទៅស្ទូងស្រូវ ទៅធ្វើអ្វី១ដែលតាមការចាត់តាំងរបស់មេកងនោះ ថាតើលោកស្រីស្គាល់ឈ្មោះភូមិសាស្ត្រនៃតំបន់ទីនោះ នៅកន្លែងណាខ្លះដែលលោកស្រីស្គាល់ លោកស្រីអាចនិយាយប្រាប់អង្គសវនាការបានដែរទេ?

**ឆ៖** ចាស, នាងខ្ញុំចាំបានថា នៅព្រៃកជ្រៃមួយ ហើយព្រៃកហូរមួយ វត្តក្រពើហាមួយ ហើយនិងវត្តឫស្សីសាញ់ ចាំបានមួយជុំវិញហ្នឹង នាងខ្ញុំបានដើរធ្វើស្រែ លើកប្រឡាយ ជីកប្រឡាយ លើកទំនប់ លើកភ្លឺស្រែអីនៅតាមជុំវិញទីតាំងហ្នឹង ។

**ស៖** លោកស្រីនិយាយអំមិញថា មានកុមារដែលមានមនុស្សចាស់មើលថែទាំ កុមារនៅទីនោះមានចំនួនច្រើនទេ?

[១៥:៣៣:៣៥]

**ឆ៖** ចាស, កុមារហ្នឹង ខ្ញុំមិនអាចដឹងថា នៅក្នុងកងហ្នឹងមានច្រើនទេ តែពេលដែលព្រឹកឡើង ពួកខ្ញុំចេញធ្វើការកុមារក៏បានចេញទៅធ្វើការដែរ គឺផ្នែកគេឲ្យកាប់ មានមេកងគេមួយដឹកនាំឲ្យទៅកាប់ជី អំ កាប់ដើមទន្រ្ទានខែត្រ ដើមព្រៃឈើអីទៅចិញ្ច្រាំធ្វើជី ហើយក្រុមកុមារតូចៗហ្នឹងឃើញលី ទូលអូស ហើយកន្លែងមន្ទីរកុមារហ្នឹងនៅជិតកង១៤ កង១៦ កង១៤ ។ ហើយមានក្មេងតូចៗដែលស្រ្តីដែលមានប្តីហើយបង្កើតកូនបានហ្នឹង ឃើញនៅក្នុងបរិវេណគេហដ្ឋាននៅហ្នឹង នាងខ្ញុំតែងឆ្លងកាត់ដើរទៅធ្វើស្រែធ្វើអី តាមពេលដែលមេឲ្យទៅចំតាមផ្ទះកុមារនៅហ្នឹង ឃើញមានកុមារតូចៗខ្លះទើបកើតបានប្រហែលជា ពីរខែ បីខែ ឃើញម៉ែដោះហ្នឹងនៅមើលថែ ខ្លះស្គមស្គាំង ខ្លះនៅទុក នៅម្នួបៗមាត់នៅលើគ្រែហ្នឹង ខ្ញុំឃើញ ខ្ញុំគួរឲ្យអាណិតដល់ក្មេងនុ៎ង តែមិនដឹងធ្វើម៉េច ព្រោះយើងជាអ្នកទោសទាំងអស់គ្នាហ្នឹង ។

**ស៖** មុនពេលលោកស្រីចាកចេញពីទីនោះ ទៅដាំបន្លែនៅស្រុកស្អាង តើលោកស្រីកត់សម្គាល់ឃើញថាកុមារទាំងអស់នោះនៅរស់រានមានជីវិតនៅទីនោះដដែលទេ?

**ឆ៖** ចាស, កុមារហ្នឹងតាមខ្ញុំដឹង តែងដើរឆ្លងកាត់ហ្នឹង កុមារខ្លះស្លាប់ខ្លះ កុមារខ្លះរស់ ។ មុនពេល ដែលខ្ញុំទៅនៅដាំបន្លែងហ្នឹង កុមារភាគច្រើនគឺស្លាប់លោកប្រធាន ព្រោះវាអត់អាហារ វាស្គមស្គាំង ។ ហើយឈឺដាច់បាក់ទឹកដោះ ម្តាយទៅធ្វើការបាត់ទៅ អ្នកមើលហ្នឹងធ្វើថែរក្សារឲ្យហួបមិនដិតដល់ក្នុងការបំបៅដោះ ។

**ស៖** ក្នុងអំឡុងពេលនៃលោកស្រីដែលគេបញ្ជាឲ្យទៅធ្វើការរួមជាមួយនឹងអ្នកផ្សេងទៀត ដែលនៅក្នុងក្រុម ឬក៏កងជាមួយលោកស្រីហ្នឹង ក្នុងរយៈពេលធ្វើការហ្នឹង តើមានការត្រួតពិនិត្យតឹងតែងពីកងកម្លាំងដែលប្រដាប់ដោយអាវុធដែរឬទេ? ឬមួយគ្រាន់តែមានការតឹងតែងក្នុងនាមជាមេកង មេក្រុមដែលគ្រប់គ្រងលោកស្រីជាបន្តបន្ទាប់ ដោយពាក្យសម្តី ដោយកាយវិការធម្មតាអ៊ីចឹងទេ? ឬក៏មានប្រើប្រាស់ ឬក៏កាន់ដោយអាវុធមានកាំភ្លើងអីជាដើមដែរ?

**ឆ៖** ចាស, លោកប្រធាន នៅកន្លែងខ្ញុំ គឺអត់មានកងប្រដាប់អាវុធអី ទៅការពារទៅធ្វើទារុណ-កម្មតឹងតែងអីទេ គឺមានតឹងតែនឹងមេក្រុមមេកង ដែលគេគ្រប់គ្រងមើលយើងហ្នឹង ។ គេដាក់ផែនការថា

ឲ្យយើងធ្វើអ្វីឲ្យរួចគឺត្រូវតែរួច បើយើងធ្វើមិនរួចគឺយើងត្រូវពិន័យគេ ដូចថា គេពិន័យឲ្យយើងជីកប្រឡាយ លើកទំនប់ ឧទាហរណ៍ថា ឲ្យរួចប្រាំម៉ែត្រក្នុងមួយព្រឹក យើងត្រូវតែធ្វើឲ្យរួចបើធ្វើមិនរួចទេ គេឲ្យយើងធ្វើទាល់តែរួចហ្នឹងឯង នឹងការបង្ខិតបង្ខំហ្នឹង ។

**ស៖** លោកស្រីបានចាកចេញពីទីកង១៧ ហើយទៅកាន់កន្លែងមួយទៀតដែលលោកស្រីថាមានគេមនុស្សពីរនាក់មកនាំយកទៅហ្នឹង ។ ហើយលោកស្រីក្រោយមកដឹងថា ស្រុកស្អាងកោះធំ អំមិញប្រើពាក្យពាក្យពីរផង ។ ស្អាងផ្សេង កោះធំផ្សេង តាមភូមិសាស្ត្រនៅទីនោះ គឺស្រុកមួយស្រុកស្អាង ស្រុកមួយកោះធំ កោះធំនោះ គឺជាប់ដែនដីវៀតណាមឯណោះ ហើយចំណែកស្អាងហ្នឹង ជាប់នឹងតាខ្មៅជាប់នឹងតាខ្មៅនេះចម្ងាយពីតាខ្មៅហ្នឹង ប្រហែលជាប៉ុន្មានគីឡូ ប៉ុន្មានជាងប៉ប្រាំគីឡូទេ ។ តើលោកស្រីចាកចេញពីទីកង១៧ ទៅហ្នឹងប្រហែលជាថ្ងៃខែឆ្នាំណាដែរ?

[១៥:៣៨:១០]

**ឆ៖** ចាស, លោកប្រធាន នៅពេលដែលខ្ញុំចាកចេញពីកង១៧ហ្នឹង ចុងឆ្នាំ១៩៧៨ នៅពេលដែលស្រូវសន្ទូងហ្នឹង ស្រូវផើមហើយ ស្រូវខ្លះហាលផ្កា ។ ខ្ញុំគេនាំខ្ញុំដើរកាត់ប្រឡាយភ្លឺស្រែហ្នឹង ស្រូវវាហាលផ្កា ហើយពេលខ្ញុំទៅដល់ហ្នឹងនៅស្រុកស្អាងទេ តែគេថាស្រុកស្អាង និងកោះធំ វាជាប់គ្នាលោកប្រធាន ។

**ស៖** ក្នុងអំឡុងប្រហែលជាខែ១០ ឬក៏ខែ១១ មែនទេ?

**ឆ៖** ចាស, ក្នុងខែចុងខែ១០ ខែ១១ ហ្នឹងចូលខែ១១ ស្រូវយើងក្រហមខ្លះមេៗហើយ ។ ខ្ញុំត្បាញកន្ទេលដាំបន្លែផងចាក់ទឹកដំណាំផងចាក់ទឹកបន្លែផង ។ គេឲ្យខ្ញុំត្បាញកន្ទេលហើយគេដាក់ផែនការឲ្យខ្ញុំត្បាញកន្ទេលហ្នឹង លើកទីមួយ គេសួរយើងថា ចេះត្បាញកន្ទេល? ប្រាប់ថាចេះត្បាញកន្ទេលទៅ គេឲ្យយើងត្បាញកន្ទេល ។ ជំហានទីមួយ ក្បាលបណ្ដោយ៥ម៉ែត្រ ក្បាល៣ម៉ែត្រ ។ នាងខ្ញុំធ្វើ គេឲ្យធ្វើបីថ្ងៃរួច តែនាងខ្ញុំធ្វើពីរថ្ងៃរួចមុនបីថ្ងៃ តែពីរថ្ងៃនាងខ្ញុំធ្វើរួច ព្រោះកន្ទេលឆ្មោតហ្នឹងវាស្រួលត្បាញវាបន្ទោះធំៗហើយយើងត្បាញពេញៗដៃហ្នឹង ។

**ស៖** លោកស្រីស្គាល់បាគូទេ? នៅកន្លែងណាបាគូដែលស្គាល់ទេ?

**ឆ៖** ស្គាល់ ឮឈ្មោះដើរចំដែរ តែឥឡូវភ្លេចហើយលោកប្រធាន ។

**ស៖** កាលជំនាក់នោះ លោកស្រី ដែលបានទៅដល់បាគូទេ ទៅធ្វើការនៅបាគូដែរទេ?

**ឆ៖** បានទៅធ្វើលោកប្រធាន ព្រោះខ្ញុំនៅក្នុងកន្លែងកង១៤ កង១៧ នាងខ្ញុំមានស្គាល់បងស្រីមួយនៅកង១៤ ។ គាត់រស់នៅដល់សព្វថ្ងៃហ្នឹងឈ្មោះគាត់កាលជំនាន់ហ្នឹង គាត់ឈ្មោះ ជុំ ភី តែឥឡូវគាត់ឈ្មោះ ជុំ នៅ ។ ហើយបានជួបគ្នា ឡើងសវនាការជាញឹកញាប់មកហ្នឹង បានជួបគ្នាស្គាល់គ្នាហើយគាត់ប្រាប់ខ្ញុំថា យើងតែងទៅធ្វើការនៅបាគូហ្នឹងជាញឹកញាប់ជួបគ្នា ។

**ស៖** បាគូហ្នឹងនៅខាងណាក្រពើហា? នៅទិសខាងណានៃវត្តក្រពើហា?

**ឆ៖** បើខ្ញុំចាំស្រពិចស្រពិល ប្រហែលជាខាងត្បូងក្រពើហាលោកប្រធាន ។

**ស៖** ត្រលប់ក្រោយបន្តិចវិញ លោកស្រីក្រោយឆ្នាំថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩ ពីរបបកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីដែលបានចូលទៅទស្សនានៅសារមន្ទីរគុកទួលស្លែងដែរឬទេ? ហើយបើដែលទៅទៅនៅពេលណា?

**ឆ៖** ចាស, នៅក្រោយរំដោះ៧ មករា មក នាងខ្ញុំអត់ដែលបានទៅចូលកន្លែងទួលស្លែងទេ ។ ពេលដែលខ្ញុំមកពីភ្នំវិញ ខ្ញុំនៅជម្ពូវ័ន្តហ្នឹង ខ្ញុំបានចូលបម្រើជាកងទ័ពនៅជម្ពូវ័ន្តហ្នឹង នៅវរៈ៩ កងលខ១នៅឈរនៅជម្ពូវ័ន្តហ្នឹង វត្តជម្ពូវ័ន្តហ្នឹង ។ គេបបួលខ្ញុំនាងខ្ញុំទៅដែរ តែនាងខ្ញុំថា កាលណាតែឮមន្ទីរឃុំឃាំង ឮកន្លែងគុក នាងខ្ញុំមិនចង់ឃើញទាំងអស់ ព្រោះគឺជាការដែលឈឺចាប់ដែលនាងខ្ញុំបានរងគ្រោះហើយពួកនារីៗទាហានហ្នឹងថា អើ! មិត្តម៉េតៗ មិត្តឯងទៅៗ ចង់ឃើញទិដ្ឋភាពនៅទីនោះ គួរឲ្យចាប់អារម្មណ៍ណាស់ ។ នាងខ្ញុំថា ខ្ញុំមិនទៅទេ ហើយគេចេះតែបបួលនាងខ្ញុំ ខ្ញុំមិនដែលទៅទេលោកប្រធាន ខ្ញុំទើបតែទៅការដែលគេស្រាវជ្រាវរក ជនរងគ្រោះដែលរស់ពីស្លាប់ ។ ហើយគេបានយកប្រវត្តិរូបខ្ញុំមកឲ្យខ្ញុំហ្នឹង តាមរយៈអង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ដែលគេបានទៅខេត្តនាងខ្ញុំហើយគេនាំបងប្អូននាងខ្ញុំ គេធ្វើការខាងកិច្ចការនារីនៅស្រុកប្រាសាទបល្ល័ង្កហ្នឹង មកទស្សនកិច្ចនៅបឹងជើងឯកទួលស្លែង ។ ពេលដែលបងប្អូនខ្ញុំគេមកដល់ចូលមន្ទីរស-២១ អូ៎! ទួលស្លែងហ្នឹងគេឃើញ គេមើលតាមអាតាប្លូ ដាក់រូបថតទៅ គេឃើញរូបខ្ញុំហ្នឹង គេបានប្រាប់ទៅខាងអង្គការហ្នឹងថា នេះ ខ្ញុំ វារស់តើនេះរូបវាហ្នឹងមានស្លាប់ឯណា វានៅតើរាល់ថ្ងៃ ។ ទៅខាងអង្គការហ្នឹងបុគ្គលិកអង្គការហ្នឹង គេក៏ចេះសួរដេញដោលគាត់ ។ ហើយនាងខ្ញុំអត់ដឹងទេ ព្រោះនាងខ្ញុំមករស់នៅលើគំនរសម្រាបស្ទឹងមានជ័យ ។ នាងខ្ញុំនៅឯណោះអត់ពិបាកពេក តាំងពីអត់ឪពុកខ្ញុំស្លាប់ទៅ នាងខ្ញុំក៏ភៀសខ្លួនមកនៅកន្លែងគំនរសំរាមដើម្បីរើសអេតចាយចិញ្ចឹមកូន ។

ដល់ទៅពេលក្រោយមកទៀត ពួកកាសែតហ្នឹងគេសួររកគេមករកខ្ញុំដល់បឹងទំពុនហ្នឹង ហើយ

ខាងអង្គការមជ្ឈមណ្ឌលគេមករកខ្ញុំហើយ គេបានឲ្យទាំងរូបថត ។ គេដើរទស្សនកិច្ចហ្នឹង គេឲ្យរូបនេះខ្ញុំហើយ នេះក្រុមអង្គការគេហ្នឹង គឺបានឲ្យហើយថា រូបអ្នកពិតមែន ។ ខ្ញុំឃើញខ្ញុំថា ជារូបរបស់ខ្ញុំ តែខ្ញុំអត់ចង់ដឹងចង់ឮអីទាំងអស់ ព្រោះមួយជីវិតខ្ញុំហ្នឹង ខ្ញុំហែលឆ្លងកាត់អាទុក្ខលំបាកវេទនាឆ្អែតឆ្អន់ហើយ ។ ហើយកាលណាពេលដែលខ្ញុំបានប្ដី មានកូនខ្ញុំមិនដែលនិយាយប្រវត្តិខ្ញុំឲ្យប្ដី ឬឲ្យកូន ឲ្យបងប្អូនណាដឹងទាំងអស់ ។ រឿងរបស់ខ្ញុំ ខ្ញុំទុកតែក្នុងចិត្ត ព្រោះកាលណាខ្ញុំនឹកឃើញខ្ញុំឈឺចាប់ តែពេលដែលខ្ញុំបំបាត់មិនយកចិត្តទុកដាក់នឹងរឿងនោះ ខ្ញុំអត់មានខ្វាយខ្វល់អ្វីទាំងអស់ តែពេលដែលគេរកខ្ញុំឃើញហើយ គេបង្ហាញរូបភាពរូបអីទាំងអស់ ពេលនោះខ្ញុំមានអារម្មណ៍ថា ឈឺចាប់ ហើយវិលវល់ដូចចង់ឡប់សតិ ភ្លេចមុខភ្លេចក្រោយលោកប្រធាន ។ ហើយគេបាននាំខ្ញុំទៅមើលទៀត ហើយគេថា តើអ្នកស្គាល់រូបអ្នកអត់ ចូលមើលរូបទាំងអស់ហ្នឹង ។ ខ្ញុំទៅឃើញមិត្តនារីៗខ្ញុំ ខ្ញុំហើយបង ខ្ញុំនិងប៉ុន្មានអ្នកនៅហ្នឹងបង នៅកងអង្គភាពជាមួយគ្នាហ្នឹង ។ ខ្ញុំសឹងតែសន្លប់បាត់ស្មារតី មួយរំពេច តែពួកគេហ្នឹងបានគក់ច្របាច់ខ្ញុំទៅ គេថាពង្រឹងអារម្មណ៍ឲ្យនឹងធ័ ហើយមើលរូបខ្លួនឯង តើមួយណាស្គាល់ទេ? ខ្ញុំទៅខ្ញុំថា នេះរូបខ្ញុំនៅនេះជិតបងរ៉ន ។ បងរ៉ន ហ្នឹង គាត់ជាអ្នកដាំបាយនៅកងខ្ញុំ គាត់រាងកែកឆ្អែកម្ខាង ។ លោកប្រធានហ្នឹង ជាលើកទីមួយរបស់ខ្ញុំហើយនៅខែ១១ ឆ្នាំ២០០៧ ។

[១៥:៤៥:២៦]

**ស៖** ឥឡូវនេះ តើស្ថានភាពអាការៈរាងកាយ ក៏ដូចជាផ្នែកខាងស្មារតីរបស់លោកស្រីហ្នឹង វាមានបញ្ហាយ៉ាងម៉េចទៅដែលមានការបន្សល់ទុកតាំងពីក្នុងអំឡុងពេល ដែលមានការចាប់ឃុំឃាំងហើយមានការវាយដំលោកស្រីនោះ? តើអាការៈទាំងអស់នេះមានស្ថានភាពយ៉ាងម៉េចនាពេលបច្ចុប្បន្ន?

**ឆ៖** ចាស, លោកប្រធាន ខ្ញុំមានស្លាកស្នាម អានេះដែលគេចង់នឹងខ្សែទឡ្យងទៅ យើងមានដំបៅ ហើយកជើងនេះស្នាមដែលគេចាប់ មិនដឹងនឹងអីទេដាច់ដំបៅទៅពេលខ្ញុំទៅនៅកង១៧ហ្នឹង គេបានឲ្យថ្នាំឲ្យអីខ្ញុំលាបទៅជា តែមាស្លាកស្នាមនៅជាប់សព្វថ្ងៃហ្នឹង ។

**ស៖** ស្មារតីយ៉ាងម៉េចដែរ?

**ឆ៖** ចាស, បើនិយាយពីស្មារតីវិញ ។ ខ្ញុំឥឡូវរាងភ្លេចមុខ ភ្លេចក្រោយការចងចាំរបស់នាងខ្ញុំ គឺតិច ព្រោះបានថា ចងចាំតិចនៅក្នុងគ្រួសាររបស់នាងខ្ញុំ អ្នកដែលជំហាររក គឺតែរូបនាងខ្ញុំមួយចិញ្ចឹមប្ដី ចិញ្ចឹមកូន ចិញ្ចឹមក្មេងនៅក្នុង ខ្ញុំដើរទាក់ទងសុំខាងអង្គការផ្សេងៗ ដើម្បីឲ្យគេជួយក្មេងនៅក្នុងសហគមន៍របស់ខ្ញុំដែលជាជនក្រីក្រហ្នឹង ។ ដល់ពេលហ្នឹងហើយ ការងារខ្ញុំវាច្រើននោះ ភ្លេចភ្លាំងដល់យូរៗក្រុម

ការងារហ្នឹងគេស្ដីបន្ទោសឲ្យនាងខ្ញុំថា វរវល់តែគិតរឿងខ្មែរក្រហម បានជាការងារហ្នឹងបាត់ការចងចាំ ភ្លេចមុខភ្លេចក្រោយ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រី តើចៅក្រមតើមានសំណួរអ្វីសួរដល់ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? មានទេ?

តទៅនេះ សូមប្រគល់វេទិកានេះជូនទៅសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញា ដើម្បីឲ្យមានឱកាសក្នុងការសួរ ។ ហើយមានពេលវេលាសាមសិបនាទីក្នុងការសួរនេះ ។ បើមានសំណួរសូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក សេង ប៊ុនឃាង៖**

អរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ឈប់ៗ ។ សុំបង្អង់បន្តិច លោក ហ្សង់ម៉ាក មានបញ្ហាអីទៅ?

សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ជាការពិត វាហាក់ដូចជាមានប្រយោជន៍ណាស់សម្រាប់យើង មុនពេលដែលយើងបន្ត ។ វាមានប្រយោជន៍ក្នុងការបង្ហាញនូវរូបថត និងប្រវត្តិរូបទៅឲ្យជនជាប់ចោទពិនិត្យមើល ។ ហើយថាតើជនជាប់ចោទហ្នឹងគាត់ស្គាល់ដែរឬទេ ថាវាជាឯកសារនិងប្រវត្តិរូប រូបភាពចេញមកពីស-២១?

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ សូមបញ្ចាំងនូវឯកសារចំនួនពីរសាជាថ្មីម្ដងទៀត ឯកសារដែលមានលេខ ERN ជាភាសាខ្មែរ 00343199 ហើយនិងលេខ 00343200 ។

ជនជាប់ចោទ ពិនិត្យមើលនូវរូបថតទីមួយនេះ នេះជារូបថតក្មេងស្រីម្នាក់ ។ សំណួរសួរថាលោកកត់សម្គាល់ថារូបថតនេះយ៉ាងម៉េចដែរ? ជារូបថតដែលចេញពីមន្ទីរស-២១ ឬក៏យ៉ាងម៉េច?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! រូបថតនេះពិតជារូបថតដែលចេញពីមន្ទីរស-២១ មជ្ឈមណ្ឌលព្រៃស ប្រាកដ ។

**ប្រធានអង្គជំនុំ៖**

បង្ហាញនូវប្រវត្តិរូប និងរូបថតមួយទៀតដែលមានលេខ 00343200។

ជនជាប់ចោទពិនិត្យមើលឯកសារប្រវត្តិរូបសង្ខេបរបស់ យឹម ម៉េត ហើយនិងរូបថត ឯកសារនេះ តើចេញពីមន្ទីរស-២១ ឬក៏មិនមែនទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ឯកសារនេះ ពិតជាឯកសារដែលចេញពីមន្ទីរស-២១ មជ្ឈមណ្ឌលព្រៃស ។ នៅទំព័រខាងដើម នៅផ្នែកខាងឆ្វេង ផ្នែកខាងលើក្រោមលេខ*ERN* នេះ លេខ*ERN* បោះពុម្ពទៅរលុប ។ ស-២១ ច្បាស់ថែសនៅនុ៎ង ។ ហើយទីពីរទម្រង់បែបបទនេះជាទម្រង់បែបបទដែល មិត្តហ៊ុយ ធ្វើសម្រាប់អ្នកដែលទៅនៅក្នុងមជ្ឈមណ្ឌលព្រៃសនេះ ទទួលការអប់រំសាថ្មី ។ ហើយឯកសារនេះបានបញ្ជាក់ច្បាស់ថា កងចាស់លេខ៤៥០ កងពលលេខ៤៥០ បច្ចុប្បន្ននៅកង១៧ ហើយចុងខាងក្រោមបានចារច្បាស់ថា មិត្តម៉េត ទៅដល់ទីនោះនៅថ្ងៃ១២ ខែតុលា ឆ្នាំ១៩៧៧ ។ អាហ្នឹងខ្ញុំសូមទទួលស្គាល់ទាំងស្រុង ។ ហើយទន្ទឹមនេះខ្ញុំក៏សូមមេត្តាបញ្ជាក់បន្ថែមបន្តិច។ នៅពេលដែលខ្ញុំអានពាក្យបណ្តឹងរបស់មិត្តម៉េត ខ្ញុំចារពីក្រោមច្បាស់របស់ខ្ញុំណាស់ នេះថាខ្ញុំទទួលស្គាល់ថាបណ្តឹងរបស់មិត្តម៉េតចេញមកពីសុទ្ធចិត្ត ខ្ញុំរង់ចាំតែរូបថតហើយនិងឯកសារបន្ថែម ។ ដល់ឃើញរូបថតមកហើយនិងឯកសារបន្ថែមមកខ្ញុំអត់តថ្លៃពីរឿង ខឹម ម៉េត ផ្សេង ជិន ម៉េត ផ្សេងទេ ខ្ញុំទទួលស្គាល់ ខឹម ម៉េត ក៏ដោយ ជិន ម៉េត ក៏ដោយគឺមនុស្សម្នាក់ដែលទៅរងទុក្ខនៅទីនោះ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះដោយគោរព ។

**ប្រធានអង្គជំនុំ៖**

ឥឡូវលោកបានទទួលស្គាល់ហើយ ប៉ុន្តែមានបញ្ហាមួយទៀត ។ ជនជាប់ចោទតើអាចបញ្ជាក់បាននៅពេលនេះទេ ដោយ ជិន ម៉េត គាត់បានអះអាងថា គាត់ទៅជាប់ឃុំឃាំងដប់ប្រាំយប់ ដប់ប្រាំថ្ងៃ ហើយនៅកន្លែងមួយ ។ ហើយនៅបណ្តឹងរបស់គាត់ គាត់ដាក់ថាមន្ទីរនោះគឺជាមន្ទីរស-២១ ដែលគុកទួលស្លែង ហើយដល់ពេលគាត់ឆ្លើយនៅពេលនេះ គឺគាត់មិនបញ្ជាក់ចំណុចនេះច្បាស់លាស់ទេ ប៉ុន្តែជាផ្នែកខាងចុង គឺលទ្ធផលដែលគាត់បញ្ជូនទៅមន្ទីរអប់រំកែប្រែព្រៃស លោកទទួលស្គាល់ ។ សំណួរសួរថា អាការឃុំខ្លួន ដប់ប្រាំយប់ដប់ប្រាំថ្ងៃនោះ តើលោកកត់សម្គាល់អាទីកន្លែងដែលឃុំឃាំងគាត់ហ្នឹងយ៉ាងម៉េចដែរ?

[១៥:៥៣:៤៦]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! បញ្ហានេះខ្ញុំអត់ចង់និយាយទេ ព្រោះបើនិយាយទៅវាប៉ះទង្គិចអារម្មណ៍ មិត្តម៉េត ខ្លាំង ។ ប៉ុនឥឡូវបើលោកប្រធានសួរទៅហើយខ្ញុំត្រូវតែនិយាយ ។ ខ្ញុំសុំសន្និដ្ឋានថា មិត្តម៉េត ជាប់ឃុំនៅមន្ទីរឃុំឃាំងរបស់កងពល៤៥០ ។ ខ្ញុំបានយកសេចក្តីសារភាពរបស់ មិត្តសួង ឈ្មោះដើម ជា នុន លេខា៤៥០ចាស់មុនយកមកអាន ។ មិត្តសួង សារភាពអំពីការដែលខ្លួនបានចាប់មនុស្សនៅក្នុងកងពល៤៥០ ទៅដាក់ឃុំនៅនុ៎ង ។ ហើយសែងមនុស្សឈឺទៅឲ្យកាប់ដីអីមាន ដោយសេចក្តីសារភាពរបស់ជនរងគ្រោះយកជាការមិនបាន ខ្ញុំក៏ត្រៀមឯកសារមួយទៀតបញ្ជាក់ជូនអង្គសវ-នាការថា គ្រប់កងពលសម័យនោះសុទ្ធតែមានមន្ទីរឃុំឃាំង ។ ភស្តុតាងគឺនៅសំបុត្ររបស់ ស៊្វ ម៉េត ចុះថ្ងៃ៦ មិថុនា ១៩៧៧ លេខ*ERN* ជាភាសាខ្មែរ 00173329, *ERN*ជាភាសាអង់គ្លេស 00226100, *ERN* ជាភាសាបារាំង 00233327 នៅឃ្លាខាងក្រោមបង្អស់ ស៊្វ ម៉េត សរសេរថា ឈ្មោះទាំងនេះគឺបីនាក់នេះ ខាងលើនេះ ខ្ញុំបានឃាត់ខ្លួនយូរមកហើយ ប៉ុន្តែវាឆ្លើយសារភាពមិនទាន់បានច្បាស់លាស់នៅឡើយ ។ ផ្ញើនៅថ្ងៃ១ មិថុនា ១៩៧៧ ចូលគណៈកងពល៥០២ ។

សរុបមកខ្ញុំជឿថា មិត្តម៉េត ជិន ម៉េត នេះ រងទុក្ខវេទនាដែលគេឃុំឃាំងសួរចម្លើយនៅកង៤៥០ ។ ខ្ញុំនិយាយយ៉ាងនេះ មិនមែនចង់បដិសេធឧក្រិដ្ឋកម្មខ្លួនឯងទេ ក៏ប៉ុន្តែការបញ្ជូនទៅស-២១ តែបញ្ជូនចូលទៅដល់អាមជ្ឈមណ្ឌលគុកនៅភ្នំពេញហើយ អត់ចេញទេ មិត្តម៉េត គឺមិត្តនៅនុ៎ង ខ្ញុំយកទៅដើងឯកហើយ ។ ដូច្នេះខ្ញុំទទួលស្គាល់ថា មិត្តចេញពី៤៥០ ទៅចូលព្រៃស ។ នេះគឺប៉ុណ្ណឹងដូច្នេះបានជាខ្ញុំពិបាកនឹងនេះ ។

សរុបមកខ្ញុំមិនបដិសេធឧក្រិដ្ឋកម្មអីទេ ក៏ប៉ុន្តែចង់បញ្ជាក់ថា ការប្រតិបត្តិជំនាន់នុ៎ងវាអ៊ីចឹងចេញពីកងពលឲ្យតែទៅចូលក្នុងស-២១ភ្នំពេញ ហើយអត់មានអ្នកណានៅរស់ទេ គ្មានសល់បានរស់ទេ ស្លាប់អស់ហើយ ។ នេះខ្ញុំគ្រាន់តែសុំបញ្ជាក់ ប៉ុណ្ណោះសុំចប់ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ មន្ត្រីសោតទស្សន៍សូមបង្ហាញនូវឯកសារERN00173329 នៅលើអេក្រង់ទូរទស្សន៍។ បញ្ជូនទៅ រំកិលឡើងលើ១ បានហើយ ។ បានហើយមន្ត្រីសោតទស្សន៍បង្វែររូបភាពទៅជារូបភាពធម្មតាឡើងវិញ ។

ជាកិច្ចបន្តនេះ សូមប្រគល់វេទិកានេះទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសក្នុងការសាកសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជិន ម៉េត ។ សូមអញ្ជើញ ។

ឥឡូវបង្អង់ម្តងទៀតជាលើកទីពីរហើយ ដោយអង្គជំនុំជម្រះ ដូចអត់យល់គ្នានាំឲ្យមានបញ្ហា ។

អញ្ជើញលោកចៅក្រម។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** សូមអរគុណលោកប្រធាន ។ សូមអរគុណចំពោះចម្លើយរបស់លោកស្រី ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរឲ្យបំភ្លឺទៅលើចំណុចមួយចំនួន ។ លោកស្រីបានពន្យល់ថា លោកស្រីស្ថិតនៅក្នុងផ្នែកមួយនៃកងពល៤៥០ ហើយស្ថិតនៅក្នុងកងយុទ្ធនារី ។ តើលោកស្រីអាចជម្រាបយើងខ្ញុំដែរឬទេថាតើវាជាអង្គភាពធំមួយដែរឬទេ? ហើយថាតើយុទ្ធនារីនោះជាផ្នែកនៃកងពលនោះយ៉ាងម៉េច? ហើយលោកស្រី ក៏បានដឹង ក៏បានជម្រាបថា បន្តិចម្តងៗគឺយុទ្ធនារីគាត់បានបាត់ខ្លួន ហើយតើលោកស្រីអាចជម្រាបអំពីបញ្ហានេះឲ្យបានពិស្តារជាងនេះបន្តិចដែរឬទេ?

**ឆ៖** ចាស, ខ្ញុំអាចនិយាយបាន ។ កាលដែលនាងខ្ញុំរស់នៅក្នុងកងពលទី៣ លេខ៤៥០ហ្នឹង ក្នុងកងពលទី៣ហ្នឹង មានបងសួង, បងយ៉ាន់ ជាប្រធានកងពល កាន់កងពលហើយគាត់បានរៀបចំអង្គភាពនារីហ្នឹងជាកូនពៅ បន្ទាប់ពីបុរសក្នុងអង្គភាព៤៥០ កង៤៥០ហ្នឹង មាននារីហ្នឹងអត់មានលេខកង លេខអង្គភាពគឺយកលេខកងពលទី៣ ហ្នឹងដាក់កង៤៥០ ជាលេខកងនារីតែម្តង។

**ស៖** តើលោកស្រីដឹងដែរឬទេអំពីចំនួនយុទ្ធនារីដែលធ្វើការនៅក្នុងកងពលនេះ? ថាតើមានចំនួន ៥០, ១០ នាក់, ២០ ឬក៏មានចំនួនច្រើនជាងហ្នឹង?

**ឆ៖** គឺមានចំនួនច្រើនព្រោះការដែលនាងខ្ញុំនៅកងនារីហ្នឹង គេចាត់ជាបីកងធំ ។ ក្នុងមួយកងធំមានជាងមួយរយនាក់ បើបូកសរុបទាំងអ្នកដាំស្ល ទាំងអ្នកកាន់ខាងសម្ភារៈ សរុបទាំងអស់វាបួនរយជាង បួនរយលើសខ្លះ លើសតិចតួច លោកប្រធាន ។

**ស៖** តើលោកស្រីចាំទេ ចាំអំពីថ្ងៃខែដែលលោកស្រីបានកត់សម្គាល់ថា យុទ្ធនារីនោះមានការបាត់ខ្លួនចេញពីកងពលហ្នឹង ឬក៏អង្គភាពនេះ?

[១៦:០២:១៨]

**ឆ៖** នាងខ្ញុំអត់បានចាំថ្ងៃ ចាំខែទេ តែនាងខ្ញុំចាំឆ្នាំ គឺនៅក្នុងឆ្នាំ១៩៧៧ ។ នៅក្នុងអង្គភាពនារីនាងខ្ញុំហ្នឹងដាក់កន្លែងធ្វើការហ្នឹងបីកន្លែង ។ កងធំទីមួយ នៅពីស្ពានជ្រោយចង្វារដល់គីឡូលេខ៦ ច្រាំង

ចំរេះ ។ ឯកងធំទីពីរនៅព្រៃកញ្ចៅ អន្លង់ក្ងាន កប់ស្រូវ ។ ឯកងធំទីបី នៅឯទួលគោកក្រោយផ្ទះ មួយរយខ្ទងគឺធ្វើស្រែប្រាំង ចែកជាបីកង ។ តែក្រោយមកទៀត នៅក្នុងឆ្នាំ១៩៧៧ ដដែលហ្នឹងពួកមេៗ ខ្ញុំដូចជាប្រធានវរៈ ប្រធានកងអីហ្នឹងចេះតែបាត់ហែរបន្តបន្ទាប់គ្នាមក ។ ក្រោយមកទៀត នាយកងខ្ញុំ បាត់ ដែលខ្ញុំរស់នៅផ្ទាល់ជាមួយនឹងក៏បាត់ រហូតដល់នាងខ្ញុំ គេហៅខ្ញុំទៅកសាងអប់រំម្ដងជាពីរដង បីដង រហូតដល់ខ្ញុំមានអារម្មណ៍មួយចង់ធ្វើឃាតខ្លួនឯង នាងខ្ញុំនៅក្នុងឆ្នាំ១៩៧៧ ដដែល ។

**ស៖** ថាតើគេមាននិយាយអ្វីទាក់ទងទៅនឹងការបាត់ខ្លួននេះ? ថាតើគេដឹងថា គេនាំខ្លួនពីមួយ ពីតំបន់មួយទៅតំបន់មួយ កន្លែងមួយទៅកន្លែងមួយដែរឬទេ? ហើយគេមានប្រាប់ថា នាំអ្នកទាំងអស់នោះទៅអប់រំដែរឬទេ? គេមាននិយាយប្រាប់យ៉ាងម៉េចនៅពេលដែលបាត់ខ្លួននោះ?

**ឆ៖** នៅពេលដែលបាត់ខ្លួនបងៗនោះ ពួកនាងខ្ញុំដែលនៅជាកូនក្រុមៗហ្នឹងបានសួរទៅមេដឹកនាំថ្មីនោះថា ចុះពួកអ្នកដឹកនាំចាស់ៗហ្នឹងទៅណាអស់ហើយ ។ គេក៏បានប្រាប់មកពួកខ្ញុំវិញថា មិនបាច់ព្រួយបារម្ភទេ គេយកទៅ គេឲ្យទៅរៀនសូត្រនៅកន្លែងថ្មី ។

**ស៖** ថាតើមានចំនួនមនុស្សច្រើនទេដែលបាត់ខ្លួននោះ ឬក៏វាមានការបាត់ខ្លួននោះក្នុងចំនួនតិចតែ ប៉ុណ្ណោះតាមដែលលោកស្រីចងចាំ?

[១៦:០៥:០០]

**ឆ៖** ចាស តាមដែលនាងខ្ញុំធ្លាប់រស់នៅអង្គភាពហ្នឹងគឺនារីៗហ្នឹងបាត់ខ្លួនប្រហែលជាហាសិបភាគរយ បាត់ខ្លួនមិនឃើញមុខមិនឃើញសំឡេង ឃើញមនុស្ស គឺបាត់តែម្ដង ។ លើសពីហាសិបភាគរយផង លោកប្រធាន ។

**ស៖** ដូច្នេះយើងយល់ប្រាកដថានៅក្នុងបញ្ជីអ្នកទោស ដែលបញ្ជីនេះបានបង្កើតឡើងដោយខាងអយ្យការ យើងឃើញមានចំនួនមនុស្សអ្នកទោសច្រើនណាស់មកពីកងពល៤៥០ ហើយយើងក៏ឃើញយុទ្ធនារីនៅក្នុងបញ្ជីអ្នកទោសនោះផងដែរ។ ហើយព្រឹកមិញនេះលោកបានផ្ដល់ លោកស្រីបានផ្ដល់នូវឈ្មោះអ្នកមួយចំនួនដែលលោកស្រីស្គាល់ ហើយលោកស្រីមិនបានផ្ដល់ត្រកូលរបស់អ្នកទាំងអស់នោះទេ តើមែនដែរឬទេ?

ឧទាហរណ៍លោកស្រីនិយាយអំពី យ៉ាត, ឈឿន អំពី សែន, អំពីណាំ ។ ដូច្នេះ ខ្ញុំសូមនិយាយសាថ្មីថានៅក្នុងបញ្ជីអ្នកទោសខាងសហព្រះរាជអាជ្ញា យើងអាចឃើញមានឈ្មោះ ហើយវាឈ្មោះទាំងអស់នោះវាស្រដៀងៗលោកស្រីបានលើកឡើង ហើយយើងក៏បានមើលឃើញឈ្មោះ និងឈ្មោះ ហៅ

ក្រៅ និងបដិវត្តន៍ផងដែរ ។ តើលោកស្រីអាចចាំត្រកូលឈ្មោះដែលលោកស្រីបានលើកឡើងទាំងអស់នោះដែរឬទេ ឬក៏លោកស្រីមិនអាចចាំទាល់តែសោះ?

**ឆ៖** ចាស, លោកប្រធាន នៅក្នុងកងនារីរបស់ខ្ញុំហ្នឹងមិនអាចស្គាល់ត្រកូលគ្នាទេ បងៗហ្នឹងគេសុទ្ធជាមេដឹកនាំធំ ដូចជាប្រធានវរៈ ប្រធានកងធំ ប្រធានកងតូចអី គឺពួកនាងខ្ញុំមិនអាចស្គាល់ត្រកូលគេបានទេ បានត្រឹមហៅគេបងៗ បើថាស្គាល់ឈ្មោះបងយ៉ាត, បងយ៉ាត ជាប្រធានកងនារីនោះ ហៅបងយ៉ាត បើបងសែន ហៅបងសែន, បងណាំ ហៅបងណាំ ។ អត់ស្គាល់ត្រកូលទេ ។ គ្រាន់តែដឹងមកពីខេត្ត មកពីស្រុក គឺស្គាល់, ស្រុកសន្ទុក, ស្រុកសណ្តាន់, ស្រុកកំពង់ស្វាយ គឺស្គាល់ស្រុកស្គាល់ឈ្មោះ តែអស់ស្គាល់ត្រកូលទេ ។

**ស៖** នៅពេលដែលលោកស្រីបានត្រឡប់មកជាមួយខាងមជ្ឈមណ្ឌលឯកសារកម្ពុជាទៅទួលស្លែង នៅពេលដែលទៅទួលស្លែងនោះ លោកស្រីបាននិយាយថាលោកស្រីស្គាល់យុទ្ធនារីមួយចំនួនតាមរយៈរូបថត ។ ហើយរូបថតទាំងអស់នោះ គឺវាមានដាក់លេខ ឬក៏រូបភាពហ្នឹងវាដូចដែលរូបភាពដែលលោកស្រីបានឃើញ រូបភាពលោកស្រីនេះ ។ តើរូបភាពហ្នឹងមានលេខដែរឬទេ ឬក៏អត់លេខ? ថាតើមានលេខ ឬក៏អត់លេខនៅលើរូបថតទាំងអស់នោះដែរឬទេ ឬក៏នៅលើរូបថតដែលលោកស្រីឃើញនោះមិនមានលេខដែលវាបញ្ជាក់អំពីអ្នកទោស? លោកស្រីអាចជម្រាបប្រសិនបើចាំ តែប្រសិនមិនចាំទេក៏មិនអីដែរ ។

[១៦:០៩:១៦]

**ឆ៖** ចាស, រូបថតបងៗដែលខ្ញុំឃើញនៅក្នុងសារមន្ទីរហ្នឹងនៅក្នុងកង៤៥០ហ្នឹង មិត្តនារីហ្នឹងអត់មានលេខទេចាស គឺមានធម្មតាៗដូចរូបខ្ញុំដែរ ។

**ស៖** ជាថ្មីម្តងទៀត តាមការចងចាំរបស់លោកស្រី តើលោកស្រីចាំដែរឬទេថា ក្នុងពេលដែលសួរចម្លើយនោះ តើអ្នកសួរចម្លើយនោះគេហៅគ្នាគេដោយប្រើឈ្មោះដែរឬទេ ហើយលោកស្រីបានឮឈ្មោះដែលគេហៅគ្នានោះដែរឬទេ?

**ឆ៖** ចាស,អត់មានឮហៅឈ្មោះទេ ឮតែគេនិយាយគ្នាចំៗតែម្តង បង ឬក៏ហៅជាអក្សរកាត់បើថា មិត្តខ គឺមិត្តខ, មិត្តក គឺមិត្តក ។ គេអត់ហៅឈ្មោះទេ ឬមួយគេហៅថា មិត្តឯងមកណេះ ត្រូវធ្វើអានេះ ។ ខ្ញុំស្តាប់បានអ៊ីចឹង ។

**ស៖** ជាថ្មីម្តងទៀត នៅពេលដែលលោកស្រីទៅទួលស្លែង នៅពេលដែលលោកស្រីទៅទស្សនកិច្ច ឬក៏ទៅមើលអគារផ្សេងៗនោះ តើលោកស្រីស្គាល់ទីកន្លែងដែលវាស្រដៀងទៅនឹងបន្ទប់ឃុំខ្លួនលោកស្រីដែរឬទេ ឬក៏វា ឬក៏លោកស្រីបានឃើញបន្ទប់ ឬអគារដែលស្រដៀងទៅនឹងកន្លែងដែលគេសួរលោកស្រីដែរឬទេ?

**ឆ៖** ចាស, លោកប្រធាន កាលដែលគេសួរខ្ញុំ នាងខ្ញុំអត់ដឹងថាគេសួរនៅកន្លែងណាទេ ព្រោះកាលដែលគេសួរចងភ្នែកយើងជិតអស់ហើយ តែគ្រាន់តែនាងខ្ញុំចំណាំថាអគារហ្នឹងវាបណ្តោយថ្ងៃ តែមិនដឹងនៅកងពល៤៥០ ឬមួយនៅក្នុងមន្ទីរទួលស្លែង ព្រោះនាងខ្ញុំអត់ស្គាល់ ហើយក៏ចាំមិនបានដែរ ព្រោះកាលគេចាប់ហ្នឹងគេចងមុខជិតរហូត ។

**ស៖** ចំពោះបន្ទប់ដែលគេឃុំខ្លួនលោកស្រី ថាតើនៅពេលដែលលោកស្រីទៅមើលអគារនោះឡើងវិញ តើវាមានធ្វើឲ្យលោកស្រីចងចាំថាវាស្រដៀងទៅនឹងបន្ទប់ឃុំខ្លួនលោកស្រីដែរឬទេ?

**ឆ៖** នាងខ្ញុំគ្រាន់តែថា បន្ទប់ដែលនាងខ្ញុំនៅហ្នឹងរៀបជាប្អូនជ្រុងក្នុងបន្ទប់ហើយ បង្អួចឈើមានចម្រឹងដែក ។ បង្អួចមុខមួយក្រោយមួយមានទ្វារឈើហើយក្រាលការ៉ូ ហើយខាងជាន់លើហ្នឹងមានចាក់ធ្នឹមចាក់អីធម្មតាដូចផ្ទះថ្មយើងធម្មតាហ្នឹង ។ តែពេលដែលយើងមើលទៅវាគ្រាន់តែប្រហែលៗ តែគ្រាន់ថាអារម្មណ៍នាងខ្ញុំចាំមិនបានថា កន្លែងគុកហ្នឹងជាគុកនៅកន្លែងណាឈ្មោះអី គឺចាំអត់បានអត់ស្គាល់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណច្រើនចំពោះលោកស្រីដែលបានបំភ្លឺ ។ ខ្ញុំពុំមានសំណួរបន្ថែមសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីនេះទៀតទេ ។ សូមអរគុណ ។

[១៦:១៣:២៩]

**ប្រធានអង្គជំនុំ៖**

អរគុណច្រើនលោកស្រី ជិន ម៉េត ហើយអង្គជំនុំជម្រះក៏បានយល់ពីបញ្ហាលំបាករបស់លោកស្រីដែរ ដែលលោកស្រីមកឆ្លើយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះនេះ ។ ហើយអរគុណដែលបានអញ្ជើញមកតាមការកោះហៅរបស់អង្គជំនុំជម្រះ ។ ហើយដោយសារហេតុផលវាពាក់ព័ន្ធជាមួយនឹងភាពលំបាកវេទនារបស់លោកស្រីពីអតីតកាលផង ហើយរឿងហេតុហ្នឹងវាកើតឡើងដល់សាមសិបឆ្នាំហើយ។ ប៉ុន្តែសវនាការគឺចំពោះការស្តាប់សេចក្តីថ្លែងការណ៍ ឬក៏សក្ខីកម្មរបស់លោកស្រី គឺមិនទាន់ចប់ទេ ។ អ៊ីចឹងអង្គជំនុំជម្រះនឹងអញ្ជើញលោកស្រី អញ្ជើញលោកស្រីមកចូលរួមនៅក្នុងសវនាការនៅថ្ងៃស្អែកនៅវេលា

ព្រឹកចាប់ពីម៉ោងប្រាំបួនព្រឹកទៀត ។

ហើយមន្ត្រីតុលាការសម្របសម្រួលគាត់ដើម្បីឲ្យជាមួយនឹងអង្គភាព អង្គភាពរបស់គាំពារជនរងគ្រោះ ដើម្បីឲ្យគាត់ត្រឡប់ទៅលំនៅដ្ឋានវិញបានដោយសុវត្ថិភាព និងត្រឡប់មកកាន់សាលសវនាការវិញ ។

សវនាការថ្ងៃនេះដល់ត្រូវពេលសម្រាកហើយ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកសវនាការថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅព្រឹកថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំបួនព្រឹកទៅ ។ ដូច្នេះភាគីទាំងអស់សូមអញ្ជើញចូលរួមតាមពេលវេលាដែលបានជម្រាបជូននេះ ។

ហើយស្អែកនេះគឺយើងធ្វើនឹងសក្ខីកម្មចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀតដែលយើងបានបម្រុងទុក ប្រសិនបើពេលវេលាហ្នឹងគឺអាចនៅសល់ យើងនឹងធ្វើបន្ត ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ។

*[សវនាការផ្អាកនៅម៉ោង១៦:១៥:៣០]*